**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale De Droit Et Des Sciences Économiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ប្រសិត សេដ្ឋា**

លោក **ឡោ គឹមស្រ៊ុន**

ណែនាំដោយ៖

លោក **ភខ ស៊ីផាន់ណារ៉ា**


ថ្នាក់បរិញ្ញបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale De Droit Et Des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ប្រសិត សេដ្ឋា**

លោក **ឡោ គឹមស្រ៊ុន**

ណែនាំដោយៈ

លោក **គង ស៊ីផាន់ណារ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# **សេចក្តីថ្លែងអំណរគុណ**

📖📖📖📖

យើងខ្ញុំឈ្មោះ **ប្រសិត សេដ្ឋា** និងនិស្សិតឈ្មោះ **ឡោ គីមស្រ៊ុន** ជានិស្សិត **ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ** ឆ្នាំទី៤ ជំនាន់ទី២៤ ក្រុមL4C01សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២៣-២០២៤ សូមសម្តែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតមិនអាចកាត់ថ្លៃបាន គោរពជូនចំពោះ៖

១.លោកអ្នកមានគុណទាំង៤ គឺលោកឪពុក **អ៊ិត ប្រសិត** អ្នកម្តាយ **ឡាង សុមាលី** និងលោកឪពុក **ឡោ ហាក់** អ្នកម្តាយ **អ៊ឹង ស៊ិនមៀន** ដែលបានផ្តល់កំណើតដល់រូបយើងខ្ញុំ ព្រមទាំងបានបីបាច់ថែរក្សាផ្គត់ផ្គង់ការស្នាក់នៅ ផ្គត់ផ្គង់អាហារហូបចុក ថ្នាំសង្កូវ និងផ្គត់ផ្គងការសិក្សារបស់យើងខ្ញុំទាំងពីរចាប់ពីមត្តេយ្យសិក្សា រហូតមកដល់ថ្នាក់បរិញ្ញាបត្រ ថែមទាំងបានរួមចំណែកជាកម្លាំងចិត្ត  ការបង្រៀនប្រៀនប្រដៅ និងបានចិញ្ចឹមបីបាច់យើងខ្ញុំប្រកបដោយព្រហ្មវិហារធម៌របស់លោកអ្នកមានគុណ ។ សេចក្តីដឹងគុណទាំងអស់នេះមិនអាចកាត់ថ្លៃបានទេ ហើយក៏មិនអាចរៀបរាប់អស់សេចក្តី ផងដែរចំពោះគុណឧបការៈរបស់លោកអ្នកមានគុណទាំង៤ ដែលមានមកលើរូបយើងខ្ញុំបានឡើយ  ។

២.ទន្ទឹមនឹងនេះផងដែរយើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ** ព្រមទាំង **សាស្ត្រាចារ្យទាំងអស់** របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលតែងតែងខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះ ការបង្ហាត់បង្ហាញ ក៏ដូចជាបានផ្តល់នូវបទពិសោធល្អៗដល់យើងខ្ញុំដើម្បីជាត្រីវិស័យចង្អុលបង្ហាញក្នុងការសរសេរសារណារបស់យើងខ្ញុំប្រកបដោយភាពជោគជ័យជាទីបំផុត ។

៣.លើសពីនេះទៀតយើងខ្ញុំសូមថ្លែងអំណរគុណចំពោះ **លោក គង ស៊ីផាន់ណារ៉ា** ដែលលោកជាអ្នកណែនាំសារណារបស់យើងខ្ញុំ ដែលលោកតែងតែណែនាំ ផ្តល់ជាគំនិតយោបល់ល្អៗ ពិសេសបានបំពេញបន្ថែមនៅចំណុចខ្វះខាតដែលយើងខ្ញុំទាំងពីរខ្វះខាត ក៏ដូចជាបានជំរុញឲ្យយើងខ្ញុំខិតខំធ្វើយ៉ាងណាឲ្យសម្រេចបានលទ្ធផលល្អក្នុងការសរសេរសារណា ។

ជាចុងបញ្ចប់ យើងខ្ញុំសូមគោរពជូនពរ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត** ព្រមទាំង **មិត្តអ្នកអានទាំងអស់** ជួបតែសេចក្តីសុខ សេចក្តីចម្រើន រកទទួលទានមានបាន ព្រមទាំងបានជួបប្រទះតែពុទ្ធិពរទាំងឡាយបួនប្រការគឺ **អាយុ  វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

# **អារម្ភកថា**

យើងខ្ញុំទាំងពីរនាក់ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោយពីបានបញ្ចប់ការសិក្សារយៈពេល០៤ឆ្នាំ លើជំនាញនេះរួចមក ក៏មានគោលបំណងក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ ដោយយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលជាប្រយោជន៍ទូទៅក្នុងមជ្ឈដ្ឋានអ្នកច្បាប់ គឺប្រធានបទ “**នីតិវិធីក្នុងការបង្កើតក្រុមហ៊ុននៅកម្ពុជា**” មកធ្វើជាប្រធានបទក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ ។

ដោយបានសិក្សាស្រាវជ្រាវរៀនសូត្រ និងចាប់អារម្មណ៍លើផ្នែកពាណិជ្ជកម្មនេះ បានធ្វើឲ្យយើងខ្ញុំទាំងពីរនាក់បានចិញ្ចឹមចិត្ត និងសម្រេចយកប្រធានបទនេះមកធ្វើជាប្រធានបទសារណាដើម្បីស្វែងយល់បន្ថែមពាក់ព័ន្ធជាមួយនីតិវិធីក្នុងការបង្កើតក្រុមហ៊ុននេះ ក៏ដូចជាការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនតាមប្រភេទនីមួយៗ ព្រមទាំងការបិទបញ្ចីផ្សេងៗក្នុងករណីក្រុមហ៊ុននោះ ក្ស័យធនជាដើម ។ ពិសេសជាងនេះទៅទៀត **ពាណិជ្ជកម្មកម្ពុជា** កំពុងមានការរីកចម្រើនជាខ្លាំង ដែលជាហេតុផលមួយផងដែរក្នុងការឲ្យមជ្ឈដ្ឋានទូទៅបានដឹង ក៏ដូចជាបានស្វែងយល់បន្ថែមពីការបង្កើត ការប្រព្រឹត្តទៅ ការបង្កើត និងការបិទបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មជាដើម ។

ការសិក្សាស្រាវជ្រាវ ក៏ដូចជាការចងក្រងសារណាមួយនេះឡើយ យើងខ្ញុំក៏មិនអាចគេចផុតបាននៅកំហុសឆ្គងដោយអចេតនាក្តី ប៉ុន្តែយើងខ្ញុំបានព្យាយាមឲ្យមានកំហុសឆ្គងនេះនៅតិចបំផុត ហើយក៏មិនអាចគេចបាននៅតែមានចំណុចខ្វះខាត និងមិនទាន់គ្រប់ជ្រុងជ្រាយ នូវខ្លឹមសារ ពាក្យពេចន៍ និងកំហុសអក្ខរាវិរុទ្ធជាដើម ដែលក្នុងមានយើងខ្ញុំជានិស្សិតដែលបានចងក្រងប្រធានបទនេះឡើង នឹងរីករាយស្វាគមន៍រាល់មតិយោបល់ការរិះគន់ ក្នុងន័យស្ថាបនាកែលម្អដើម្បីបំពេញបន្ថែម រាល់ចំណុចខ្វះខាតពីសំណាក់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ សិស្សនិស្សិត** និង**បងប្អូនមិត្តអ្នកអានទាំងអស់** ដោយក្តីគោរព ។ បន្ថែមពីនេះផងដែរ យើងខ្ញុំសូមអធ្យាស្រ័យ និងអភ័យទោស ចំពោះកំហុសខុសឆ្គងដោយចេតនាដែលកើតមានក្នុងកិច្ចសារណា របស់យើងខ្ញុំ ។

ជាចុងបញ្ចប់យើងខ្ញុំសូមបួងសួងឲ្យវត្ថុសក្តិសិទ្ធិក្នុងលោកសូមឲ្យ **ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត** និង**បងប្អូនមិត្តអ្នកអានទាំងអស់** ឲ្យជួបប្រទះ តែសេចក្តីសុខ សេចក្តីចម្រើន រកទទួលទានមានបាន នឹងពុទ្ធពរទាំងឡាយបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

# មាតិកា

**ទំព័រ**


**សេចក្ដីផ្ដើម** ........ ១

១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

៣.គោលបំណងនៃការស្រាវជ្រាវ ........ ២

៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥.សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ៣

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១**

**សញ្ញាណទូទៅនៃក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា**

**ផ្នែកទី១.សញ្ញាណនៃក្រុមហ៊ុន** ........ ៥

**១.និយមន័យ** ........ ៥

**២.ផលប្រយោជន៍នៃក្រុមហ៊ុន** ........ ៥

២.១ ជម្រើសដៃគូពាណិជ្ជកម្ម ........ ៥

២.២ របបគតិយុត្តជាក្រុមហ៊ុន ........ ៦

២.៣ ហិរញ្ញវត្ថុនៃក្រុមហ៊ុន ........ ៦

**ផ្នែកទី២.ចំណាត់ថ្នាក់នៃក្រុមហ៊ុន** ........ ៦

**១.ក្រុមហ៊ុនគ្មាន និងមានបុគ្គលិកលក្ខណៈ** ........ ៦

១.១ ក្រុមហ៊ុនគ្មានបុគ្គលិកលក្ខណៈ ........ ៦

១.២ ក្រុមហ៊ុនមានបុគ្គលិកលក្ខណៈ ........ ៧

**២.ក្រុមហ៊ុនឯកបុគ្គល និងក្រុមហ៊ុនមូលធន** ........ ៧

២.១ ក្រុមហ៊ុនឯកបុគ្គល ........ ៧

២.២ ក្រុមហ៊ុនមូលធន ........ ៨

**៣.ក្រុមហ៊ុនឯកជន និងក្រុមហ៊ុនសាធារណៈ** ........ ៨

៣.១ ក្រុមហ៊ុនឯកជន ........ ៨

៣.២ សហគ្រាសសាធារណៈ ........ ៨
៣.២.១ ក្រុមហ៊ុនរដ្ឋ ........ ៩
៣.២.២ ក្រុមហ៊ុនចម្រុះ ........ ១០
៣.៣ ក្រុមហ៊ុនខ្មែរ និងក្រុមហ៊ុនបរទេស ........ ១១
៣.៣.១ ក្រុមហ៊ុនខ្មែរ ........ ១១
៣.៣.២ ក្រុមហ៊ុនបរទេស ........ ១១
៣.៣.២.១ ការិយាល័យតំណាងពាណិជ្ជកម្ម ........ ១២
៣.៣.២.២ សាខាក្រុមហ៊ុន ........ ១២
៣.៣.២.៣ បុត្រសម្ព័ន្ធ ........ ១៣
**ផ្នែកទី៣.លក្ខណៈទូទៅនៃក្រុមហ៊ុនពាណិជ្ជកម្ម** ........ ១៣
**១.លក្ខខណ្ឌគ្រឹះនៃការបង្កើតក្រុមហ៊ុន** ........ ១៣
១.១ កម្មវត្ថុស្របច្បាប់ ........ ១៣
១.២ ការព្រមព្រៀង ........ ១៤
១.៣ ទម្រង់នៃការបង្កើតក្រុមហ៊ុន ........ ១៤
១.៣.១ លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង ........ ១៤
១.៣.២ ការផ្សព្វផ្សាយស្របតាមច្បាប់ ........ ១៥
១.៣.៣ ពាក្យស្នើសុំ និងប្រតិវេទន៍អនុលោមភាព ........ ១៥
១.៤ ការចុះបញ្ជីពាណិជ្ជកម្ម និងទណ្ឌកម្ម ........ ១៥
**២.ការប្រព្រឹត្តទៅនៃក្រុមហ៊ុន** ........ ១៦
២.១ ការបង់ពន្ធ ........ ១៦
២.២ សិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុន ........ ១៧
២.៣ ការផ្ទេរ ការលក់ភាគទុន ........ ១៧
**៣.ការបញ្ចប់ក្រុមហ៊ុន** ........ ១៧
៣.១ ការចែងក្នុងកិច្ចសន្យា ........ ១៨
៣.២ ការព្រមព្រៀង ........ ១៨
៣.៣ ការរំលាយតាមផ្លូវច្បាប់ ........ ១៨

## ជំពូកទី២

## ទម្រង់នៃក្រុមហ៊ុនពាណិជ្ជកម្ម


**ផ្នែកទី១.សហគ្រាសឯកបុគ្គល និងឯកបុគ្គលទទួលខុសត្រូវមានកម្រិត** ........................១៩

**១.សហគ្រាសឯកបុគ្គល** ........................................................................................១៩

១.១ ស្ថានភាពគតិយុត្ត និងនិយមន័យ..............................................................................១៩

១.១.១ ស្ថានភាពគតិយុត្ត.....................................................................................................១៩

១.១.២ និយមន័យ ..................................................................................................................១៩

១.២ ការបង្កើត .......................................................................................................................២០

១.៣ ការចុះបញ្ជីសហគ្រាសឯកបុគ្គល ...................................................................................២១

១.៤ គុណសម្បត្តិ និងគុណវិបត្តិ.............................................................................................២២

១.៤.១ គុណសម្បត្តិ ..................................................................................................................២២

១.៤.២ គុណវិបត្តិ.......................................................................................................................២២

១.៥ ការបញ្ចប់ ..........................................................................................................................២៣

១.៥.១ ការបញ្ចប់ដោយស្ម័គ្រចិត្ត...............................................................................................២៣

១.៥.២ ការបញ្ចប់ដោយមិនស្ម័គ្រចិត្ត.........................................................................................២៣

**២.សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត** .....................................................២៤

២.១ និយមន័យ និងទម្រង់ ......................................................................................................២៤

២.១.១ និយមន័យ ........................................................................................................................២៤

២.១.២ ទម្រង់ ...............................................................................................................................២៤

២.២ ការបង្កើត និងការគ្រប់គ្រង...............................................................................................២៤

២.២.១ ការបង្កើត.........................................................................................................................២៤

២.២.២ ការគ្រប់គ្រង ....................................................................................................................២៥

២.៣ ការចុះបញ្ជីសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត.................................................២៦

២.៤ ការបញ្ចប់ ឬការរំលាយ .......................................................................................................២៧

**ផ្នែកទី២.ក្រុមហ៊ុនសហកម្មសិទ្ធិ**.....................................................................................២៨

**១.ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ**...........................................................................................២៨

១.១ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ...............................................................................២៨

១.១.១ ការបង្កើតដោយកិច្ចសន្យា ..... ២៨
១.១.២ ការបង្កើតដោយតុលាការ ..... ២៨
១.១.៣ នីតិបុគ្គលិកលក្ខណៈ សញ្ជាតិ និងនាមករណ៍ ..... ២៩
១.១.៣.១ នីតិបុគ្គលិកលក្ខណៈ ..... ២៩
១.១.៣.២ នាមករណ៍ ..... ២៩
១.១.៣.៣ សញ្ជាតិ ..... ៣០
១.១.៤ ការចុះបញ្ជី និងការតម្កល់ទុកឯកសារ ..... ៣០
១.២ ភាគទុន ..... ៣០
១.២.១ ភាគទុនជាប្រាក់ ..... ៣១
១.២.២ ភាគទុនជាវត្ថុ ..... ៣១
១.២.៣ ភាគទុនជាសេវា ..... ៣១
១.២.៤ ភាគទុនជាចំណេះដឹង ..... ៣២
១.៣ ការប្រព្រឹត្តទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិ ..... ៣២
១.៣.១ ទំនាក់ទំនងរវាងសហកម្មសិទ្ធិទូទៅ ..... ៣២
១.៣.២ ការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ..... ៣៣
១.៣.៣ ទំនាក់ទំនងក្រុមហ៊ុនសហកម្មសិទ្ធិ ជាមួយនឹងតតិយជន ..... ៣៣
១.៣.៤ ការអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ ..... ៣៣
១.៤.ការរំលាយ និងការជម្រះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ..... ៣៤
១.៤.១ ការបញ្ចប់ នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ..... ៣៤
១.៤.១.១ មូលហេតុដែលមានចែងនៅក្នុងកិច្ចសន្យា ..... ៣៤
១.៤.១.២ ការរំលាយក្រុមហ៊ុនដោយតុលាការ ..... ៣៤
១.៤.២ សិទ្ធិរបស់កម្មសិទ្ធិករនៅពេលរំលាយ ..... ៣៥
១.៤.៣ សិទ្ធិរបស់តតិយជនពេលរំលាយ ..... ៣៥
១.៤.៤ នីតិវិធីនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ..... ៣៥
**២.ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត** ..... ៣៥
២.១ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ..... ៣៥
២.១.១ និយមន័យ និងលក្ខណៈនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ..... ៣៦

២.១.១.១ និយមន័យ ..................................................................... ៣៦
២.១.១.២ លក្ខណៈនៃសមាជិក ..................................................................... ៣៦
២.១.២ ការបង្កើត ..................................................................... ៣៦
២.១.៣ នាមករណ៍ ..................................................................... ៣៧
២.១.៤ ការបង់ភាគហ៊ុន ..................................................................... ៣៧
២.២ ការប្រព្រឹត្តិទៅ នៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ..................................................................... ៣៨
២.២.១ សិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករទូទៅ ..................................................................... ៣៨
២.២.២ សិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករមានកម្រិត ..................................................................... ៣៨
២.៣ ការរំលាយ ឬការបញ្ចប់នៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ..................................................................... ៣៩
**ផ្នែកទី៣.ក្រុមហ៊ុនមូលធន** ..................................................................... ៤០
**១.ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត** ..................................................................... ៤០
១.១ ការបង្កើត ..................................................................... ៤០
១.១.១ សមត្ថភាព និងដើមទុន ..................................................................... ៤១
១.១.១.១ សមត្ថភាព ..................................................................... ៤១
១.១.១.២ ភាគទុន ឬដើមទុន ..................................................................... ៤១
១.១.២ កម្មវត្ថុ និងលក្ខន្តិកៈនៃអាជីវកម្ម ..................................................................... ៤២
១.១.២.១ កម្មវត្ថុនៃអាជីវកម្ម ..................................................................... ៤២
១.១.២.២ លក្ខន្តិកៈនៃអាជីវកម្ម ..................................................................... ៤២
១.១.៣ នាមករណ៍ និងសញ្ជាតិ ..................................................................... ៤៣
១.១.៣.១ នាមករណ៍ ..................................................................... ៤៣
១.១.៣.២ សញ្ជាតិ ..................................................................... ៤៤
១.១.៤ ថេរវេលា និងការបង់វិភាគទុន ..................................................................... ៤៤
១.១.៤.១ ថេរវេលា ..................................................................... ៤៤
១.១.៤.២ ការបង់ភាគទុន ..................................................................... ៤៤
១.២ ការប្រព្រឹត្តទៅនៃអភិបាល ..................................................................... ៤៥
១.២.១ អភិបាល និងគុណភាពអភិបាល ..................................................................... ៤៥
១.២.២ សិទ្ធិអំណាចរបស់អភិបាល ..................................................................... ៤៦

១.២.៣ ការបញ្ចប់តួនាទីរបស់អភិបាល ....................................................................................៤៧
១.៣ ការបញ្ចប់ក្រុមហ៊ុន.......................................................................................................៤៧
**២.ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**.....................................................................៤៨
២.១ ការបង្កើត ....................................................................................................................៤៨
២.១.១ ការបង្កើត និងការចុះបញ្ជីនៃក្រុមហ៊ុន ...........................................................................៤៩
២.១.១.១ ការបង្កើត.........................................................................................................៤៩
២.១.១.២ ការចុះបញ្ជីនៃក្រុមហ៊ុន.......................................................................................៤៩
២.១.២ នាមករណ៍ និងលក្ខន្តិកៈក្រុមហ៊ុន ...............................................................................៥០
២.១.២.១ នាមករណ៍ .........................................................................................................៥០
២.១.២.២ លក្ខន្តិកៈក្រុមហ៊ុន ..............................................................................................៥១
២.១.៣ សមត្ថភាព និងសិទ្ធិរបស់ក្រុមហ៊ុន ...............................................................................៥១
២.២ ការប្រព្រឹត្តទៅនៃក្រុមហ៊ុន ...............................................................................................៥២
២.២.១ ការគ្រប់គ្រងក្រុមហ៊ុន ...............................................................................................៥២
២.២.២ ទីស្នាក់ការចុះបញ្ជី សៀវភៅបញ្ជី និងកំណត់ហេតុ ..........................................................៥៣
២.២.២.១ ទីស្នាក់ការចុះបញ្ជី ..............................................................................................៥៣
២.២.២.២ សៀវភៅបញ្ជី និងកំណត់ហេតុ ...............................................................................៥៤
២.២.៣ ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ...................................................................................៥៤
២.៣ ការបញ្ចប់ក្រុមហ៊ុន .........................................................................................................៥៦
២.៣.១ ការបញ្ចប់អត្ថិភាព ...................................................................................................៥៧
២.៣.២ ការជម្រះបញ្ជី និងបំណុល ..........................................................................................៥៧

## ជំពូកទី៣

## គុណសម្បត្តិ គុណវិបត្តិ បញ្ហាប្រឈម និងដំណោះស្រាយ នៅក្នុងនីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា

**ផ្នែកទី១.គុណសម្បត្តិនៃការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា**.....................៥៩
១. ការវិនិយោគទុន ...........................................................................................................៥៩
២. ការចូលរួមជាមួយអាស៊ាន ...............................................................................................៥៩
៣. ការរីកចម្រើននៃទីផ្សារពាណិជ្ជកម្ម .....................................................................................៦០

**ផ្នែកទី២.គុណវិបត្តិនៃការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា**......................៦០
១. ប្រភពដើមទុន ....................................................................................................៦០
១.១ ធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ..................................................................................៦១
១.២ វិនិយោគបរទេស...................................................................................................៦១
១.៣ ដើមទុនផ្ទាល់ខ្លួន ...................................................................................................៦២
២. ការទាមទារផ្នែកច្បាប់...............................................................................................៦២
៣. ការប្រកួតប្រជែង ការបង់ពន្ធ និងហានិភ័យ ....................................................................៦៣
**ផ្នែកទី៣.បញ្ហាប្រឈមនៃការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា**..................៦៤
១. បញ្ហាប្រឈមក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធទូទៅ និងមានកម្រិត.....................................៦៤
២ បញ្ហាប្រឈមនៃការខ្វះខាតលិខិតបទដ្ឋានគតិយុត្តិ.................................................................៦៥
៣. បញ្ហាប្រឈមនៃកង្វះធនធានមនុស្ស និងថវិកា .....................................................................៦៦
៤. បញ្ហាប្រឈមនៃសេដ្ឋកិច្ច ............................................................................................៦៧
**ផ្នែកទី៤.ដំណោះស្រាយនៃការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា** ................៦៧
១.លិខិតបទដ្ឋានគតិយុត្ត....................................................................................................៦៧
២. ធនធានមនុស្ស និងថវិកា..............................................................................................៦៨
៣. សេដ្ឋកិច្ច.....................................................................................................................៦៩
**សេចក្តីសន្និដ្ឋាន**...........................................................................................................៧១
**អនុសាសន៍**....................................................................................................................៧៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ពាណិជ្ជកម្មនៅកម្ពុជា បាននឹងកំពុងដើរតួយ៉ាងសំខាន់នៅក្នុងការទាក់ទាញវិនិយោគទុនទាំងក្នុងនិងក្រៅប្រទេស ។ កម្ពុជាបាននឹងកំពុងរីកចម្រើនយ៉ាងឆាប់រហ័សដោយមានការពឹងផ្អែកលើវិស័យពាណិជ្ជកម្មនេះ ដែលយើងអាចសង្កេតឃើញថាមានការបង្កើតក្រុមហ៊ុនសហគ្រាសពាណិជ្ជកម្មជាច្រើន និងបន្តបន្ទាប់នៅកម្ពុជាក៏ដូចជាសាខារបស់ក្រុមហ៊ុនបរទេសទៀតផង ។ នៅក្នុងរយៈពេលចុងក្រោយនេះ សេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនកាន់ល្អពីមួយកម្រិតទៅមួយកម្រិត ផ្ទួបផ្សំនិងស្ថេរភាពនយោបាយ មានសុខសន្តិភាពថែមទៀតនោះបានធ្វើឲ្យវិនិយោគិនទាំងក្នុង និងក្រៅប្រទេស បានចាប់អារម្មណ៍ជាខ្លាំងមកលើប្រទេសកម្ពុជា នឹងមានមហិច្ឆតាចង់ដាក់ទុនវិនិយោគរបស់ខ្លួន មកបើកអាជីវកម្ម ក៏ដូចជាសាខាថ្មីបន្ថែមទៀតមកលើទឹកដីប្រទេសកម្ពុជា ។

ទន្ទឹមនឹងនោះផងដែរ ប្រទេសកម្ពុជា ក៏ជាប្រទេសមួយដែលមានសម្បត្តិធម្មជាតិជាច្រើនមហាសាលទាំងក្នុងដី និងលើដី ដែលបានធ្វើឲ្យវិនិយោគិនបរទេសសម្លឹងឃើញ និងមានចំណាប់អារម្មណ៍ក្នុងការវិនិយោគនៅលើធនធានទាំងអស់នោះ ។ ហេតុនេះហើយប្រសិនការវិវត្តនៃវិស័យពាណិជ្ជកម្មរបស់កម្ពុជាមិនមានភាពល្អប្រសើរ នឹងមិនអាចបំពេញតម្រូវការការវិនិយោគទុនក្នុងទំហំទឹកប្រាក់ជាច្រើន ឬមិនមានភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មនោះទេ គឺប្រាកដណាស់មិនអាចទាក់ទាញការវិនិយោគទុនទាំងនោះបានទេ ដូច្នេះហើយយើងខ្ញុំបានសម្រេចចិត្ត និងមានចំណាប់អារម្មណ៍ជាខ្លាំងនៅលើវិស័យពាណិជ្ជកម្មនេះ ព្រមជាមួយនឹងបានជ្រើសរើសយកប្រធានបទ “ **នីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា** ” នេះដោយយកចិត្តទុកដាក់បំផុត ដើម្បីយកមកស្រាវជ្រាវចងក្រងជាឯកសារសារណា ដែលជាជំនួយបន្ថែមអំពើដំណើរការ ការប្រព្រឹត្តទៅនៃក្រុមហ៊ុនពាណិជ្ជកម្មនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ។

បន្ថែមពីនេះទៀត យើងខ្ញុំក៏នឹងរំលេចឲ្យឃើញពីនីតិវិធីនានា នៅក្នុងការបង្កើតក្រុមហ៊ុននៅកម្ពុជាតាមបញ្ញត្តិច្បាប់ជាធរមាន ដែលជាចំណេះដឹងផ្នែកច្បាប់របស់អ្នកសិក្សាស្រាវជ្រាវច្បាប់ក៏ដូចជាសាធារណៈជនផ្សេងទៀតអាចស្វែងយល់បន្ថែមពីវិស័យពាណិជ្ជកម្មនេះឲ្យកាន់តែល្អប្រសើរ ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ “ **នីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា** ” នេះបានផ្តោតលើចំណុចសំខាន់ៗជាច្រើនដូចជា៖

១.តើនីតិវិធីនៃការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជាប្រព្រឹត្តទៅយ៉ាងដូចម្តេច ?

២.តើការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មពិតជាទទួលបានគុណសម្បត្តិច្រើនជាគុណវិបត្តពិតមែនឬទេ ?

៣.តើការមិនបានស្វែងយល់ពីច្បាប់ជាធរមាននៅកម្ពុជា ធ្វើឲ្យប៉ះពាល់ដល់ការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម

នៅកម្ពុជាដែរឬទេ ? មូលហេតុអ្វី ?

៤.តើនៅក្នុងការចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មជួបប្រទះផលវិបាក និងបញ្ហាប្រឈមអ្វីខ្លះ ?

៥.តើក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជាចាំបាច់ត្រូវជម្រះបញ្ជីទាំងអស់ដែរឬទេ ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរនាក់បានធ្វើការបែងចែក ក៏ដូចជាកំណត់អំពីនីតិវិធីក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា ដោយបានផ្អែកលើគោលការណ៍ និងបទបញ្ញត្តិច្បាប់ពាក់ព័ន្ធ និងពិសេសជាងនេះទៀតគឺបានសង្កត់ធ្ងន់លើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលត្រូវបានស្គាល់ថាជាមូលដ្ឋានគ្រឹះដ៏ចាំបាច់បំផុតនៅក្នុងច្បាប់ដែលបានបញ្ញត្តិអំពីប្រភេទក្រុមហ៊ុនលក្ខខណ្ឌនៃការបង្កើតក្រុមហ៊ុន និងការចាប់ផ្តើមអានុភាពស្របតាមបញ្ញត្តិច្បាប់ ។

ជាពិសេសដោយមើលឃើញនូវលទ្ធផល និងសមិទ្ធផលនានារបស់កម្ពុជានាពេលកន្លងមករួមផ្សំជាមួយនឹងការគាំទ្រក្នុងការអនុវត្តន៍លើទីផ្សារសេរីរបស់កម្ពុជាថែមទៀត ដែលបានបង្ហាញឡើងក្នុងរូបភាពជាការវិនិយោគទុនការប្រកបពាណិជ្ជកិច្ច និងការបណ្តាក់ទុនជាដើម បានដើរតួជាកាតាលីករជម្រុញសេដ្ឋកិច្ចទីផ្សាររបស់កម្ពុជាឲ្យមានការវិវត្តកាន់តែរីកច្រើន និងមានភាពកាន់តែល្អប្រសើរឡើងពីមួយកម្រិតទៅមួយកម្រិត ។ ហេតុនេះហើយបានជាប្រធានបទស្តីពី “ **នីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា** ” គឺជាជំនួយបន្ថែមសម្រាប់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាក្រុមហ៊ុន ឬគ្រឹះស្ថានទាំងអស់ ដែលមានបំណងដំណើរការអាជីវកម្ម ឬស្វែងយល់បន្ថែមពីនីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា ដែលប្រធានបទនេះនឹងជួយជាផ្តល់អត្ថប្រយោជន៍ជាច្រើនដូចជា៖

១.ការចូលរួមបន្ថែមក្នុងការជួយលើកម្ពស់វិស័យពាណិជ្ជកម្មនៅកម្ពុជា

២.ការទាក់ទាញវិនិយោគទុនពីបរទេស

៣.បង្ហាញអំពីការប្រមូលផ្តុំដើមទុនសម្រាប់ធ្វើអាជីវកម្ម

៤.ទទួលបានសមត្ថភាពក្នុងការជ្រើសរើសក្រុមហ៊ុនអាជីវកម្មដែលមានសមស្របក្នុងការធ្វើអាជីវកម្ម

៥.ការផ្សព្វផ្សាយជូនសាធារណៈជនឲ្យបានជ្រាបពីនីតិវិធីនៃក្រុមហ៊ុននៅកម្ពុជា

៦.ការទទួលបានចំណេះដឹងបន្ថែមលើផ្នែកពាណិជ្ជកម្ម ......។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវលើប្រធានបទនេះ គឺមានការស្រាវជ្រាវដោយបានផ្តោតលើចំណុចសំខាន់ៗចំនួន០៣គឺ៖ នីតិវិធីការបង្កើតក្រុមហ៊ុននៅកម្ពុជា ការចុះបញ្ជីក្រុមហ៊ុននៅកម្ពុជា ការរំលាយក្រុមហ៊ុន ការជម្រះបញ្ជីក្រុមហ៊ុន និងគុណសម្បត្តិ គុណវិបត្ត បញ្ហាប្រឈម ព្រមទាំងដំណោះស្រាយ ដែលនឹងត្រូវបានយកមកបកស្រាយនៅក្នុងសារណានេះ ។ នៅក្នុងចំណុចនីតិវិធីនៃការបង្កើតក្រុមហ៊ុន គឺត្រូវបានស្រាវជ្រាវដោយលម្អិត និងស៊ីជម្រៅ រួមផ្សំ

ជាមួយការអនុវត្តន៍ជាក់ស្តែង ចំណែកការចុះបញ្ជីក្រុមហ៊ុននៅកម្ពុជា ការរំលាយក្រុមហ៊ុន ការជម្រះបញ្ជីក្រុមហ៊ុន និងគុណសម្បត្តិ គុណវិបត្តិ បញ្ហាប្រឈម ព្រមទាំងដំណោះស្រាយ គឺស្រាវជ្រាវបន្ថែមពីលើតែប៉ុណ្ណោះ មិនបានស្រាវជ្រាវឲ្យស៊ីជម្រៅ និងល្អិតល្អន់ដូចនីតិវិធីនៃការបង្កើតក្រុមហ៊ុននោះទេ គឺគ្រាន់តែស្រាវជ្រាវដើម្បីទទួលបានចំណេះដឹង និងសញ្ញាណពាក់ព័ន្ធបន្ថែមពីប្រធានបទនេះតែប៉ុណ្ណោះ ។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះ ពិតជាមានសារសំខាន់ចំពោះវិស័យសេដ្ឋកិច្ច វិស័យពាណិជ្ជកម្ម វិស័យទំនាក់ទំនងអន្តរជាតិ និងវិស័យពាក់ព័ន្ធផ្សេងទៀត ដែលបានធ្វើឲ្យអ្នកសិក្សាអាចទទួលបានចំណេះដឹងបន្ថែម និងស៊ីជម្រៅ ចំពោះ អាជីវករ ពាណិជ្ជករ ទទួលបានការយល់ដឹងក្នុងការប្រកបមុខរបររបស់ខ្លួន ដែលធ្វើឲ្យមានការវិនិយោគទុនពីបរទេសបន្ថែមទៀតចូលមកកាន់ប្រទេសកម្ពុជា ទាក់ទងនឹងវិស័យពាណិជ្ជកម្មដោយបានមើលឃើញពីការអភិវឌ្ឍ និងរីកចម្រើនក៏ដូចជាការយល់ដឹងខាងពាណិជ្ជកម្មច្រើន និងមានភាពសម្បូរបែបនៅកម្ពុជា ។

ផ្អែកតាមការអអនុវត្តជាក់ស្តែង ដែលមានការលើកឡើងថា នីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជាមានភាពស្មុំញ៉ាំ ស្មុគស្មាញ ត្រូវចំណាយពេលវេលាច្រើន និងថវិកាច្រើន ដែលជាហេតុនាំឲ្យប្រធានបទនេះបានដើរតួយ៉ាងសំខាន់នៅក្នុងការដោះស្រាយបញ្ហាទាំងអស់នេះ ។

## ៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ដើម្បីសម្រេចនៅក្នុងការស្រាវជ្រាវលើប្រធានបទនេះ យើងបានសិក្សាស្វែងរក និងស្រាវជ្រាវលើឯកសារពាក់ព័ន្ធមួយចំនួនដែលមានលក្ខណៈជាទ្រឹស្តីគតិយុត្ត ភ្ជាប់ជាមួយការអនុវត្តន៍ជាក់ស្តែង ដែលភាគច្រើនមានទំនាក់ទំនងជាមួយប្រធានបទ និងទទួលបានចំណេះដឹងបន្ថែមជាមួយការអនុវត្តន៍ជាក់ស្តែង ដែលជាជំនួយបន្ថែមក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទទាំងមូល ។

ចំពោះប្រភពឯកសារដែលយើងបានសិក្សាស្រាវជ្រាវ គឺមានប្រភពមកពី រដ្ឋធម្មនុញ្ញ ច្បាប់សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ច្បាប់ក្រុមហ៊ុន សៀវភៅនីតិក្រុមហ៊ុន ព្រមទាំងឯកសារគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត ។ លើសពីនេះទៅទៀតក៏ទទួលបានការចង្អុលបង្ហាញពី និងផ្តល់ដំបូន្មានល្អៗពី លោកគ្រូណែនាំលើប្រធានបទនេះបន្ថែមទៀត ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទ “ **នីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា** ” នេះយើងខ្ញុំបានធ្វើការបកស្រាយ នូវខ្លឹមសារ និងការបែងចែកជា០៣(បី)ជំពូកធំៗ ដែលរួមមាន៖

- **ជំពូកទី១ សញ្ញាណទូទៅនៃក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា**
- **ជំពូកទី២ ទម្រង់នៃក្រុមហ៊ុនពាណិជ្ជកម្ម និង**

- **ជំពូកទី៣ គុណសម្បត្តិ គុណវិបត្តិ បញ្ហាប្រឈម និងដំណោះស្រាយនៅក្នុងនីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា**

# ជំពូកទី១
# សញ្ញាណទូទៅនៃក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា

# ជំពូកទី១
# សញ្ញាណទូទៅនៃក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា

## ផ្នែកទី១.សញ្ញាណនៃក្រុមហ៊ុន

### ១.និយមន័យ

ពាក្យថាក្រុមហ៊ុន ត្រូវបានគេកំណត់អត្ថន័យជាច្រើនយ៉ាងដូចខាងក្រោមៈ

**និយមន័យទី១** ក្រុមហ៊ុន គឺជាកិច្ចសន្យារវាង បុគ្គលពីរ ឬច្រើនក្នុងការព្រមព្រៀងគ្នា ដាក់ទ្រព្យធនមួយចំនួនរួមគ្នាដើម្បីសម្រេចសកម្មភាពសេដ្ឋកិច្ចអ្វីមួយ និងក្នុងបំណងទទួលកម្រៃមកចែកគ្នា។

**និយមន័យទី២** ក្រុមហ៊ុន គឺជានីតិបុគ្គលនៃនីតិឯកជនដែលមានបេតិកភណ្ឌផ្ទាល់ខ្លួន និងមានសមត្ថភាពគតិយុត្តប្រព្រឹត្តក្នុងនាមក្រុមហ៊ុន និងដើម្បីផលប្រយោជន៍សមូហភាព[1]។

ដោយយោងតាមនិយមន័យខាងលើ យើងអាចធ្វើសេចក្តីសន្និដ្ឋានជារួមបានថា **ក្រុមហ៊ុនពាណិជ្ជកម្ម** គឺជាកិច្ចសន្យារវាងបុគ្គលពីរ ឬច្រើននាក់ដែលបានព្រមព្រៀងគ្នាដាក់នូវទ្រព្យសម្បត្តិ សេវា ចំណេះដឹង ឬសកម្មភាពផ្សេងៗ ដើម្បីប្រកបនូវពាណិជ្ជកិច្ចក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ ។

ចំណែក **ពាណិជ្ជកិច្ច** គឺជាសកម្មភាពទិញលក់ទំនិញ ឬសេវាដែលត្រូវបានអនុវត្តជាប្រចាំ ក្នុងគោលបំណងធ្វើការដោះដូរ ស្វែងរកប្រាក់ចំណេញ[2] ។

### ២.ផលប្រយោជន៍នៃក្រុមហ៊ុន

នៅក្នុងសកម្មភាពពាណិជ្ជកម្មធំៗជាច្រើន គេតែងធ្វើសកម្មភាពក្រោមទម្រង់ជាក្រុមហ៊ុន ពីព្រោះអាជីវកម្មខាងក្រោមប្រភេទជាក្រុមហ៊ុនបានផ្តល់នូវផលប្រយោជន៍ជាច្រើនដូចជាៈ

- ទទួលបានជម្រើសដៃគូពាណិជ្ជកម្មច្រើន
- របបគតិយុត្តជាក្រុមហ៊ុនមានភាពរឹងមាំជាងរូបវន្តបុគ្គល
- ហិរញ្ញវត្ថុនៃក្រុមហ៊ុនមានភាពច្បាស់លាស់

### ២.១ ជម្រើសដៃគូពាណិជ្ជកម្ម

ការរៀបចំក្រុមហ៊ុនជាបច្ចេកទេសមួយត្រូវបន្ថែម ដែលច្បាប់ផ្តល់សិទ្ធិឲ្យម្ចាស់ក្រុមហ៊ុនរៀបចំជាជម្រើសដៃគូសមាជិកភាគហ៊ុន និងប្រភេទក្រុមហ៊ុនដែលគេចង់បាន ។

ឧទាហរណ៍ៈ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រុមហ៊ុនមូលធន ក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ជាដើម ។

[1] សៀវភៅនីតិសហគ្រាសពាណិជ្ជកម្ម រៀបរៀងដោយសាស្ត្រាចារ្យ ខាត់ ធី ទំព័រទី១

[2] មាត្រា២ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

### ២.២ របបគតិយុត្តជាក្រុមហ៊ុន

ក្រោយពីទទួលបានបុគ្គលិកលក្ខណៈជានីតិបុគ្គលតាមនិម្មិតរបស់ច្បាប់ នោះនិងនាំឲ្យក្រុមហ៊ុនមានសិទ្ធិ និងបេតិកភណ្ឌផ្ទាល់ខ្លួនដូចរូបវន្តបុគ្គលដែរ ។ ដូច្នេះទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនចែកដាច់ពីគ្នារវាងទ្រព្យសម្បត្តិផ្ទាល់របស់ពាណិជ្ជករ និងទ្រព្យសម្បត្តិរបស់នីតិបុគ្គល ។

ជាគោលការណ៍ សិទ្ធិអត្ថិភាពនៃនីតិបុគ្គលភាព របស់ក្រុមហ៊ុនក្លាយជាឧបករណ៍យ៉ាងមានប្រសិទ្ធភាពក្នុងការរារាំង ការរឹបអូសទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ម្ចាស់ភាគហ៊ុន ។

ក្រុមហ៊ុននីតិបុគ្គលដែលមានសិទ្ធិ កាតព្វកិច្ច និងមានបេតិកភណ្ឌដោយឡែកធ្វើឲ្យពាណិជ្ជករជៀសផុតពីហានិភ័យជាច្រើន ក្នុងការខាតបង់ធនធានផ្ទាល់ខ្លួនជាយថាហេតុ ។

### ២.៣ ហិរញ្ញវត្ថុនៃក្រុមហ៊ុន

នៅក្នុងក្រុមហ៊ុន ផ្នែកហិរញ្ញវត្ថុនេះមួយ ពិតជាសំខាន់និងមិនអាចខ្វះបាន ដែលម្ចាស់អាជីវកម្ម ឬសហគ្រាសត្រូវយកចិត្តទុកដាក់ និងមានការរៀបចំឲ្យបានល្អបំផុតនៅក្នុងដំណើរការរបស់ក្រុមហ៊ុន ។ ការកំណត់ពីចំណាយ ចំណូល ត្រូវបានកត់ត្រាយ៉ាងច្បាស់លាស់ និងល្អិតល្អន់ជាទីបំផុត នៅក្នុងនោះផងដែរទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនក៏ត្រូវបានកត់បញ្ចូល នៅក្នុងបញ្ជី ដែលទ្រព្យសម្បត្តិនោះជាការប្រមូលផ្តុំដើមទុនរបស់សមាជិកក្រុមហ៊ុន ។

អាជីវកម្មក្នុងទម្រង់ជាក្រុមហ៊ុនបានផ្តល់ជំនឿទុកចិត្តដល់ដៃគូពាណិជ្ជកម្ម ហើយវាបានផ្តល់នូវផលវិជ្ជមានដល់ការទទួលបានប្រាក់កម្ចី ពីព្រោះក្រុមហ៊ុនមានទ្រព្យសម្បត្តិផ្ទាល់ខ្លួនសម្រាប់ដាក់ធានាបំណុល ។ ការរួមបញ្ចូលគ្នាជាក្រុមដើម្បីប្រកបអាជីវកម្មផ្តល់ប្រយោជន៍សំខាន់ដល់ការប្រមូលប្រភពធនធានផ្នែកហិរញ្ញវត្ថុ ។

ដូច្នេះប្រភពធនធានទាំងនោះកើតចេញពីការប្រមូលផ្តុំភាគហ៊ុន ឬទ្រព្យសម្បត្តិ នៅក្នុងការបង្កើតបានជាក្រុមហ៊ុន[3] ឬអាចប្រមូលធនធានបានតាមរយៈការលក់ភាគហ៊ុនតាមទីផ្សារមូលបត្រជាដើម ។

## ផ្នែកទី២.ចំណាត់ថ្នាក់នៃក្រុមហ៊ុន

### ១.ក្រុមហ៊ុនគ្មាន និងមានបុគ្គលិកលក្ខណៈ

### ១.១ ក្រុមហ៊ុនគ្មានបុគ្គលិកលក្ខណៈ

ក្រុមហ៊ុនគ្មានបុគ្គលិកលក្ខណៈ គឺជាក្រុមហ៊ុនដែលមានទម្រង់ជាសមាគមន៍ ។ ការបង្កើតក្រុមហ៊ុននេះច្បាប់មិនទាន់ទទួលស្គាល់នោះទេ ហើយក៏ពុំមានធ្វើការផ្សព្វផ្សាយនោះដែរ ។

សក្ខីភាពបញ្ជាក់ពីកំណើតក្រុមហ៊ុននេះអាចធ្វើបានដោយសៀវភៅបញ្ជី និងព្រមទាំងសាក្សី ។ ក្រុមហ៊ុន

[3] មាត្រា១៤ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

ប្រភេទនេះគ្មានបុគ្គលិកលក្ខណៈ ដូច្នេះក្រុមហ៊ុននេះគ្មានឈ្មោះ គ្មានទីស្នាក់ការជាក់លាក់នោះទេ ។ សមាជិកគ្មានចំនួនពិតប្រាកដ ហើយអាចចុះកិច្ចសន្យាជាមួយតតិយជនណាក៏បាន ។

សាធារណៈជនទទួលស្គាល់សមាជិកចុះកិច្ចសន្យា ហើយប្រសិនបើមានការខាតបង់ សមាជិកនៃកិច្ចសន្យាមានសិទ្ធិទាមទារនូវភាគណាមួយនៃសមាជិកដទៃទៀតបាន ។

តាមក្រមពាណិជ្ជកម្មសង្គមចាស់ បានបញ្ញត្តិទទួលស្គាល់ពីអត្ថិភាពក្រុមហ៊ុនដែលមិនបានចុះបញ្ជីពាណិជ្ជកម្មហើយគ្មានបុគ្គលិកលក្ខណៈ ។ ផ្ទុយទៅវិញច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មក៏ដូចជាច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មមិនផ្តល់ការអនុញ្ញាតការធ្វើអាជីវកម្មក្នុងទម្រង់ជាក្រុមហ៊ុនដោយមិនបានចុះបញ្ជីនោះទេ ។ រាល់ការធ្វើអាជីវកម្មណាមួយដោយមិនចុះបញ្ជីគឺជា **អាជីវកម្មខុសច្បាប់** ។

### ១.២ ក្រុមហ៊ុនមានបុគ្គលិកលក្ខណៈ

ក្រុមហ៊ុនដែលមានបុគ្គលិកលក្ខណៈ គឺជាក្រុមហ៊ុនបង្កើតឡើងដោយបំពេញបែបបទ និងធ្វើការចុះបញ្ជីត្រឹមត្រូវតាមច្បាប់កំណត់ ។

យោងតាមច្បាប់ស្តីពីសហគ្រាស់ពាណិជ្ជកម្ម កំណត់ពីទម្រង់ផ្សេងៗរបស់ក្រុមហ៊ុនមានដូចជា ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធនដែលធ្វើសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ។

- ក្រុមហ៊ុនសហកម្មសិទ្ធិមានក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។
- ក្រុមហ៊ុនមូលធនមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ។

## ២.ក្រុមហ៊ុនឯកបុគ្គល និងក្រុមហ៊ុនមូលធន

### ២.១ ក្រុមហ៊ុនឯកបុគ្គល

ក្រុមហ៊ុនឯកបុគ្គល គឺជាក្រុមហ៊ុនដែលបង្កើតឡើងរវាងសមាជិកស្គាល់គ្នាឬបងប្អូនដែលទុកចិត្តគ្នាប៉ុណ្ណោះ សមាជិកក្រុមហ៊ុនមានលក្ខណៈ ជាឈ្មួញ(ពាណិជ្ជករ) ។ សមាជិកក្រុមហ៊ុនបុគ្គលអាចលក់ភាគហ៊ុនឲ្យទៅអ្នកក្រៅបាន លុះត្រាតែមានការព្រមព្រៀងពីសមាជិកទាំងអស់ ។

ប្រសិនបើក្រុមហ៊ុនធ្វើប្រតិបត្តិការខាត សមាជិកម្នាក់ៗត្រូវទទួលសងបំណុលក្រុមហ៊ុនដោយសាមគ្គីលើទ្រព្យរបស់ខ្លួនផ្ទាល់ ទោះបីភាគហ៊ុនរបស់ខ្លួនមានចំនួនកំណត់ក៏ដោយ ។ ច្បាប់ហាមក្រុមហ៊ុនបុគ្គលមិនឲ្យខ្ចីប្រាក់ពីសាធារណៈជនឡើយ ។

ក្រុមហ៊ុនបុគ្គលត្រូវគោរពតាមក្រមរដ្ឋប្បវេណី ។ ក្រុមហ៊ុនប្រភេទនេះមិនចាត់ចូលក្នុងរបបក្រុមហ៊ុននោះទេតែមុននឹងបង្កើតត្រូវតែមានការអនុញ្ញាតជាមុនពីរដ្ឋ ។

ការរំលាយក្រុមហ៊ុនបុគ្គលមានមូលហេតុ ៤យ៉ាងគឺ៖ សមាជិកម្នាក់ ឬច្រើននាក់សុំឲ្យរំលាយ មរណភាព

សមាជិកណាម្នាក់ កង្វះសមត្ថភាពសមាជិកណាម្នាក់ និងក្ស័យធនសមាជិកណាម្នាក់ ។

## ២.២ ក្រុមហ៊ុនមូលធន

ច្បាប់អនុញ្ញាតឲ្យបង្កើតក្រុមហ៊ុនមូលធន ដែលមានក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដើម្បីប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនមូលធនត្រូវបានបែងចែកចេញជា(០២)ពីរះ

១.ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២.ក្រុមហ៊ុនមហាជណទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុនមូនធន គឺជាក្រុមហ៊ុនមិនទទួលយកការមានទំនុកចិត្តលើសមាជិកជាសំខាន់នោះទេ តែគេទទួលយកដើមទុនជាចម្បង។ ក្រុមហ៊ុននេះកើតឡើងអាស្រ័យលើការប្រមូលដើមទុន មិនដូចក្រុមហ៊ុនបុគ្គលនោះទេ ។

ការទទួលខុសត្រូវចំពោះម្ចាស់បំណុល ម្ចាស់ហ៊ុនមិនទទួលសងបំណុលលើសពីភាគហ៊ុនដែលខ្លួនបានចូលក្រុមហ៊ុននោះទេ ។ ម្ចាស់ភាគហ៊ុនអាចលក់ ឬផ្ទេរភាគហ៊ុនទៅតតិយជនបាន ។ មរណភាពរបស់សមាជិកហ៊ុនមិនអាចធ្វើឲ្យរំលាយក្រុមហ៊ុននោះទេ ។ ក្រុមហ៊ុនត្រូវបន្តអាជីវកម្មជាមួយសមាជិកថ្មី ឬអ្នកទទួលភាគហ៊ុនថ្មី ឬអ្នកបន្តកេរ្តិ៍មរតកពីអ្នកស្លាប់ ។

តាមធម្មតាការបង្កើតក្រុមហ៊ុនមូលធនមិនចាំបាច់ សុំការអនុញ្ញាតពីរដ្ឋាភិបាលទេ ដោយហេតុថាច្បាប់បានកំណត់របៀបបង្កើត ។ ម្យ៉ាងទៀតច្បាប់អាចទុកជាមោឃៈនូវក្រុមហ៊ុនណាមិនគោរពរបៀបបង្កើត ដូចជាការភ្លេចមិនបានចុះផ្សាយ ឬមិនបានចុះផ្សាយដែរតែមិនបានបង្ហាញពីចំនួនដើមទុនជាដើម ។

# ៣.ក្រុមហ៊ុនឯកជន និងក្រុមហ៊ុនសាធារណៈ

## ៣.១ ក្រុមហ៊ុនឯកជន

ក្រុមហ៊ុនឯកជន (Private Companies )គឺជាក្រុមហ៊ុនដែលបង្កើតដោយដើមទុនរបស់បុគ្គលឯកជន ។ ភាគីឯកជនកាន់កាប់ភាគហ៊ុនភាគច្រើននៅក្នុងក្រុមហ៊ុន។

ក្រុមហ៊ុនឯកជនមានច្រើនទម្រង់ដូចជាៈ សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធនជាដើម ។

## ៣.២ ក្រុមហ៊ុនសាធារណៈ

ក្រុមហ៊ុនសាធារណៈ (Public Enterprises) គឺកើតឡើងពីប្រតិបត្តិការមួយផ្នែករបស់រដ្ឋ ក្នុងក្របខណ្ឌសេដ្ឋកិច្ចជាតិ ដើម្បីគោលដៅរក្សាស្ថេរភាពការអភិវឌ្ឍន៍ ។

នៅក្នុងទិដ្ឋភាពនៃរបបគតិយុត្តក្រុមហ៊ុនសាធារណៈ ប្រសិនបើក្រុមហ៊ុនសាធារណៈគ្រប់គ្រងអាជីវកម្មដូចឯកជន ក្រុមហ៊ុនសាធារណៈនោះត្រូវស្ថិតនៅក្រោមច្បាប់ពាណិជ្ជកម្ម ។ ប៉ុន្តែប្រសិនបើក្រុមហ៊ុនសាធារណៈ

នោះមានបេសកកម្មចម្បងបម្រើសេវាសាធារណៈដោយមិនគិតការចំណេញ ឬ ខាតសហគ្រាសនោះត្រូវស្ថិតនៅក្រោមនីតិរូប[4] ។

នៅកម្ពុជាក្រុមហ៊ុនសាធារណៈ ត្រូវបានបែងចែកជាពីរប្រភេទ គឺក្រុមហ៊ុនរដ្ឋ និង ក្រុមហ៊ុនចម្រុះ ។

**៣.២.១ ក្រុមហ៊ុនរដ្ឋ**

ក្រុមហ៊ុនរដ្ឋ គឺក្រុមហ៊ុនដែលមានដើមទុនទាំងអស់ជារបស់រដ្ឋ និងត្រូវបានបង្កើតឡើងដោយអនុក្រឹត្យក្រោមការស្នើសុំរួមគ្នារវាងរដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងអាណាព្យាបាល ឬអាជ្ញាធរមានសមត្ថកិច្ច ។

អនុក្រឹត្យដែលបង្កើតក្រុមហ៊ុនរដ្ឋនេះនឹងធ្វើការកំណត់នូវៈ

- កម្មវត្ថុរបស់ក្រុមហ៊ុន
- របបគតិយុត្តក្រុមហ៊ុន
- ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល
- របបត្រួតពិនិត្យដែលត្រូវអនុវត្ត សមាសភាពរបស់ក្រុមប្រឹក្សាភិបាល[5] ។

តាមទម្រង់នៃការបង្កើតក្រុមហ៊ុនរដ្ឋ ត្រូវប្រព្រឹត្តដោយអនុលោមទៅតាមវិធាននៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម

ក្រសួងអាណាព្យាបាល ឬអាជ្ញាធរបច្ចេកទេសត្រូវទទួលខុសត្រូវបំពេញទម្រង់បែបបទនៃការបង្កើតក្រុមហ៊ុនដោយៈ

- ការរៀបចំលក្ខន្តិកៈក្រុមហ៊ុនដោយមានការព្រមព្រៀងពីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ
- ការចាត់ចែងចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- ការបំពេញទម្រង់បែបបទទាំងអស់តាមគោលការណ៍ និងបែបបទទាំងឡាយតាមបញ្ញត្តិនៃនីតិក្រុមហ៊ុន

ការរៀបចំលក្ខន្តិកៈក្រុមហ៊ុនរដ្ឋត្រូវកំណត់ជាអាទិ៍ ចំនួនទឹកប្រាក់ ប្រភេទទុន ការរៀបចំរដ្ឋបាល និងហិរញ្ញ-វត្ថុ វិធាននៃការប្រព្រឹត្តទៅរបស់ក្រុមហ៊ុន ។

បដិបញ្ញត្តិលើគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្មអំណាចនៃមហាសន្និបាតរបស់ក្រុមហ៊ុនរដ្ឋត្រូវប្រគល់ឲ្យក្រុមប្រឹក្សាភិបាល ។ ភាគទុនដំបូងព្រមទាំងការកែប្រែជាក្រោយនៃដើមទុនរបស់រដ្ឋត្រូវបានធ្វើឲ្យសម្រេចដោយអនុលោមតាមបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ហិរញ្ញវត្ថុជាធរមាន ។

ប្រធានអគ្គនាយក ឬ អង្គនាយកក្រុមហ៊ុនរដ្ឋត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើររបស់ក្រសួង

[4] នីតិក្រុមហ៊ុន របស់លោកមេធាវី អ៊ីវ ប៉ូលី ឆ្នាំ២០០៨ ទំព័រទី១២

[5] មាត្រា៣១ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

អាណាព្យាបាល ឬអាជ្ញាធរមានសមត្ថកិច្ច ដោយសមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើររបស់ក្រសួង ឬអាជ្ញាធរអាណាព្យាបាលដែលសមាជិកជាតំណាង និងត្រូវជ្រើសរើសក្នុងលក្ខខណ្ឌដែលមានកំណត់តាមបញ្ញត្តិច្បាប់[6] ។

**៣.២.២ ក្រុមហ៊ុនចម្រុះ**

ក្រុមហ៊ុនចម្រុះ គឺជាក្រុមហ៊ុនត្រូវបានបង្កើតឡើងតាមគោលការណ៍ និងតាមបែបបទនៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ហើយដើមទុនត្រូវកាន់កាប់រួមគ្នាដោយនីតិបុគ្គល ឬបុគ្គលឯកជន និងនីតិបុគ្គលរដ្ឋ ។

ភាគកម្មសាធារណៈ គឺជាចំណែកដើមទុនភាគហ៊ុនចម្រុះដែលកាន់កាប់ដោយរដ្ឋ ដោយគ្រឹះស្ថានសាធារណៈ ឬដោយក្រុមហ៊ុនរដ្ឋ។ កាលណាភាគកម្មសាធារណៈលើសពី៥១% ដើមទុន ឬសិទ្ធិបោះឆ្នោតក្រុមហ៊ុនចម្រុះត្រូវចាត់ទុកជាគ្រឹះស្ថានសាធារណៈ[7]។ ភាគកម្មសាធារណៈត្រូវបានរ៉ាប់រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ក្រុមហ៊ុនចម្រុះ គឺត្រូវមានអាណត្តិគាហកៈពិសេសមួយរូបតំណាងឲ្យរដ្ឋនៅក្នុងមហាសន្និបាតរបស់ក្រុមហ៊ុនចម្រុះ ។ អាណត្តិគាហកៈពិសេសមានភារកិច្ចការពារផលប្រយោជន៍រដ្ឋនៅក្នុងមហាសន្និបាតវិសាមញ្ញ ហើយមានសិទ្ធិមានសិទ្ធិបោះឆ្នោតក្នុងនាមភាគីរដ្ឋ[8] ។

អាណត្តិគាហកៈពិសេស ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលកំពុងបម្រើការងារយ៉ាងតិច៥ឆ្នាំ ។ អាណត្តិគាហកៈពិសេសនេះត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អាណត្តិគាហកៈពិសេសត្រូវសុំមតិណែនាំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមុនចូលរួមមហាសន្និបាតក្រុមហ៊ុនចម្រុះ ។

សមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះដែលតំណាងឲ្យរដ្ឋ ឬតំណាងគ្រឹស្ថានសាធារណៈត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ តំណាងរបស់ក្រុមហ៊ុនរដ្ឋនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះត្រូវតែងតាំងដោយ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនរដ្ឋនោះក្រោយពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

តំណាងរបស់រដ្ឋរបស់គ្រឹះស្ថានសាធារណៈ ឬរបស់ក្រុមហ៊ុនរដ្ឋនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះត្រូវជ្រើសរើសដោយផ្អែកលើគុណសម្បត្តិ និងបទពិសោធន៍របស់ខ្លួន ឬពីក្នុងចំណោមមន្ត្រីរាជការ បម្រើការងារយ៉ាងតិច៥ឆ្នាំ ឬមន្ត្រីចូលនិវត្តន៍ ប៉ុន្តែអាយុមិនលើស៦៥ឆ្នាំ ឬក្នុងចំណោមឥស្សរជនខ្មែរដែលមានសមត្ថភាពខាងសេដ្ឋកិច្ច ខាងនីតិសាស្ត្រ ឬខាងវិទ្យាសាស្ត្រ[9] ។

---

[6] មាត្រា៤៣ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

[7] មាត្រា៣៨ កថាខណ្ឌទី២ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ

[8] មាត្រា៤៧ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ

[9] មាត្រា៤៣ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ

ការទទួលខុស ត្រូវផ្នែករដ្ឋប្បវេណីរបស់តំណាងរដ្ឋទាំងឡាយក្នុងការបំពេញភារកិច្ចរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះត្រូវធ្លាក់លើរដ្ឋ លើគ្រឹះស្ថានសាធារណៈ និងលើក្រុមហ៊ុនរដ្ឋ តែតំណាងត្រូវទទួលខុសត្រូវដោយខ្លួនឯងនូវផ្នែកព្រហ្មទណ្ឌ[10] ។

## ៣.៣ ក្រុមហ៊ុនខ្មែរ និងក្រុមហ៊ុនបរទេស

### ៣.៣.១ ក្រុមហ៊ុនខ្មែរ

ក្រុមហ៊ុនពាណិជ្ជកម្ម ដែលអាចទទួលបានសញ្ជាតិខ្មែរបានលុះត្រាតែក្រុមហ៊ុននោះមានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ហើយអត្ថប្រយោជន៍និងសិទ្ធិបោះឆ្នោតភាគច្រើនត្រូវបានកាន់កាប់ដោយរូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរផងដែរ ។ ចំណុចដែលបានរៀបរាប់បញ្ជាក់ខាងលើនេះ គឺគ្រប់គ្រាន់ដែលអាចកំណត់បានថាក្រុមហ៊ុននោះជា ក្រុមហ៊ុនពាណិជ្ជកម្មខ្មែរ ។

**ឧទាហរណ៍ទី១៖** ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទទួលបាននីតិបុគ្គលលក្ខណៈសញ្ជាតិខ្មែរលុះត្រាតែ៖[11]

១.ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតនៅព្រះរាជាណាចក្រកម្ពុជា

២.អត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុនចាប់ពី៥១%ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលមានសញ្ជាតិខ្មែរ

**ឧទាហរណ៍ទី២៖** ក្រុមហ៊ុនមូលធនត្រូវបានចាត់ទុកថាជាក្រុមហ៊ុនមានសញ្ជាតិខ្មែរលុះត្រាតែ៖[12]

១.ក្រុមហ៊ុនមានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើពាណិជ្ជកម្មស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា

២.ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី៥១% ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ ។

### ៣.៣.២ ក្រុមហ៊ុនបរទេស

ក្រុមហ៊ុនពាណិជ្ជកម្មបរទេ[13] គឺសំដៅលើក្រុមហ៊ុនទាំងឡាយណាដែលត្រូវបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ហើយបានបោះទីតាំងធ្វើពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ។ លើសពីនេះក្រុមហ៊ុនពាណិជ្ជកម្មបរទេសនេះអាចបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាបានតាមទម្រង់ដូចខាងក្រោម៖

ក.ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម

ខ.សាខាក្រុមហ៊ុនពាណិជ្ជកម្ម

គ.បុត្រសម្ព័ន្ធ ។

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស ដែលធ្វើពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងរូបភាពបែបណាក៏ដោយ

[10] មាត្រា៤៤ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ

[11] មាត្រា១៣ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[12] មាត្រា១០១ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[13] មាត្រា២៧០ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ក៏ត្រូវបំពេញបែបបទនៃការចុះបញ្ជីពាណិជ្ជកម្ម ស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ហើយត្រូវស្ថិតក្រោមច្បាប់ និងសមត្ថកិច្ចយុត្តាធិការរបស់ព្រះរាជាណាចក្រកម្ពុជា ។

ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុន គឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលលក្ខណៈដាច់ពីក្រុមហ៊ុនដើមឡើយ ។

### ៣.៣.២.១ ការិយាល័យតំណាងពាណិជ្ជកម្ម

ការិយាល័យតំណាង ( Representative Office ) គឺជាទម្រង់មួយនៃការវិនិយោគក្នុងប្រទេសកម្ពុជា ដោយក្រុមហ៊ុនមេបរទេស ហើយគោលដៅចំបង គឺក្នុងគោលបំណងជួយសម្រួលដល់ប្រភេទនៃទំនិញ និងសេវាក្នុងស្រុកព្រមទាំងប្រមូលព័ត៌មានឲ្យក្រុមហ៊ុនមេ ។ ការិយាល័យតំណាងមិនត្រូវធ្វើសកម្មភាព ដែលចាត់ទុកថាស្ថិតនៅក្នុងទំហំអាជីវកម្មរបស់ក្រុមហ៊ុនមេឡើយ ។

ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្មអាចធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានជាអាទិ៍៖

ក.ទំនាក់ទំនងផ្សេងៗជាមួយអតិថិជននានា ក្នុងគោលដៅធ្វើឲ្យអតិថិជនទាំងនោះបានស្គាល់ក្រុមហ៊ុនដើមរបស់ខ្លួន

ខ.ស្រាវជ្រាវព័ត៌មានពាណិជ្ជកម្ម និងផ្តល់ព័ត៌មានទាំងនេះជូនទៅក្រុមហ៊ុនដើមនៅបរទេស

គ.ស្រាវជ្រាវទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ឃ.ឃោសនាផលិតផល តាំងពិព័រណ៍ពាណិជ្ជកម្ម បង្ហាញផលិតផលនៅការិយាល័យរបស់ខ្លួន ឬនៅកន្លែងតាំងពិព័រណ៍ដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង.ទិញ និងរក្សាទុកទំនិញមួយចំនួន សម្រាប់គោលដៅបម្រើឲ្យការតាំងពិព័រណ៍ពាណិជ្ជកម្ម ។

ច.ជួលទីតាំងការិយាល័យ និងជួលបុគ្គលិកក្នុងស្រុក ដើម្បីបម្រើការងារ ។

ឆ.ចុះកិច្ចសន្យាពាណិជ្ជកម្មជាមួយអតិថិជនក្នុងស្រុកក្នុងនាមជាក្រុមហ៊ុនដើម ។

លើសពីនេះការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម មិនត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពទិញ លក់និងធ្វើសេវាជាអាជីពជាប្រចាំ ឬសកម្មភាពពាក់ព័ន្ធនឹងប្រត្តិបត្តិការផលិតកែច្នៃ និងសាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា បាននោះឡើយ ។

### ៣.៣.២.២ សាខាក្រុមហ៊ុន

សាខាក្រុមហ៊ុន ត្រូវបានគេសម្គាល់ថាអាចធ្វើសកម្មភាពបានដូចការិយាល័យតំណាងពាណិជ្ជកម្ម ។ លើសពីនេះទៀត សាខាក្រុមហ៊ុន គឺអាចទិញលក់ជាប្រចាំបាននូវទំនិញ និងសេវាកម្ម ព្រមទាំងសកម្មភាពដែលទាក់ទងទៅនឹងការផលិត ការកែច្នៃ និងការស្ថាបនាដូចសហគ្រាសពាណិជ្ជកម្មក្នុងស្រុកដែរ ។ ប៉ុន្តែលើកលែង

សកម្មភាពណាដែលត្រូវបានហាមឃាត់ចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលបរទេស ។[14]

តាមការបកស្រាយខាងលើសាខាក្រុមហ៊ុន គឺជាការិយាល័យតំណាងរបស់ក្រុមហ៊ុន ថាតើសាខាក្រុមហ៊ុននេះត្រូវមាននាមករណ៍ដូចក្រុមហ៊ុនដើមឬយ៉ាងណា ? តាមមាត្រា២៨១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ បានកំណត់ថា នាមករណ៍របស់សាខាក្រុមហ៊ុន គឺជានាមករណ៍របស់ក្រុមហ៊ុនដើម ប៉ុន្តែអ្វីដែលសំខាន់ជាគេងនោះគឺ នាមករណ៍នោះត្រូវសរសេរពាក្យ " **សាខាក្រុមហ៊ុន** "សាខាក្រុមហ៊ុន នៅខាងលើ ឬពីមុខនាមករណ៍នោះ ។ បន្ថែមពីនេះ សាខាក្រុមហ៊ុន ត្រូវបានបញ្ចប់ ឬរំលាយបានដោយសេចក្តីសម្រេចរបស់ក្រុមហ៊ុនដើម[15] ។

### ៣.៣.២.៣ បុត្រសម្ព័ន្ធ

បុត្រសម្ព័ន្ធ (Subsidiary) ក្រុមហ៊ុនពាណិជ្ជកម្មបរទេស គឺជាក្រុមហ៊ុនដែលបង្កើតឡើងដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលមានភាគហ៊ុនយ៉ាងតិច៥១(ហាសិបមួយ)ភាគរយត្រូវបានកាន់កាប់ដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ ។ បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនបរទេស ដែលត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេស នឹងបានធ្វើសកម្មភាពពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ប៉ុន្តែបុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មនេះ គឺមាននីតិបុគ្គលគតិយុត្តិដាច់ដោយឡែកពីក្រុមហ៊ុនដើម ចាប់ពីពេលចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់ពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។ លើសពីនេះ បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេសអាចត្រូវបានបង្កើតឡើងក្នុងទម្រង់ជាក្រុមហ៊ុនសហកម្មសិទ្ធិ ឬជាក្រុមហ៊ុនមូលធន[16] ។

## ផ្នែកទី៣ លក្ខណៈទូទៅនៃក្រុមហ៊ុនពាណិជ្ជកម្ម

## ១.លក្ខខណ្ឌសុពលភាពនៃការបង្កើតក្រុមហ៊ុន

### ១.១ កម្មវត្ថុស្របច្បាប់

ក្រុមហ៊ុនត្រូវមានកម្មវត្ថុប្រកបពាណិជ្ជកម្មដោយស្របច្បាប់និងមិនត្រូវផ្ទុយនឹងសណ្តាប់ធ្នាប់សាធាណៈ ឬទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់យើងនោះទេ ។

**ឧទាហរណ៍៖** ថ្មីនេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសលុបចោលនូវឡូតិ៍នៃសាទទូរទាំងប្រទេស ដូច្នេះយើងមិនអាចបង្កើតក្រុមហ៊ុនដែលមានគោលដៅប្រកបពាណិជ្ជកិច្ចក្នុងទម្រង់បែបនេះបានឡើយ ។ ឧទាហរណ៍ដូចគ្នាផងដែរ គឺគេមិនអាចបង្កើតក្រុមហ៊ុនរកស៊ីជួញដូរមនុស្ស ឬជួញដូរគ្រឿងញៀន ឬការជួញដូរអាវុធណាមួយបានឡើយ ។

[14] មាត្រា២៧៨ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[15] មាត្រា២៨២ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[16] មាត្រា២៨៣-២៨៦ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ម្យ៉ាងវិញទៀត ក្រុមហ៊ុនដែលមានគោលដៅប្រកបពាណិជ្ជកម្មដោយខុសច្បាប់ក៏មិនទទួលបានការចុះបញ្ជីដោយក្រសួងពាណិជ្ជកម្មនោះទេ ។

## ១.២ ការព្រមព្រៀង

ការព្រមព្រៀង គឺជាការបង្ហាញនៅអ្វីមួយដែលគ្មាននូវវិការៈ ។ ការព្រមព្រៀងដែលត្រូវបានចាត់ទុកថាមានវិការៈ គឺជាការព្រមព្រៀងទាំងឡាយណាដែលកើតឡើងដោយសារការបង្ហាញឆន្ទៈកើតឡើងដោយសារមានការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត អំពីការឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ ។ល។

## ១.៣. ទម្រង់នៃការបង្កើតក្រុមហ៊ុន

ក្រៅពីលក្ខខណ្ឌគ្រឹះក្នុងការបង្កើតកិច្ចសន្យា កិច្ចសន្យាក្រុមហ៊ុនក៏ទាមទារលក្ខខណ្ឌជាទម្រង់មួយចំនួនផ្សេងទៀតដូចខាងក្រោម៖

### ១.៣.១ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង

សហគ្រាសមួយចំនួនមិនចាំបាច់ទាមទារនូវលក្ខន្តិកៈទេ ដូចជាសហគ្រាសឯកបុគ្គល ប៉ុន្តែក្រុមហ៊ុន ឬ សហគ្រាសប្រទេសណាក៏ដោយនៅពេលដែលដាក់ពាក្យស្នើសុំចុះបញ្ជីពាណិជ្ជកម្មនោះ មន្ត្រីគ្រប់គ្រងបញ្ជីក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មតែងតែស្នើសុំឲ្យមានជាបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឬ សហគ្រាស ដើម្បីបំពេញបែបបទក្នុងការចុះបញ្ជី ។

ប៉ុន្តែក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ ដែលមានសហកម្មសិទ្ធិទូទៅ និងសហកម្មសិទ្ធិមានកម្រិតពាក្យថាលក្ខន្តិកៈមិនត្រូវបានប្រើប្រាស់ឡើយ ។ ក្រុមហ៊ុនសហកម្មសិទ្ធិទោះជាទូទៅក្តី ឬមានកម្រិតក្តីត្រូវបានបង្កើតឡើងដោយកិច្ចសន្យារវាងបុគ្គលពីរ ឬច្រើនដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬសកម្មភាពផ្សេងៗ ។

ដូច្នេះ កិច្ចសន្យាជាមួយបុគ្គលដែលជាម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនសហកម្មសិទ្ធិនេះនឹងកំណត់អំពីសិទ្ធិនិងកាតព្វកិច្ច និងការទទួលខុសត្រូវផ្សេងៗរបស់សមាជិកក្រុមហ៊ុននោះ ។

ចំណែកឯការបង្កើតក្រុមហ៊ុនមូលធន ដែលមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតវិញ ទាមទារការរំលេចនូវពាក្យពេចន៍ដែលថា ក្រុមហ៊ុនមូលធនអាចត្រូវបង្កើតឡើងដោយនីតិបុគ្គល ឬរូបវន្តបុគ្គលមួយ ឬច្រើនដែលមានកាយសម្បទា និងមានសមត្ថភាពគ្រប់គ្រាន់ដោយធ្វើការបំពេញលក្ខន្តិកៈជូនឲ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

លក្ខន្តិកៈនោះនឹងមានរៀបរាប់ទាំងអស់អំពី នាមករណ៍របស់ក្រុមហ៊ុន ទីស្នាក់ការ កម្មវត្ថុ អាជីវកម្មដើមទុនការបោះចេញមូលបត្រ ឬការផ្ទេរភាគហ៊ុន និងចំនួននៃអភិបាល ។ល។

### ១.៣.២ ការផ្សព្វផ្សាយស្របតាមច្បាប់

ការចុះឈ្មោះក្នុងបញ្ជី ឬការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម គឺត្រូវបានចុះផ្សាយដោយមន្ត្រីចុះពាណិជ្ជកម្មនៅក្នុងរាជកិច្ច និងចុះផ្សាយនៅក្នុងព្រឹត្តិបត្ររបស់ក្រសួងពាណិជ្ជកម្ម ។ ចំពោះក្រុមហ៊ុនត្រូវបានចុះនិទ្ទេសមួយចំនួនដូចជា លេខចុះបញ្ជី នាមករណ៍ ចំនួនដើមទុន ទីស្នាក់ការ សកម្មភាព ថ្ងៃទីឆ្នាំចាប់ផ្តើមទ្រង់ទ្រាយក្រុមហ៊ុន[17] ។

### ១.៣.៣ ពាក្យស្នើសុំ និងប្រតិវេទន៍អនុលោមភាព

អ្នកស្នើសុំចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មនៃក្រុមហ៊ុន ឬសាខាក្រុមហ៊ុន ឬការិយាល័យតំណាងក្រុមហ៊ុនបរទេសក៏ដោយត្រូវចុះបញ្ជីពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ហើយទម្រង់នៃពាក្យស្នើសុំ គឺវាអាស្រ័យទៅតាមប្រភេទនៃក្រុមហ៊ុននោះ ។ **ឧទាហរណ៍៖** ពាក្យស្នើសុំចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនត្រូវប្រើគំរូ (ក) រីឯសហគ្រាសឯកបុគ្គលត្រូវប្រើគំរូ (ឃ) និងសាខាឬការិយាល័យតំណាងក្រុមហ៊ុនបរទេស ។ល។

អ្នកស្នើសុំចុះឈ្មោះត្រូវផ្តល់ដល់ទីកន្លែងទទួលពាក្យចុះបញ្ជីនូវប្រតិវេទន៍ចំនួន២ច្បាប់ដែលមានចុះហត្ថលេខារបស់សាមីខ្លួនអ្នកស្នើសុំព្រមទាំងតម្កល់លក្ខន្តិកៈក្រុមហ៊ុន ។

ប្រតិវេទន៍ ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មផ្តល់គំរូនោះត្រូវចែងអំពី នាមត្រកូល ផ្លាកសញ្ញារបស់ក្រុមហ៊ុន ដើមទុនក្រុមហ៊ុន ទ្រង់ទ្រាយក្រុមហ៊ុន លិខិតបញ្ជាក់អំពីការតម្កល់ដើមទុនចេញដោយធនាគារ ការប្រកាសថាគ្មានទោសពៃរ៍ក្នុងរឿងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌដោយអ្នកស្នើសុំ ។ល។

## ១.៤ ការចុះបញ្ជីពាណិជ្ជកម្ម និងពាណិជ្ជកម្ម

គ្រប់ក្រុមហ៊ុនដែលធ្វើសកម្មភាពពាណិជ្ជកម្មនៅក្នុងកម្ពុជាត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្មនោះ ទោះបីបែបបទនៃការបង្កើត ឬចិរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ ។

ការចុះឈ្មោះក្នុងបញ្ជីនេះ ត្រូវធ្វើឡើងដោយបណ្ណាធិការ ឬអភិបាលនៃក្រុមហ៊ុននៅក្នុងខែនៃការបង្កើតក្រុមហ៊ុន និង១៥ថ្ងៃមុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម ។

រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនទាំងឡាយណាដែលមិនបានសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមការបញ្ញត្តិ នឹងត្រូវបានចោទតាមផ្លូវតុលាការអំពីបទប្រកបសកម្មភាពពាណិជ្ជកម្មមិនស្របច្បាប់ ហើយនឹងត្រូវបានផ្តន្ទាទោសជាប្រាក់ពី ៥០០០០រៀល ទៅ៥០០ ០០០រៀល[18] ។

ផ្ទុយទៅវិញ រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណាដែរបានផ្តល់ព័ត៌មាន

[17] មាត្រា៣៨ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

[18] មាត្រា៣៩ និង៤០ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

មិនពិតដោយគំនិតអាក្រក់ ដើម្បីនឹងសុំចុះលេខ ឬសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម[19] ឬប្រើឯកសារក្លែងក្លាយដោយចេតនាក្នុងទំនាក់ទំនងពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី១ឆ្នាំ ទៅ៥ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១.000.00 លានរៀល ទៅ១0.000.000 លានរៀល ។

## ២.ការប្រព្រឹត្តទៅនៃក្រុមហ៊ុន

ក្នុងដំណើរការរបស់ក្រុមហ៊ុន តែងតែជួបប្រទះនឹងកិច្ចការមួយចំនួនដែលជៀសមិនរួចដូចជាការបង់ពន្ធ ការប្រើប្រាស់សិទ្ធិ ឬការទទួលខុសត្រូវលើបំណុល និងកាតព្វកិច្ចផ្សេងៗ ពិសេសការលក់ ឬការផ្ទេរភាគហ៊ុននៅក្នុងក្រុមហ៊ុនជាដើម ។

### ២.១ ការបង់ពន្ធ

ជាគោលការណ៍ដំណើរការក្នុងនាមជាក្រុមហ៊ុន តែងតែជៀសមិនរួចពីការបង់ពន្ធ ប៉ុន្តែក៏អាស្រ័យទៅតាមប្រភេទនៃក្រុមហ៊ុនសកម្មភាពអាជីវកម្ម និងផលរបរដែលជាប្រាក់ចំណេញរបស់សហគ្រាសផងដែរ ។

**ប្រភេទពន្ធទាំងនោះដែលពាក់ពន្ធលើមុខជំនួញរួមមាន៖**

| ប្រភេទពន្ធ | អត្រាពន្ធ |
|---|---|
| ពន្ធលើប្រាក់បៀវត្ស | ៥% ទៅ២0% នៃប្រាក់បៀវត្ស |
| ពន្ធលើអត្ថប្រយោជន៍បន្ថែម | ២0% នៃអត្ថប្រយោជន៍បន្ថែម |
| ប្រាក់រំដោះពន្ធលើប្រាក់ចំណេញនៃរបរគតិរួមបញ្ចូលទាំងពន្ធអាករទាំងអស់ | ១% |
| ពន្ធកាត់ទុកទៅតាមប្រភេទនៃការប្រាក់ចំណូល | ៤%, ៦%, ១0% និង១៥% |
| ពន្ធអាករលើតម្លៃបន្ថែម | ១0% |
| ពន្ធលើប្រាក់ចំណេញទៅតាមប្រភេទនៃប្រាក់ចំណេញ | 0%, ៥%, ៩%, ២0% និង៣0% |
| ពន្ធអប្បរមានៃផលរបរប្រចាំឆ្នាំគិតរួមបញ្ចូលទាំងពន្ធអាករនានា | ១% |
| ពន្ធប៉ាតង់ | ១,១៤0,000រៀលក្នុងមួយឆ្នាំ<br>៥៧0,000រៀល សម្រាប់កន្លះឆ្នាំ |

[19] មាត្រា៤២ កថាខណ្ឌ១ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

| | |
|---|---|
| អាករពិសេសលើទំនិញ និងសេវាមួយចំនួនទៅតាមប្រភេទនៃទំនិញ | ២%, ១០%, ២០% និង៣០% |
| ពន្ធនាំចូល | មានច្រើនប្រភេទទៅតាមតារាងពន្ធគយ |
| ពន្ធនាំចេញ | មានច្រើនប្រភេទទៅតាមតារាងពន្ធគយ |

### ២.២ សិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុន

ក្រុមហ៊ុន គឺត្រូវបានចងភ្ជាប់ជាមួយសិទ្ធិ និងកាតព្វកិច្ច ដែលសិទ្ធិនៅក្នុងនោះមានច្រើន សិទ្ធិ[20]គឺសំដៅដល់សិទ្ធិផ្សេងៗដូចជា៖

- សិទ្ធិក្នុងការស្វែងរកប្រាក់ចំណេញ
- សិទ្ធិក្នុងការធ្វើសេចក្តីសម្រេច
- សិទ្ធិក្នុងការលក់ ឬការធ្វើអនុប្បទានភាគហ៊ុន ឬក្រុមហ៊ុន
- សិទ្ធិក្នុងការរំលាយក្រុមហ៊ុនចូលគ្នា។ល។

**ក្រុមហ៊ុន ក៏ត្រូវបានចងភ្ជាប់ផងដែរជាមួយកាតព្វកិច្ច[21]របស់ក្រុមហ៊ុន ដែលកាតព្វកិច្ចទាំងនោះរួមមាន៖**

- កាតព្វកិច្ចក្នុងការបង់ពន្ធ
- កាតព្វកិច្ចក្នុងការសងបំណុល
- កាតព្វកិច្ចក្នុងការប្រកាសផ្សាយ ។ល។

### ២.៣ ការផ្ទេរ ការលក់ភាគហ៊ុន

នៅក្នុងដំណើរការរបស់ក្រុមហ៊ុនតែងតែជៀសមិនរួចពីការលក់ ឬការផ្ទេរភាគហ៊ុនរវាងសមាជិកភាគហ៊ុននៅក្នុងក្រុមហ៊ុន ឬទៅទាយាទ ឬទៅតតិយជន ។

បែបបទនៃការអនុញ្ញាតការផ្ទេរនេះក៏អាស្រ័យទៅតាមប្រភេទនីមួយៗរបស់ក្រុមហ៊ុន ឬលក្ខន្តិកៈរបស់ក្រុមហ៊ុនកំណត់ ។

## ៣.ការបញ្ចប់ក្រុមហ៊ុន

ការរំលាយក្រុមហ៊ុនគឺស្ថិតក្រោមមូលហេតុជាច្រើនយ៉ាងដូចជា៖

- មូលហេតុដែលមានចែងក្នុងកិច្ចសន្យា (ភាគីណាមួយធ្វើខុសពីប្រការដែលមានចែងក្នុងកិច្ចសន្យា)
- គោលបំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់

---

[20] សិទ្ធិ គឺសំដៅលើសេចក្តីសម្រេច សេចក្តីចម្រើន អំណាច វចនានុក្រមសម្រេចព្រះសង្ឃរាជ **ជួន ណាត**

[21] កាតព្វកិច្ច គឺចំណងតាមផ្លូវច្បាប់ ដែលចងបុគ្គលពីរនាក់ដោយឲ្យបុគ្គលម្នាក់ដែលបានកំណត់ថា កូនបំណុល មានករណីកិច្ចមួយចំនួនចំពោះបុគ្គលម្នាក់ទៀតដែលបានកំណត់ថា ម្ចាស់បំណុល យោងតាមសន្ធានុក្រម ផ្នែករដ្ឋប្បវេណី ល.រ៤

- គ្មានលទ្ធភាពក្នុងការបន្តអាជីវកម្ម តទៅមុខទៀត

- តាមការព្រមព្រៀងជាឯកច្ឆ័ន្ទរបស់សមាជិកទូទៅបាន តាមមូលហេតុមួយដែលស្របទៅតាមច្បាប់

- តុលាការអាចរំលាយក្រុមហ៊ុនបាន តាមមូលហេតុមួយដែលស្របច្បាប់

- ការបញ្ចប់ក្រុមហ៊ុនបែបសាធារណៈ ត្រូវធ្វើឡើងដោយមានការផ្សព្វផ្សាយក្នុងសារព័ត៌មាន ជាភាសាខ្មែរក្នុងរយៈពេល ៤សប្តាហ៍ជាបន្តបន្ទាប់ និងតម្កល់លើសេចក្តីជូនដំណឹងនៃការរំលាយនៅក្នុងការិយាល័យចុះបញ្ជី ។

- ការចុះផ្សាយក្នុងសារព័ត៌មានដោយមានចុះនិទ្ទេស ស្តីពីការតែងតាំងអ្នកជម្រះបញ្ជី

- សេចក្តីសម្រេចក្នុងការបញ្ចប់ក្រុមហ៊ុន និងសេចក្តីតែងតាំងអ្នកជម្រះបញ្ជីត្រូវដាក់តម្កល់នៅក្នុងការិយាល័យចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម

- ចាប់ពីពេលដែលត្រូវបានបញ្ចប់នៅក្រុមហ៊ុននោះ ត្រូវតែមានដាក់ភ្ជាប់មកជាមួយនាមការណ៍ នូវនិទ្ទេសក្រុមហ៊ុនកំពុងជម្រះក្តីការផ្សាយនេះមានប្រសិទ្ធភាពកាន់តែខ្លាំងកាលណាមានចុះឈ្មោះនៃអ្នកជម្រះក្តីផងដែរ។ ការចុះនិទ្ទេសនេះត្រូវធ្វើរាល់លិខិតដែលចេញពីក្រុមហ៊ុនចំពោះតតិយជន ដូចជា លិខិតឆ្លើយឆ្លង វិក្កយបត្រ ប្រកាស ។ល។ បន្ថែមពីនេះ ការបញ្ចប់លើវិធាននេះធ្វើឲ្យមានការបង់ពិន័យ ។

**ការបញ្ចប់នៃក្រុមហ៊ុន អាចបណ្តាលមកពីកត្តាសំខាន់មួយចំនួនដូចជា៖**

- ការចែងក្នុងកិច្ចសន្យា

- ការព្រមព្រៀង

- ការរំលាយតាមផ្លូវតុលាការ

### ៣.១ ការចែងក្នុងកិច្ចសន្យា

ក្នុងករណីដែលមានចែងកំណត់ច្បាស់ក្នុងកិច្ចសន្យាបង្កើតក្រុមហ៊ុន ឬលក្ខន្តិកៈរបស់ក្រុមហ៊ុន ដែលជាគោលបំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់នោះក្រុមហ៊ុនអាចនឹងរំលាយតាមការចែងនៅក្នុងកិច្ចសន្យាតាមការព្រមព្រៀងនេះបាន ។

### ៣.២ ការព្រមព្រៀង

ក្រុមហ៊ុន ត្រូវបញ្ចប់សកម្មភាពរបស់ខ្លួនដោយសារគ្មានលទ្ធភាពបន្តអាជីវកម្ម ឬ តាមការព្រមព្រៀងជាឯកច្ឆ័ន្ទពីសំណាក់ម្ចាស់ភាគហ៊ុន ឬពីសំណាក់អភិបាលដោយអាស្រ័យទៅតាមប្រភេទនៃក្រុមហ៊ុននីមួយៗ ។

### ៣.៣ ការរំលាយតាមផ្លូវច្បាប់

ក្រុមហ៊ុនអាចរំលាយតាមផ្លូវតុលាការបានតាមរយៈការស្នើសុំ ឬ ត្រូវបានរំលាយដោយបង្ខំដោយតុលាការ ។ **ឧទាហរណ៍៖** ក្រុមហ៊ុន ក ត្រូវបានប្រកាសបិទដំណើរការអាជីវកម្មពីតុលាការ ដោយមូលហេតុកម្មវត្ថុនៃអាជីវកម្មខុសច្បាប់ ឬក្នុងករណីក្ស័យធន ជាដើម ។

# ជំពូកទី២
# ទម្រង់នៃក្រុមហ៊ុនពាណិជ្ជកម្ម

# ជំពូកទី២
# ទម្រង់នៃក្រុមហ៊ុនពាណិជ្ជកម្ម

## ផ្នែកទី១ សហគ្រាសឯកបុគ្គល និងឯកបុគ្គលទទួលខុសត្រូវមានកម្រិត

### ១.សហគ្រាសឯកបុគ្គល

សហគ្រាសឯកបុគ្គល ត្រូវបានកំណត់សម្គាល់ថាជាក្រុមហ៊ុនមួយដែលមានភាពពេញនិយមច្រើន និងមានភាពទាក់ទាញបំផុតមួយនៅកម្ពុជា ដែលត្រូវបានអ្នកប្រកបអាជីវកម្មភាគច្រើនបានសម្រេចចិត្តនៅក្នុងការបង្កើតសហគ្រាសឯកបុគ្គលនេះឡើង[22] ។ លើសពីនេះទៅទៀត **សហគ្រាសឯកបុគ្គល** ក៏ត្រូវបានគេសង្កេតឃើញថាបានប្រែក្លាយមកពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត នៅក្នុងករណីដែលសមាជិករបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត បានលក់ភាគហ៊ុនទាំងនោះទៅឲ្យបុគ្គលតែម្នាក់ ដែលជាមូលហេតុនាំឲ្យក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនេះបានក្លាយជា **សហគ្រាសឯកបុគ្គល** ហើយធ្វើពាណិជ្ជកិច្ចរបស់ខ្លួនដូចទៅនឹងក្រុមហ៊ុនឯកកម្មសិទ្ធិដែរ ប៉ុន្តែត្រូវទទួលខុសត្រូវតែម្នាក់ឯង ទទួលខុសត្រូវដោយមានកម្រិត ។

ហេតុនេះហើយខាងក្រោមនេះ នឹងបង្ហាញពីសញ្ញាណបន្ថែមទៀតដែលទាក់ទងជាមួយសហគ្រាសឯកបុគ្គល ចាប់ពីការបង្កើត ការប្រព្រឹត្តទៅនៃសហគ្រាស និងរហូតដល់ការចុះបញ្ជីដើម្បីទទួលបានបុគ្គលភាពគតិយុត្តជាដើម ។

### ១.១ ស្ថានភាពគតិយុត្ត និងនិយមន័យ

#### ១.១.១ ស្ថានភាពគតិយុត្ត

បើនិយាយពីស្ថានភាពគតិយុត្តរបស់សហគ្រាសឯកបុគ្គល គឺមានការប្រែប្រួល និងមិនទាន់មានភាពជាក់លាក់នៅឡើយ ដោយហេតុថាស្ថានភាពរបស់សហគ្រាសឯកបុគ្គលនោះមានទំនាក់ទំនងជាមួយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មិនបានកំណត់ពីអត្ថិភាពនៃការបង្កើតសហគ្រាសឯកបុគ្គលដូចដែរមានចែងនៅក្នុងសារាចរណែនាំស្តីពីការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៧ ។ លើសពីនេះទៅទៀត គេក៏សង្កេតឃើញមានការកំណត់ស្តីពីចំណាត់ថ្នាក់អ្នកជាប់ពាក់ព័ន្ធតាមរបបស្វ័យប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

#### ១.១.២ និយមន័យ

**សហគ្រាសឯកបុគ្គល** គឺសំដៅដល់សហគ្រាសអាជីវកម្មមួយប្រភេទដែលកម្មសិទ្ធិករត្រូវតែជារូបវន្តបុគ្គលណាម្នាក់ ឬអាចនិយាយបានថា សហគ្រាសឯកបុគ្គល គឺសំដៅជាសហគ្រាសដែលបានបង្កើតឡើងដោយរូបវន្តបុគ្គលតែម្នាក់ ដែលជាម្ចាស់ដើមទុន ។ ម្ចាស់ដើមទុនជារូបវន្តបុគ្គលតែម្នាក់នេះអាចហៅម្យ៉ាងទៀត

[22] យោងតាមស្ថិតិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឆ្នាំ២០២២

បានថា **ឯកកម្មសិទ្ធិករ** ។

យើងក៏អាចសម្គាល់បានថា នៅក្នុងសហគ្រាសឯកបុគ្គល កិច្ចសន្យា គណនីប្រើប្រាស់ ទ្រព្យសម្បត្តិ និងអាជ្ញាប័ណ្ណទាំងអស់ ត្រូវបានដាក់ឈ្មោះតែម្ចាស់តែម្នាក់គត់របស់រូបវន្តបុគ្គល ( ម្ចាស់សហគ្រាសឯកបុគ្គល ឬសហគ្រិន ) ។

ម្ចាស់សហគ្រាសឯកបុគ្គល គឺជាអ្នកផ្តល់ដើមទុនចាប់ផ្តើមដំបូងទាំងអស់ ដែលភាគច្រើនគេសង្កេតឃើញថាជាញឹកញាប់ដើមទុនទាំងនោះ អាចខ្ចីពីកម្ចីពីធនាគារ ដោយមានការដាក់បញ្ចាំផ្ទះ ឬទ្រព្យសម្បត្តិរបស់ម្ចាស់សហគ្រាស ឬកម្ចីពីគ្រួសារ ។

## ១.២ ការបង្កើត

ក្នុងការក្លាយជាសហគ្រិនម្នាក់ ឬអាចនិយាយបានថាក្នុងការក្លាយជាម្ចាស់សហគ្រាសឯកបុគ្គល គឺជាវិធីសាស្ត្រល្អបំផុតក្នុងការបង្កើតអាជីវកម្មមួយដោយខ្លួនឯង ដែលមានភាពងាយស្រួលនឹងឆាប់រហ័សជាទីបំផុតពីព្រោះការបំពេញបែបបទមានលក្ខណៈងាយស្រួល មិនមានភាពស្មុគស្មាញដូចការបង្កើតក្រុមហ៊ុននោះទេ ។

ហេតុនេះហើយបានជារូបវន្តបុគ្គលភាគច្រើនដែលមានដើមទុន ឬ មានធនធាន បានសម្រេចចិត្តក្នុងការបង្កើតសហគ្រាសជាលក្ខណៈឯកបុគ្គល ដែលខ្លួននឹងក្លាយជាម្ចាស់សហគ្រាសឯកបុគ្គល ឬហៅថា សហគ្រិន ដែលមានតួនាទី និងទំនួលខុសត្រូវដោយខ្លួនឯងផ្ទាល់ទៅលើទ្រព្យសកម្ម និងទ្រព្យអកម្ម (បំណុល) និងទទួលរ៉ាប់រងកាតព្វកិច្ចទាំងអស់នៃអាជីវកម្ម ។

ការបង្កើតសហគ្រាសឯកបុគ្គលនេះ មិនមានលក្ខណៈជានីតិបុគ្គលដាច់ដោយឡែកពីម្ចាស់សហគ្រាស ដូចនីតិបុគ្គលដែលជាក្រុមហ៊ុននោះទេ ដោយមូលហេតុថា សហគ្រាសឯកបុគ្គលមិនត្រូវឲ្យមានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដូចក្រុមហ៊ុននោះទេ ។ ប៉ុន្តែសហគ្រាសឯកបុគ្គល ត្រូវបានបែងចែងជាពីរប្រភេទគឺ៖

**១.សហគ្រាសឯកបុគ្គលដែលជាប់ពន្ធលើប្រាក់ចំណេញ**

**២.សហគ្រាសឯកបុគ្គលដែលមិនជាប់ពន្ធលើប្រាក់ចំណេញ** ។

សហគ្រាសឯកបុគ្គលដែលជាប់ពន្ធលើប្រាក់ចំណេញត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នេះបើតាមសេចក្តីជូនដំណឹងលេខ០០៦ សជណ ពដ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៧ ស្តីពីបញ្ញាត្តិសំខាន់ៗនៃច្បាប់សារពីពន្ធឆ្នាំ១៩៩៧បានកំណត់ថាសហគ្រាសដែលមានភាគហ៊ុននៃប្រាក់ចំណេញប្រចាំឆ្នាំចាប់ពី 0 រៀលដល់ ៦.000.000 រៀលត្រូវចាត់ទុកថាមិនបានជាប់ពន្ធលើប្រាក់ចំណេញនោះទេ ។

ចំណែកសហគ្រាសឯកបុគ្គលដែលមិនជាប់ពន្ធលើប្រាក់ចំណេញវិញច្បាប់មិនបានកំណត់ ឬទាមទារឲ្យមានការរៀបចំបញ្ជីពាណិជ្ជកម្ម ដូចសហគ្រាសឯកបុគ្គលដែលជាប់ពន្ធលើប្រាក់ចំណេញនោះទេតែសហគ្រាសឯកបុគ្គលដែលមិនជាប់ពន្ធលើប្រាក់ចំណេញនេះត្រូវស្នើសុំលិខិតអនុញ្ញាត១ឆ្នាំម្តងនៅតាមមន្ទីរពាណិជ្ជកម្មខេត្ត

ឬ ក្រុងដែលជាទីតាំងផ្ទាល់របស់អាជីវកម្ម ។

## ១.៣ ការចុះបញ្ជីសហគ្រាសឯកបុគ្គល

បន្ទាប់ពីបានស្វែងយល់ពីសញ្ញាណ និងការបង្កើតរួចមក យើងក៏បានចម្ងល់ថា តើសហគ្រាសឯកបុគ្គលចាំបាច់ក្នុងការចុះបញ្ជីដែរឬទេ ? ឬពុំចាំបាច់ចុះបញ្ជីក៏អាចធ្វើអាជីវកម្មបាន ?

សហគ្រាសឯកបុគ្គល ដែលជាប់ពន្ធលើរបបពិតត្រូវចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនេះបើយោងតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ៧៩៥ បានកំណត់ពីតម្លៃសម្រាប់សហគ្រាសឯកបុគ្គលដែលត្រូវបង់ពន្ធតាមរបបពិត៖

- ការផ្គត់ផ្គង់ទំនិញៈ ចំណូលប្រចាំឆ្នាំច្រើនជាង ៥០០.០០០.០០០ (ប្រាំរយលាន)រៀល
- សេវាកម្មៈ ចំណូលប្រចាំឆ្នាំច្រើនជាង ២៥០.០០០.០០០ (ពីររយហាសិបលាន)រៀល
- ចុះកិច្ចសន្យាជាមួយរដ្ឋាភិបាលៈចំណូលប្រចាំឆ្នាំច្រើនជាង១២៥.០០០.០០០(មួយរយម្ភៃប្រាំលាន)រៀល

ប្រសិនបើ ចំណូលរបស់សហគ្រាសឯកបុគ្គលមានចំនួនទាបជាងតម្លៃកំណត់ខាងលើសហគ្រាសនេះត្រូវស្ថិតក្រោមរបបម៉ៅការ ( របបសម្របសម្រួល ) ។

សម្រាប់ការចុះបញ្ជីសហគ្រាសឯកបុគ្គលមានចំនួន៥ជំហាន៖

**ជំហានទី១៖** ម្ចាស់សហគ្រាសឯកបុគ្គល ឬឯកកម្មសិទ្ធិករត្រូវជូនដំណឹងមកមន្ត្រីចុះបញ្ជីនៅតាមមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង ឬនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មថាខ្លួនជារូបវន្តបុគ្គល ដែលមានបំណងចង់ធ្វើអាជីវកម្មជាម្ចាស់សហគ្រាសឯកបុគ្គល ឯកកម្មសិទ្ធិករត្រូវពិនិត្យនាមករណ៍ជាមួយមន្ត្រីចុះបញ្ជី ។

**ជំហានទី២៖** ឯកសារ និងកម្រៃរដ្ឋបាលសម្រាប់ចុះបញ្ជី

| **ឯកសារ** | **ចំនួន** |
|---|---|
| ១.ពាក្យសុំគម្រូ យ | ០៣ ច្បាប់ (១ច្បាប់ដើម) |
| ២.មានក្នុង CD ROM | ០២ ច្បាប់ (ថតចម្លង) |
| ៣.លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណថតចម្លងរបស់អ្នកស្នើសុំ ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ | ០៣ ច្បាប់ |
| ៤.រូបថតរបស់ឯកកម្មសិទ្ធិករ (៤X៦ ស.ម) | ០៣ សន្លឹក |
| ៥.លិខិតអនុញ្ញាតអាជីវកម្មផ្សេងៗថតចម្លង(ប្រសិនបើមាន) | ០៣ ច្បាប់ |
| **កម្រៃ** | |
| ១.កម្រៃរដ្ឋបាលចុះបញ្ជីជាផ្លូវការ | ១២០.០០០រៀល |
| ២.កម្រៃរដ្ឋបាលលុបឈ្មោះ | ៦០.០០០ រៀល |

**ជំហានទី៣៖** នៅពេលដែលរៀបចំឯកសារដូចមានរៀបរាប់ខាងលើត្រូវបានបំពេញរួចរាល់ និងមានលក្ខណៈត្រឹមត្រូវហើយ ឯកកម្មសិទ្ធិករត្រូវបង្ហាញខ្លួននៅមន្ទីរពាណិជ្ជកម្មខេត្ត ឬក្រុង ឬនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដើម្បីចុះហត្ថលេខា ។

**ជំហានទី៤៖** រាល់ឯកសារពាក់ព័ន្ធដែលបានរៀបចំខាងលើ ត្រូវដាក់ជូននាយកដ្ឋានចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម ។

**ជំហានទី៥៖** មន្ទីរពាណិជ្ជកម្មខេត្ត ឬ ក្រុង ឬ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម នឹងធ្វើការជូនដំណឹងដល់ឯកកម្មសិទ្ធិករ នៅក្នុងអំឡុងពេល ០១(មួយ)ខែ ក្រោយការដាក់ពាក្យស្នើសុំ ដើម្បីមកទទួលយកវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ។

## ១.៤ គុណសម្បត្តិ និងគុណវិបត្តិ

នៅក្នុងការបង្កើត ឬការដំណើរការអាជីវកម្មអ្វីមួយគឺជៀសមិនផុតនោះទេនូវផលវិបាក តែនៅក្នុងនោះក៏មានភាពងាយស្រួលផងដែរ ដែលម្ចាស់អាជីវកម្មត្រូវតែមានផែនការឲ្យបានច្បាស់លាស់ ។

### ១.៤.១ គុណសម្បត្តិ

នៅក្នុងការបង្កើតសហគ្រាសឯកបុគ្គល គឺមានគុណសម្បត្តិជាច្រើនដូចជា៖

១. ការបង្កើតក្រុមហ៊ុនមិនបង្កភាពស្មុគស្មាញ និងមិនត្រូវចំណាយថវិកាច្រើន

២. ការទូទាត់ប្រាក់បុគ្គលិកមិនមានភាពស្មុគស្មាញ ការគ្រប់គ្រងចំណាយផ្ទាល់ខ្លួនងាយស្រួល

៣. ការគិតប្រាក់បង់ពន្ធមានភាពលឿន

៤. ការសម្រេចចិត្តមានភាពរហ័ស មនុស្សតិចមានសណ្តាប់ធ្នាប់ រក្សាការសម្ងាត់បានល្អ

៥. មានភាពងាយស្រួលក្នុងការរំលាយ .....។

### ១.៤.២ គុណវិបត្តិ

នៅក្នុងការបង្កើតសហគ្រាសឯកបុគ្គល បានកើតមាននូវគុណសម្បត្តិជាច្រើនក៏ប៉ុន្តែមិនអាចជៀសផុតបានទេនូវគុណវិបត្តដែលបានជាច្រើនដូចជា៖

១. ទ្រព្យសម្បត្តិរបស់ម្ចាស់អាជីវកម្ម ងាយទទួលរងហានិភ័យ

២. ការងារនៅក្នុងអាជីវកម្មមានច្រើន តែត្រូវទទួលបន្ទុកម្នាក់ឯង

៣.មិនសូវមានក្រុមហ៊ុនជឿទុកចិត្ត និងមានទំនាក់ទំនងល្អជាមួយច្រើន

៤. ការទទួលខុសត្រូវមិនមានកំណត់ចំពោះបំណុល នៃអាជីវកម្មរបស់ខ្លួន .....។

## ១.៥ ការបញ្ចប់

នៅក្នុងការបញ្ចប់របស់សហគ្រាសពាណិជ្ជកម្មមានការបញ្ចប់ផ្សេងៗពីគ្នាតាមការកំណត់របស់សហគ្រាសពាណិជ្ជកម្ម ដែលយើងមានការកត់សម្គាល់បានថា ជាការបញ្ចប់ដោយស្ម័គ្រចិត្ត និងការបញ្ចប់ដោយមិនបានស្ម័គ្រចិត្ត ។

### ១.៥.១ ការបញ្ចប់ដោយស្ម័គ្រចិត្ត

ការផ្ទេរការកាន់កាប់ ឬចង់លក់ដូរទៅឲ្យបុគ្គលផ្សេង នីតិបុគ្គលដែលសំដៅលើសហគ្រាសឯកបុគ្គលអាចធ្វើការលក់ ឬ ផ្ទេរការកាន់បានដោយធ្វើតាមការសម្រេចចិត្តរបស់ ឯកកម្មសិទ្ធិករ ដែលជាម្ចាស់សហគ្រាសផ្ទាល់ ។ នេះក៏អាចកំណត់ថា ការបញ្ចប់ក្រុមហ៊ុនមួយដោយស្ម័គ្រ ឬតាមគោលបំណងរបស់ម្ចាស់ក្រុមហ៊ុន ។ ម្ចាស់ក្រុមហ៊ុនក៏អាចធ្វើអនុប្បទាន[23]ទាំងស្រុងតាមគោលបំណង ឬឆន្ទៈរបស់ខ្លួន ។

### ១.៥.២.ការបញ្ចប់ដោយមិនស្ម័គ្រចិត្ត

ការទទួលមរណៈភាពរបស់ម្ចាស់សហគ្រាសក៏ជាកត្តាមួយ ឬ ជាមូលហេតុមួយដែលនាំឲ្យក្រុមហ៊ុនត្រូវបានបញ្ចប់ ត្រូវបានរំលាយ ប្រសិនបើម្ចាស់សហគ្រាសមិនមានទាយាទ ឬអ្នកស្នងមរតក ដែលធ្វើឲ្យសហគ្រាសមិនអាចដំណើរការទៅមុខបន្តទៀតបាន ។ ប៉ុន្តែក្រៅពីមូលហេតុនេះសហគ្រាសក៏ត្រូវបានបញ្ចប់ ឬ ត្រូវមានរំលាយដោយមូលហេតុ៖

**១.ការបញ្ចប់តាមផ្លូវតុលាការ**

**២.កម្មវត្ថុនៃសហគ្រាសក្លាយជាមិនស្របច្បាប់**

**៣.ភាពក្ស័យធនរបស់សហគ្រាស**

**៤.អាជ្ញាយុកាលនៃក្រុមហ៊ុន**

ការទទួលខុសត្រូវក្នុងនាមជានីតិបុគ្គលមិនអាចគេចផុតបានទេប្រសិនបើនីតិបុគ្គលនោះត្រូវបានបញ្ចប់ ឬត្រូវបានរំលាយដោយមូលហេតុខាងលើពិតប្រាកដមែន ប៉ុន្តែនីតិបុគ្គលដែលសំដៅដល់សហគ្រាសនោះត្រូវបំពេញកាតព្វកិច្ចសងបំណុល (ទ្រព្យអកម្ម) នោះរហូតទាល់តែអស់ ទើបរួចផុតពីកាតព្វកិច្ច ។

[23] អនុប្បទាន គឺការផ្ទេរ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ ដែលជាអនុប្បទាយីទៅឲ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក យោងតាមសន្ទានុក្រម ផ្នែករដ្ឋប្បវេណី ល.រ ១៨៩

# ២.សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

## ២.១ និយមន័យ និងទម្រង់

### ២.១.១ និយមន័យ

សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ដែលហៅជាភាសាអង់គ្លេសថា Single Member Private Company Limited ដែលជាប្រភេទក្រុមហ៊ុនមួយត្រូវបានបង្កើតឡើងដោយឆន្ទៈរបស់រូបវន្តបុគ្គលតែម្នាក់ដែលជាម្ចាស់ដើមទុន ។ ម្យ៉ាងទៀតសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ត្រូវបានគេសម្គាល់ថាជាសហគ្រាសដែលមានម្ចាស់តែម្នាក់ ហើយទទួលបាននូវនីតិបុគ្គលលក្ខណៈដែលមានអាសយដ្ឋានមានសញ្ជាតិ មានសិទ្ធិ កាតព្វកិច្ច និងមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ព្រមទាំងទទួលខុសត្រូវដោយមានកម្រិតចំពោះកំហុស ។

### ២.១.២ ទម្រង់

សហគ្រាសពាណិជ្ជកម្មនីមួយៗ មានលក្ខណៈខុសប្លែកពីគ្នា តាមទម្រង់នីមួយៗ ដែលយើងអាចធ្វើការកត់សម្គាល់ថាសហគ្រាសពាណិជ្ជកម្មនោះជាប្រភេទសហគ្រាសអ្វី?គឺជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ឬសហគ្រាសឯកជន ដែលជាចំណុចសំខាន់មួយគួរតែយកចិត្តទុកដាក់ ។ សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតជាប្រភេទសហគ្រាសដែលមានទ្រង់ទ្រាយដោយឡែក ហើយត្រូវបានបង្កើតឡើងដោយការប្រែក្លាយពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅពេលដែលភាគហ៊ុនទាំងអស់នៃក្រុមហ៊ុននោះត្រូវបានប្រមូលផ្តុំក្នុងដៃម្ចាស់ភាគហ៊ុនតែម្នាក់ ។

លើសពីនេះក៏មានការកត់សម្គាល់ឃើញថាសមាជិកក្រុមហ៊ុននេះ ការទទួលខុសត្រូវលើបំណុលរបស់សហគ្រាសដោយមានកម្រិតត្រឹមដើមទុនរបស់សហគ្រាសតែប៉ុណ្ណោះមានន័យថាការទទួលខុសត្រូវរបស់សមាជិកក្រុមហ៊ុននេះ គឺទទួលតែបំណុលដែលជាដើមទុនរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ។

## ២.២ ការបង្កើត និងការគ្រប់គ្រង

### ២.២.១ ការបង្កើត

ការបង្កើតសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត គឺមានភាពស្មុគស្មាញច្រើនជាងការបង្កើតសគ្រាសឯកបុគ្គល ដោយមានមូលហេតុថាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតចាំបាច់ត្រូវមានការរៀបចំ ក៏ដូចជាការបំពេញនូវលក្ខន្តិកៈដែលមានកំណត់ជាច្រើនដូចជា៖

- ទ្រង់ទ្រាយក្រុមហ៊ុន
- កម្មវត្ថុអាជីវកម្ម
- នាមករណ៍
- ទីស្នាក់ការ

- ដើមទុន
- ភាគហ៊ុន
- ថេរវេលា ។ល។

ជាពិសេសមានកន្លែងមួយដែលម្ចាស់សហគ្រាសឯកបុគ្គលគួរគត់សម្គាល់ និងយកចិត្តទុកដាក់នោះគឺត្រូវដាក់ពាក្យថា **សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត** ត្រូវសរសេរពាក្យអក្សរកាត់ដាក់នៅចុង ឬខាងក្រោម ។

សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ត្រូវធ្វើការចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ប្រសិនបើកម្មវត្ថុនៃសហគ្រាសមានការផ្ទុយពីបញ្ញត្តិច្បាប់ ឬមានភាពផ្ទុយច្បាប់គឺមិនត្រូវបានអនុញ្ញាតឲ្យចុះបញ្ជីពីក្រសួងពាណិជ្ជកម្មនោះទេ ។ សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតនឹងទទួលបានបុគ្គលភាពគតិយុត្តិភ្លាមៗ បន្ទាប់ពីធ្វើការចុះបញ្ជីពាណិជ្ជកម្ម មានន័យថាសហគ្រាសឯកបុគ្គលទទួលមានកម្រិត នឹងទទួលបានឋានៈជានីតិបុគ្គល ចាប់តាំងពីពេលចុះបញ្ជីពាណិជ្ជកម្មរួចរាល់ ។ លើសពីនេះអ្វីដែលកាន់តែពិសេសជាងនេះទៀត ការចុះបញ្ជីពាណិជ្ជកម្មត្រូវមានការចុះផ្សាយជាសាធារណៈតាមរយៈពាណិជ្ជកិច្ច ។

សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ត្រូវមានថិរវេលាតាមច្បាប់កំណត់មិនឲ្យលើសពី៩៩ឆ្នាំ ហើយនៅពេលដែលអាយុកាលដែលបានកំណត់របស់ក្រុមហ៊ុននោះ ត្រូវបានបញ្ចប់សកម្មភាពអាជីវកម្ម ប៉ុន្តែប្រសិនបើក្រុមហ៊ុនចង់នៅបន្តដំណើរការអាជីវកម្មរបស់ខ្លួន អាចធ្វើការសុំបន្តដំណើរការអាជីវកម្មរបស់ខ្លួនបានដោយមិនឲ្យលើសពី ៩៩ឆ្នាំនោះទេ ។ ប៉ុន្តែតាមកាលៈទេសជាក់ស្តែង គេសង្កេតឃើញថាទោះបីជាក្រុមហ៊ុននោះប្រកបអាជីវកម្មក្នុងរយៈពេលខ្លីក៏ដោយ ក៏គេសង្កេតឃើញថានៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុននោះនៅតែកំណត់ថិរវេលា ៩៩ឆ្នាំដដែល ។ ការធ្វើបែបនេះរបស់ក្រុមហ៊ុន មានភាពងាយស្រួលក្នុងការបន្តអាជីវកម្មរបស់ខ្លួន ប្រសិនបើក្រុមហ៊ុនចង់បន្តអាជីវកម្មរបស់ខ្លួន នៅពេលផុតអាណត្តិ ៩៩ឆ្នាំ ។

លើសពីនេះទៀត នៅពេលស្នើសុំចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មពិតជាចាំបាច់ណាស់នូវលិខិតបញ្ជាក់ពីការតម្កល់ដើមទុន ចុះបញ្ជីនៅធានាគារណាមួយក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានចំនួនអប្បរមាដែលអាចស្នើសុំចុះបញ្ជីបានគឺស្មើនឹង ៤.០០០.០០០៛(បួនលានរៀល)គឺប្រហាក់ប្រហែលទៅនឹង ១.០០០$ ដុល្លារអាមេរិច ។

### ២.២.២ ការគ្រប់គ្រង

ក្រុមហ៊ុនមានម្ចាស់តែម្នាក់ដែលកាន់កាប់ភាគហ៊ុនទាំងអស់ ។ ភាគហ៊ុនរបស់ម្ចាស់សហគ្រាសតែម្នាក់អាចត្រូវបានធ្វើអនុប្បទានមួយផ្នែក ឬទាំងស្រុង ។ ម្ចាស់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ឬអ្នកគ្រប់គ្រងដែលជាគតិយជនត្រូវប្រកាសនៅចំពោះមុខច្បាប់ថាខ្លួនមិនមែនជាមន្ត្រីរាជការ ហើយក៏ពុំដែលជាប់ទោស

ពេលណាមួយក្នុងរឿងព្រហ្មទណ្ឌ រដ្ឋប្បវេណី និងពាណិជ្ជកម្មឡើយ ។

កាលណាម្ចាស់សហគ្រាសទទួលមរណៈភាព ភាគហ៊ុនត្រូវបានផ្ទេរទៅសហព័ន្ធ ឬអ្នកទទួលមរតក ។ សេចក្តីសម្រេចទាំងអស់ជាសិទ្ធិរបស់ម្ចាស់សហគ្រាស ។ លើសពីនេះម្ចាស់សហគ្រាសអាចធ្វើការតែងតាំងបុគ្គលផ្សេងទៀតធ្វើជានាយកក្រុមហ៊ុនបានដោយទទួលបានប្រាក់ខែ ឬប្រាក់រង្វាន់តាមការព្រមព្រៀង ។ នាយកដែលជាតតិយជននេះអាចត្រូវបានដកចេញពីដំណែងដោយមាន ឬគ្មានមូលហេតុ ប៉ុន្តែក្នុងករណីដែលនាយកត្រូវបានដកចេញដោយគ្មានមូលហេតុ ម្ចាស់សហគ្រាសត្រូវធ្វើការសងជំងឺចិត្តដល់នាយកនោះ តាមការព្រមព្រៀងរវាងម្ចាស់សហគ្រាស ជាមួយនាយកគ្រប់គ្រង ។

## ២.៣ ការចុះបញ្ជីសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

ការចុះបញ្ជីសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត (Limited Liability Company - LLC) គឺជាដំណើរការមួយដែលត្រូវបានធ្វើឡើង ដើម្បីបង្កើតសហគ្រាសដែលមានស្ថានភាពជានីតិបុគ្គលត្រឹមត្រូវស្របតាមច្បាប់នេះមានន័យថា **ម្ចាស់សហគ្រាស** ត្រូវទទួលបានការការពារទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួន ពីបំណុលនិងកាតព្វកិច្ចរបស់សហគ្រាស ។

ដំណើរការចុះបញ្ជីសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតត្រូវមានលក្ខខណ្ឌដូចជា៖

**១. នាមករណ៍របស់សហគ្រាស**: ឈ្មោះត្រូវតែមានអត្ថន័យត្រឹមត្រូវ និងមិនមានឈ្មោះដូច សហគ្រាសផ្សេងៗទៀតនៅក្នុងរដ្ឋ ។

**២.ការដាក់ស្នើអត្ថបទនៃការបង្កើត**: នេះជាឯកសារដែលត្រូវដាក់ស្នើទៅកាន់រដ្ឋ ដើម្បីបង្កើតសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ។ វាមានព័ត៌មានដូចជា ឈ្មោះសហគ្រាស អាសយដ្ឋាន និងព័ត៌មានអំពីសមាជិក ។

**៣.តែងតាំងភ្នាក់ងារដែលបានចុះបញ្ជី**: ភ្នាក់ងារនេះទទួលខុសត្រូវក្នុងការទទួលឯកសារច្បាប់សម្រាប់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ។

**៤.លក្ខន្តិកៈរបស់សហគ្រាស**: អ្នកអាចបង្កើតឯកសារនេះដើម្បីកំណត់វិធីដែល សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត នឹងដំណើរការ ។ វាមិនត្រូវការចុះបញ្ជីជាមួយរដ្ឋទេ ប៉ុន្តែវាមានសារៈសំខាន់ក្នុងការគ្រប់គ្រងសហគ្រាស។

**៦.ការទទួលបានអាជ្ញាប័ណ្ណនិងការអនុញ្ញាត**: អាស្រ័យលើប្រភេទអាជីវកម្ម អ្នកអាចត្រូវការអាជ្ញាប័ណ្ណបន្ថែម ។

**៦.ការបង់ថ្លៃចុះបញ្ជី**: មានថ្លៃដែលត្រូវបង់សម្រាប់ការចុះបញ្ជី សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ដែលអាស្រ័យលើរដ្ឋ ។

**កំណត់ចំណាំ៖** រាល់ដំណើរការនៃការចុះបញ្ជីរបស់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតនេះគឺមានលក្ខណៈខុសគ្នាអាស្រ័យលើប្រទេស ឬរដ្ឋដែលច្បាប់គោរពតាមប្រទេសនីមួយៗបានកំណត់ ។

## ២.៤ ការបញ្ចប់ ឬការរំលាយ

សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតក៏ត្រូវបានរំលាយ ឬត្រូវបានបញ្ចប់ទៅវិញផងដែរតាមការកំណត់ដូចខាងក្រោម៖

១.ការរំលាយ ឬការបញ្ចប់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ដោយមូលហេតុចិរវេលានៃសកម្មភាពរបស់សហគ្រាស មានន័យថា **សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត** ត្រូវបានកំណត់ចិរវេលាមិនឲ្យលើស៩៩ឆ្នាំ[24] ក្នុងការធ្វើសកម្មភាពអាជីវកម្ម ។ ហេតុនេះនៅពេលចិរវេលាកំណត់នេះបានមកដល់ក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិត គឺត្រូវរំលាយ ឬបញ្ចប់សកម្មភាពអាជីវកម្មរបស់សហគ្រាស ។

២.ការរំលាយ ឬការបញ្ចប់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ដោយមូលហេតុមរណៈភាពនៃម្ចាស់សហគ្រាស ។ ដូចបានជ្រាបខាងលើរួចមកហើយថា **សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត** គឺត្រូវបានគ្រប់គ្រង និងកាន់កាប់ភាគហ៊ុនទាំងអស់ដោយម្ចាស់តែម្នាក់ ហេតុនេះប្រសិនបើម្ចាស់សហគ្រាសទទួលមរណៈភាព ហើយមិនមានអ្នកចង់បន្តនូវសកម្មភាពអាជីវកម្មនោះបន្តទៀតទេ គឺនាំឲ្យសហគ្រាសនោះត្រូវបានរំលាយ ឬបញ្ចប់សកម្មភាពអាជីវកម្មរបស់ខ្លួន ។

៣.ការរំលាយ ឬការបញ្ចប់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតដោយមូលហេតុការសម្រេចពីតុលាការ ។ សេចក្តីសម្រេចពីតុលាការ ពីការរំលាយ ឬការបញ្ចប់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតក៏ជាមូលហេតុមួយផងដែរ ដែលនាំឲ្យសហគ្រាស ត្រូវបានរំលាយ ឬបញ្ចប់ ។ ដូចបានដឹងរួចមកហើយថាសហគ្រាសជានីតិបុគ្គល ដែលមានបុគ្គលភាពគតិយុត្តិពិតមែន ប៉ុន្តែក៏ត្រូវទទួលទោសទណ្ឌ តាមការសម្រេចពីតុលាការផងដែរ ដែលតម្រូវឲ្យសហគ្រាសនោះត្រូវតែអនុវត្តន៍តាម ។

៤.ការរំលាយ ឬការបញ្ចប់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ដោយមូលហេតុការសម្រេចបានតាមកម្មវត្ថុរបស់សហគ្រាស ។ កម្មវត្ថុរបស់សហគ្រាស គឺត្រូវបានកំណត់យ៉ាងជាក់ច្បាស់តាំងពីដំបូង ហេតុនេះហើយប្រសិនបើសហគ្រាសបានប្រព្រឹត្ត និងដំណើរការតាមកម្មវត្ថុនោះហើយសម្រេចបានតាមអ្វីដែលចង់បានពិតមែន នោះក៏ជាមូលហេតុមួយដែលម្ចាស់សហគ្រាសត្រូវគិតថា រំលាយ ឬការបញ្ចប់សហគ្រាសនោះ ។

[24] មាត្រា៦៦ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

# ផ្នែកទី២ ក្រុមហ៊ុនសហកម្មសិទ្ធិ

## ១.ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាក្រុមហ៊ុនមួយប្រភេទដែលត្រូវបានកំណត់ទម្រង់ តាមច្បាប់សហគ្រាសពាណិជ្ជកម្មកម្ពុជាឆ្នាំ២០០៥ នឹងត្រូវបានវិសោធនកម្មនៅឆ្នាំ២០២២ ដែលបានកំណត់សម្រាប់អាជីវករ ឬពាណិជ្ជករ ដែលមានបំណង ឬចំណង់ចំណូលចិត្តក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនេះ អាចយកមកពិភាក្សាគ្នាជាមួយក្រុម ឬភាគីពាក់ព័ន្ធដែលចង់ចូលរួមជាដើមទុនដែលមិនកំណត់ថាជាប្រាក់កាក់ ទីកន្លែង សេវាកម្ម ចំណេះដឹង ជាដើម ។ តែបើយើងក្រឡេកមកមើលពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនេះវិញ មិនសូវមានអាជីវករ ឬពាណិជ្ជករ ជ្រើសរើសយកមកបង្កើត ក៏ដូចជាយកមកធ្វើជាក្រុមហ៊ុនអាជីវកម្មរបស់ខ្លួននេះទេតើមានមូលហេតុ ឬផលវិបាកគតិយុត្តិ ឬបញ្ហាពាក់ព័ន្ធដែលស្មុគស្មាញអ្វីខ្លះ ទើបអាជីវករ ឬពាណិជ្ជករ មិនចង់បង្កើតក្រុមហ៊ុននេះឡើង ?

### ១.១ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

តាមនិយមន័យ៖ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាកិច្ចសន្យារវាងបុគ្គលពីរ ឬច្រើនដែលដាក់រួមគ្នានូវដើមទុនរួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬជាទីកន្លែង ដែលជាសកម្មភាពរបស់បុគ្គលទាំងនោះ ដែលមានឆន្ទៈ និង គោលបំណងដូចគ្នា ក្នុងការបង្កើតពាណិជ្ជកិច្ចនេះរួមគ្នាក្នុងគោលបំណងរកប្រាក់ចំណេញ[25] ។

#### ១.១.១ ការបង្កើតដោយកិច្ចសន្យា

កិច្ចសន្យាក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចត្រូវបានធ្វើឡើងជាទម្រង់លាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។ ប៉ុន្តែក្នុងករណីដែលកិច្ចសន្យាក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិករនេះត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ គឺតម្រូវឲ្យសហកម្មសិទ្ធិករទូទៅ ឬសមាជិកទាំងអស់ ចុះហត្ថលេខានៅលើកិច្ចសន្យានោះ[26] ។

#### ១.១.២ ការបង្កើតដោយតុលាការ

ក្នុងករណីកិច្ចសន្យាក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅខាងលើ មិនមានភាពច្បាស់លាស់ ឬមិនបានចែងគ្រប់ជ្រុងជ្រោយនោះទេ តុលាការ ត្រូវពិនិត្យ និងពិចារណាលើចំណុចសំខាន់ដូចខាងក្រោម៖

**ចំណុចទី១៖** ក្នុងករណីដែលបុគ្គលពីរ ឬច្រើននាក់កាន់កាប់ទ្រព្យសម្បត្តិរួមគ្នា ថាតើបុគ្គលនោះចែករំលែកប្រាក់ចំណេញដែលបានមកពីទ្រព្យនោះដែលឬទេ ? និងថាតើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ពិតជាបានកើតឡើងដោយសារទ្រព្យសម្បត្តិរួមដែរឬទេ ?

---

[25] មាត្រា៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ និងវិសោធនកម្មឆ្នាំ២០២១

[26] មាត្រា១០ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ និងវិសោធនកម្មឆ្នាំ២០២១

**ចំណុចទី២៖** ក្នុងករណីដែលបុគ្គលពីរ ឬច្រើនចែករំលែកប្រាក់ចំណូលដែលបានមកពីការធ្វើពាណិជ្ជកម្ម ថាតើបុគ្គលទាំងនោះ មានសិទ្ធិ ចូលរួមក្នុងទ្រព្យសម្បត្តិណាមួយដែលបង្កើតប្រាក់ចំណូលនោះដែរឬទេ ? ថាតើក្រុមហ៊ុនសហកម្មសិទ្ធិនោះកើតឡើងដោយសារទ្រព្យសម្បត្តិរួមពិតប្រាកដដែរឬទេ ? ប៉ុន្តែប្រសិនបើរកឃើញថាក្រុមហ៊ុនមិនបានបំពេញ តាមលក្ខខណ្ឌ ឬបែបបទត្រឹមត្រូវតាមច្បាប់ដែលកំណត់នោះទេ តុលាការអាចចេញសេចក្តីសម្រេចរំលាយក្រុមហ៊ុននោះបានដោយឆន្ទានុសិទ្ធិបាន ។

### ១.១.៣ នីតិបុគ្គលិកលក្ខណៈ សញ្ជាតិ និងនាមករណ៍

#### ១.១.៣.១ នីតិបុគ្គលិកលក្ខណៈ

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មាននីតិបុគ្គលិកលក្ខណៈចាប់ទាំងពីពេលដែលបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មរួចរាល់ហើយ ក្រុមហ៊ុននឹងទទួលបាននូវសិទ្ធិដូចជា៖

១.ក្លាយជាម្ចាស់លើអចលនវត្ថុ និងចលនវត្ថុដែលជាទ្រព្យរបស់ក្រុមហ៊ុន

២.ធ្វើពាណិជ្ជកិច្ចក្នុងនាមជាក្រុមហ៊ុន

៣.ធ្វើការចុះកិច្ចសន្យានានាក្នុងនាមជាក្រុមហ៊ុន និង

៤.ត្រូវបានគេប្តឹង ឬប្តឹងគេក្នុងមានជាក្រុមហ៊ុន

#### ១.១.៣.២ នាមករណ៍

នាមករណ៍ ឬឈ្មោះរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ពិតជាសំខាន់ដែលមិនអាចខ្វះបាននោះទេ ដែលសហគ្រាស ឬក្រុមហ៊ុនដែលធ្វើពាណិជ្ជកិច្ច ត្រូវតែមានឈ្មោះ ដើម្បីឲ្យសាធារណៈជនអាចធ្វើការសម្គាល់ ឬឲ្យសាធារណៈជនបានស្គាល់តាមរយៈនាមករណ៍របស់ខ្លួន ពិសេសជាងនេះទៅទៀតនាមករណ៍ ឬឈ្មោះនេះចាំបាច់ត្រូវតែគោរពតាមបទបញ្ញត្តិនៃច្បាប់ជាធរមានទើបម្ចាស់សហគ្រាស ឬកម្មសិទ្ធិករ អាចយកមកធ្វើជានាមករណ៍ ឬឈ្មោះ របស់សហគ្រាស ឬក្រុមហ៊ុនរបស់ខ្លួនបាន ។

គួរបញ្ជាក់ថា៖ **នាមករណ៍** ឬឈ្មោះរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវប្រើនាមករណ៍ជាភាសាខ្មែរ ហើយត្រូវដាក់ឲ្យមានទំហំធំជាងគេពីរដងនៃភាសាដទៃ ប្រសិនបើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះបានប្រើឈ្មោះជាភាសាដទៃមកដាក់ជានាមករណ៍បន្ថែមទៀត ។

សម្រាប់នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវដាក់បញ្ចូលនូវឈ្មោះរបស់សហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ត្រូវសរសេរដាក់នៅខាងក្រោយ ឬម្យ៉ាងទៀតនៅខាងក្រោមនាមករណ៍អាចធ្វើការដាក់ថា **ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ** ។ លើសពីនេះទៅទៀតនាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនត្រូវបានអនុញ្ញាតឲ្យយកទៅបកប្រែ ឬកែសម្រួលឲ្យមានភាពខុសពីឈ្មោះដើម ដោយធ្វើការបកប្រែពីភាសាមួយទៅភាសាមួយទេ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលមាននាមករណ៍ជាភាសាខ្មែរ ហើយមាននាមករណ៍ជាភាសាដទៃ

បន្ថែមពីទៀត នាមករណ៍ដែលជាភាសាដទៃនោះត្រូវតែមានសូរដូចទៅនឹងនាមករណ៍ដែលជាភាសាខ្មែរ ។ ការកំណត់នេះគឺគ្របដណ្តប់តែច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។ បន្ថែមពីនេះទៀត ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មិនអាចយកនាមករណ៍ ឬឈ្មោះថ្មីមកប្រើប្រាស់បានទេ អំឡុងពេលដែលកំពុងធ្វើពាណិជ្ជកិច្ច ។

**១.១.៣.៣ សញ្ជាតិ**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចត្រូវបានគេកំណត់សញ្ជាតិខ្មែរបានច្បាស់លាស់ និងមានភាពត្រឹមត្រូវលុះត្រាតែក្រុមហ៊ុននោះមានទីស្នាក់ការចុះបញ្ជី និងមានទីតាំងធ្វើអាជីវកម្មស្ថិតនៅព្រះរាជាណាចក្រកម្ពុជារួម និងអត្ថប្រយោជន៍ដែលកាន់កាប់ភាគហ៊ុនចាប់ពី៥១% ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។

**១.១.៤ ការចុះបញ្ជី និងការតម្កល់ទុកឯកសារ**

ក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ សមាជិកម្នាក់ៗត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីពាណិជ្ជកម្មការតម្កល់ឯកសារទុកឯកសារ និងការចុះផ្សាយដែលតម្រូវសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវរក្សាទុកជាឯកសារនូវសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយនៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ។ លើសពីនេះទៅទៀត ការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺតម្រូវតាមលក្ខខណ្ឌទម្រង់នៃការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

## ១.២ ភាគទុន

ភាគទុន ឬអាចហៅបានថា ដើមទុន ជាដើមហេតុដំបូងគេបង្អស់ដែលនាំឲ្យមានការបង្កើតសហគ្រាស ឬក្រុមហ៊ុនអាជីវកម្ម ហេតុនេះហើយគ្រប់ក្រុមហ៊ុនពាណិជ្ជកម្មដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរួចរាល់ហើយត្រូវធ្វើការបើកគណនីអាជីវកម្មរបស់ខ្លួនយ៉ាងហោចណាស់ឲ្យបានមួយ នៅធានាគារណាមួយក៏បាននៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ធ្វើការប្រតិបត្តិការហិរញ្ញវត្ថុរបស់ខ្លួន ។ លើសពីនេះទៅទៀតសហកម្មសិទ្ធិករម្នាក់ៗអាចធ្វើការដាក់ភាគហ៊ុនរបស់ខ្លួនដែលជាតម្រូវការរបស់ក្រុមហ៊ុន ដូចជា ជាប្រាក់ ជាវត្ថុ ជាទីកន្លែងជាសេវាកម្ម ឬជាចំណេះដឹងក៏ដោយ សុទ្ធសឹងត្រូវបានចាត់ទុកជាភាគទុនរបស់ក្រុមហ៊ុន ។ ហេតុនេះហើយមានការលើកឡើងជាច្រើនទាក់ទងនឹងភាគទុន បើការដាក់ភាគទុន ឬបញ្ចូលភាគទុនក្នុងការបង្កើតក្រុមហ៊ុនកម្មសិទ្ធិទូទៅមួយនេះមិនមានភាពស្មើគ្នាក្នុងការដាក់ភាគទុន ដោយកម្មសិទ្ធិករម្នាក់ៗ ថាតើពេលទទួលបានភាគលាភ ឬហៅថា **ប្រាក់ចំណេញ** ត្រូវបែងចែកគ្នាយ៉ាងដូចម្តេច ?

ហេតុនេះហើយភាគទុនក្រៅពីប្រាក់ មានន័យថាភាគទុនជាវត្ថុក្តី ភាគទុនជាសេវាក្តី ភាគទុនជាទីកន្លែងក្តី ឬ ជាចំណេះដឹងក្តី ត្រូវធ្វើការវាយតម្លៃឲ្យទៅប្រាក់ ដើម្បីដាក់បញ្ចូលក្នុងកិច្ចសន្យាក្រុមហ៊ុន ។ ភាគទុនប្រភេទនេះមិនត្រូវបានប្រកាសជាសាធារណៈមកប្រើប្រាស់បានឡើយ ។

### ១.២.១ ភាគទុនជាប្រាក់

ចំពោះសមាជិកក្រុមហ៊ុនណា ដែលបានដាក់ភាគទុនរបស់ខ្លួនជាសាច់ប្រាក់សមាជិកក្រុមហ៊ុននោះត្រូវមានកាតព្វកិច្ចបង់ប្រាក់នោះចូលទៅក្នុងគណនីរួមរបស់ក្រុមហ៊ុន ដែលជាគណនីត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះការបង់ប្រាក់របស់សមាជិកណាម្នាក់មានភាពយឺតយ៉ាវចូលទៅក្នុងគណនីរបស់ក្រុមហ៊ុនត្រូវទទួលរងពិន័យដែលជាទណ្ឌកម្មរបស់ក្រុមហ៊ុន តាមកិច្ចសន្យាដែលខ្លួនបានព្រមព្រៀងរួចហើយ ។

ក្នុងករណីដែលក្រុមហ៊ុនរបស់ខ្លួន ត្រូវបានក្ស័យធនដោយសារតែសមាជិកក្រុមហ៊ុនណាមួយ ឬច្រើននាក់មិនបានបង់ភាគទុនជាប្រាក់បានទាន់ពេលវេលាសមាជិកក្រុមហ៊ុនដែលយឺតយ៉ាវ និងខកខានទាំងនោះត្រូវសងការខូតខាតដល់ក្រុមហ៊ុនរបស់ខ្លួន ដោយរួមទាំងសំណងជំងឺចិត្តទៀត ។

### ១.២.២ ភាគទុនជាវត្ថុ

ក្រៅពីភាគទុនជាប្រាក់ដែលសមាជិកក្រុមហ៊ុន ឬសហកម្មសិទ្ធិករម្នាក់ៗ បានដាក់ជាភាគទុននៅក្នុងក្រុមហ៊ុន សមាជិកក្រុមហ៊ុន ឬសហកម្មសិទ្ធិករម្នាក់ៗ ក៏អាចដាក់ភាគទុនជាវត្ថុរបស់ខ្លួនក៏បានដែរ ដែលភាគទុនជាវត្ថុនេះសំដៅលើចលនវត្ថុទាំងពីរប្រភេទ គឺអចលនវត្ថុ និងចលនវត្ថុ ដែលជាតម្រូវការរបស់ក្រុមហ៊ុនតាមស្ថានភាពជាក់ស្តែង និងចាំបាច់ ។

ភាគទុនិក ឬភាគហ៊ុនិកអាចដាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនដែលជាវត្ថុនោះជាកម្មសិទ្ធិទាំងមូលជូនក្រុមហ៊ុន ឬអាចកំណត់សិទ្ធិណាមួយសម្រាប់ក្រុមហ៊ុនក៏បាន ដូចជាដាក់តែសិទ្ធិប្រើប្រាស់ និងអាស្រ័យផលជូនក្រុមហ៊ុនក៏បាន (ក្រុមហ៊ុនមិនអាចធ្វើការផ្ទេរកម្មសិទ្ធិបាននោះទេ)។ គួរបញ្ជាក់ផងដែរថាបើទោះបីជាភាគទុនិក ឬភាគហ៊ុនិកបានដាក់វត្ថុជាភាគទុករបស់ក្រុមហ៊ុនក៏ដោយ ក៏ភាគទុកដែលជាវត្ថុនោះ ត្រូវធ្វើការវាយតម្លៃជាសាច់ប្រាក់ ដើម្បីឲ្យសមស្របតាមការព្រមព្រៀងរបស់សមាជិកក្រុមហ៊ុនការកំណត់ ឬវាយតម្លៃជាតម្លៃបែបនេះធ្វើឲ្យមានភាពងាយស្រួលក្នុងការកំណត់ពីការទទួលខុសត្រូវរបស់ភាគទុនិកម្នាក់ៗនិងភាគលាភរបស់សមាជិកម្នាក់ៗ ។

### ១.២.៣ ភាគទុនជាសេវា

សមាជិកក្រុមហ៊ុន ឬភាគហ៊ុនិក អាចធ្វើការដាក់ភាគទុនជាសេវាកម្មរបស់ខ្លួនណាមួយក៏បានដែលជាតម្រូវការចាំបាច់របស់ក្រុមហ៊ុន ។

**ឧទាហរណ៍៖** ក្រុមហ៊ុន **ក** ចាំបាច់ត្រូវមានសេវាសម្រាប់ដឹកជញ្ជូនទំនិញសម្រាប់អតិថិជន ហេតុនេះហើយភាគហ៊ុនិក អាចដាក់រថយន្តរបស់ខ្លួនសម្រាប់បំពេញសេវាកម្មជូនអតិថិជន ដោយមិនចាំបាច់ដាក់កម្មសិទ្ធិទាំងមូលរបស់រថយន្ត ទៅឲ្យក្រុមហ៊ុននេះទេ ដាក់ត្រឹមសេវាកម្មជូនក្រុមហ៊ុនក៏បាន ប៉ុន្តែការបម្រើសេវាកម្មនេះក៏ត្រូវឲ្យមានការវាយតម្លៃ ជាទឹកប្រាក់ផងដែរ ។

### ១.២.៤ ភាគទុនជាចំណេះដឹង

ភាគហ៊ុននិក ឬភាគទុនិក ក៏អាចអាជ្រើសរើសភាគទុនក្រៅពីវត្ថុ ប្រាក់ ឬសេវាកម្មផ្សេងៗ តែយកចំណេះដឹងដែលខ្លួនមានមកដាក់ជាភាគទុនក៏បានមានន័យថា ការប្រើចំណេះដឹង បទពិសោធន៍ ដែលខ្លួនមានលើជំនាញចាំបាច់ណាមួយរបស់ក្រុមហ៊ុន ដូចជា គណនីករ ផ្នែកច្បាប់ ផ្នែកលក់ ដើម្បីបម្រើជូនក្រុមហ៊ុនជាដើម ។

លើសពីនេះការដាក់ភាគទុនជា ចំណេះដឹងនេះក៏តម្រូវឲ្យមានការវាយតម្លៃជាសាច់ប្រាក់ផង ។ ប៉ុន្តែការវាយតម្លៃជាចំណេះដឹង មិនមែនជាការងាយស្រួលនេះទេ ដោយហេតុថាមិនមានអ្វីអាចយកមកវាស់ស្ទង់ក៏ដូចជាអាចកំណត់បានច្បាស់ដូចវត្ថុ ឬសេវាកម្ម នោះទេ ។

បន្ទាប់ពីសហកម្មសិទ្ធិករទាំងអស់ បានដាក់បញ្ចូលទ្រព្យសម្បត្តិជាភាគទុនរួចរាល់ហើយសហកម្មសិទ្ធិករទាំងអស់ចាំបាច់ត្រូវធ្វើការផ្ទេរនូវកម្មសិទ្ធិនៃទ្រព្យសម្បត្តិទាំងនោះ មកជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ។ ដើមទុនរបស់ក្រុមហ៊ុន គឺមិនត្រូវបានរាប់បញ្ចូលនូវភាគទុនសេវាកម្ម ភាពទុនជាចំណេះដឹងនោះឡើយ ហើយដើមទុនទាំងអស់របស់ក្រុមហ៊ុនត្រូវបានគណនាជារូបិយវត្ថុជាតិរបស់កម្ពុជា (ប្រាក់រៀល) ។

សហកម្មសិទ្ធិករម្នាក់ មានសិទ្ធិក្នុងការទទួលបាននូវប្រាក់ចំណេញ និងការទទួលខុសត្រូវចំពោះការខាតបង់របស់ក្រុមហ៊ុន និងត្រូវរួមចំណែកទទួលខុសត្រូវជាមួយក្រុមហ៊ុន ដោយការទទួលខុសត្រូវនេះផ្អែកតាមសមាមាត្រនៃដើមទុនរបស់សហកម្មសិទ្ធិករម្នាក់ៗ ដែលមានកំណត់នៅក្នុងកិច្ចសន្យា ។

## ១.៣ ការប្រព្រឹត្តទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិ

### ១.៣.១ ទំនាក់ទំនងរវាងសហកម្មសិទ្ធិទូទៅ

ក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ គឺត្រូវកំណត់ និងតម្រូវឲ្យម្ចាស់កម្មសិទ្ធិម្នាក់ៗអាចបង់ភាគទុនជាសាច់ប្រាក់ វត្ថុ ឬសេវាពីមុនដែលបានផ្តល់រួចហើយយ៉ាងពិតប្រាកដ ឬជាការសន្យាថានឹងផ្តល់នូវសេវានាពេលអនាគត ។ នៅពេលសហកម្មសិទ្ធិករទូទៅបានទទួលការយល់ព្រមថាខ្លួនដាក់ទ្រព្យសម្បត្តិជាភាគទុន សហកម្មសិទ្ធិករទូទៅនោះត្រូវធ្វើការផ្ទេរកម្មសិទ្ធិពីម្ចាស់ ឬពីសិទ្ធិរបស់ខ្លួនមានលើទ្រព្យសម្បត្តិនោះ ទៅជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅវិញ ។ លើសពីនេះទៅទៀត យើងបានដឹងរួចមកហើយថា ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ មានភាគទុនជាសាច់ប្រាក់ និងជាវត្ថុ ហេតុនេះហើយភាគទុនជាវត្ថុ ត្រូវបានគេវាយតម្លៃជាសាច់ប្រាក់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ ដែលជាសមាជិកត្រូវទទួលស្គាល់ការវាយតម្លៃលើវត្ថុមកជាសាច់ប្រាក់នេះ[27] ។

[27] សៀវភៅនីតិសហគ្រាសពាណិជ្ជកម្ម រៀបរៀងដោយសាស្ត្រាចារ្យ ខាត់ ធី ទំព័រទី៥៥

បន្ថែមពីនេះទៀត ភាគទុនទាំងអស់របស់ក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ គឺមិនត្រូវបានរាប់បញ្ចូលនូវភាគទុនជាចំណេះដឹង ជាសេវា ឬជាសកម្មភាពនោះទេ ។ ចំណែកដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធទូទៅទាំងអស់ ត្រូវបានគណនាជារូបិយវត្ថុជាតិ ( កម្ពុជាមានរូបិយវត្ថុជាតិ គឺប្រាក់រៀល ) ។

### ១.៣.២ ការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

សហកម្មសិទ្ធិករទូទៅទាំងអស់ អាចតែងតាំងសហកម្មសិទ្ធិករម្នាក់ ឬច្រើននាក់ ឬបុគ្គលមិនមែនជាសហកម្មសិទ្ធិករទូទៅ ឲ្យទៅជាអ្នកគ្រប់គ្រងកិច្ចការជំនួសខ្លួននៅក្នុងក្រុមហ៊ុនបាន ។ កិច្ចការអ្នកគ្រប់គ្រងអាចអនុវត្តន៍រាល់សកម្មភាពនៅក្នុងសិទ្ធិអំណាចរបស់ខ្លួន ។ ប៉ុន្តែមិនត្រូវអនុវត្តន៍ឲ្យលើសពីសិទ្ធិអំណាចរបស់ខ្លួន ដូចជាការប្រព្រឹត្តអំពើក្លែងបន្លំជាដើម ។ លើសពីនេះទៅទៀតរាល់សកម្មភាពរបស់អ្នកគ្រប់គ្រង គឺត្រូវជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនជានិច្ច ។

អ្នកគ្រប់គ្រង ក៏ត្រូវបានដកហូតចេញពីតំណែងដោយសម្លេងភាគច្រើន សម្លេងភាគច្រើននេះត្រូវប្រៀបធៀបជាមួយវត្តមានរបស់សហកម្មសិទ្ធិទូទៅទាំងអស់នៅពេលបោះឆ្នោត ប៉ុន្តែករណីនេះក៏ត្រូវបានគេលើកលែងផងដែរ ប្រសិនបើនៅក្នុងកិច្ចសន្យារបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានចែងផ្សេងក្រៅពីនេះ ។

### ១.៣.៣ ទំនាក់ទំនងក្រុមហ៊ុនសហកម្មសិទ្ធិ ជាមួយនឹងតតិយជន

សហកម្មសិទ្ធិករទូទៅម្នាក់ៗ គឺជាភ្នាក់ងាររបស់ក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ លើសពីនេះនៅក្នុងទំនាក់ទំនងរបស់សហកម្មសិទ្ធិករជាមួយតតិយជន ដែលធ្វើទំនាក់ទំនងជាមួយខ្លួនដោយមានភាពស្មោះត្រង់ ហើយទំនាក់ទំនងរបស់សហកម្មសិទ្ធិករទាំងនោះ ត្រូវជាប់កាតព្វកិច្ចជាមួយក្រុមហ៊ុន រាល់សកម្មភាពដែលសហកម្មសិទ្ធិករណាម្នាក់បានអនុវត្តន៍ ។ សហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវមានកាតព្វកិច្ចរួមគ្នា និងកាតព្វកិច្ចដាច់ដោយឡែកពីគ្នានូវកាតព្វកិច្ចទាំងអស់របស់ក្រុមហ៊ុន ។ ចំណែកតតិយជនវិញ ត្រូវបានកំណត់ថាត្រូវទាមទារការអនុវត្តន៍កាតព្វកិច្ច បំណុល ឬទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនជាមុនសិន មុនពេលទៅទាមទារពីសហកម្មសិទ្ធិទូទៅ ។

បុគ្គលណាដែលបានចូលជាសហកម្មសិទ្ធិទូទៅ នៅក្រោយពេលដែលបំណុលបានកើតឡើង រួចហើយបុគ្គលនោះក៏ត្រូវទទួលខុសត្រូវលើបំណុលនោះផងដែរ ប៉ុន្តែករណីនេះកើតមានប្រសិនបើបំណុលនោះអាចត្រូវបានចេញសងតែលើទ្រព្យរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ តែមិនអាចយកទ្រព្យសម្បត្តិបុគ្គលនោះសងបានទេ លើកលែងតែគាត់ព្រមព្រៀងចំពោះការសងបំណុលនោះ ។

### ១.៣.៤ ការអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ

ការអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ ឬ ការបាត់បង់សិទ្ធិ ជាកម្មសិទ្ធករទូទៅ ជាចំណុចមួយដែលកម្មសិទ្ធិករទូទៅត្រូវដឹង និងត្រូវការស្វែងយល់ឲ្យបានច្បាស់ពីករណីនេះ ដោយមូលហេតុថា បុគ្គលជាកម្មសិទ្ធិករ

ទូទៅអាចបាត់បង់សិទ្ធិនេះដោយហេតុបណ្ដាលមកពីខ្លួនឯង ឬការកំណត់ពីក្រុមហ៊ុន ។

បុគ្គលម្នាក់នឹងត្រូវអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ[28] នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅប្រសិនបើមានករណីដូចខាងក្រោម ៖

- បានផ្ទេរផលប្រយោជន៍របស់ខ្លួន[29]
- ការទទួលមរណភាពរបស់កម្មសិទ្ធិករទូទៅណាម្នាក់
- ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យក្នុងពេលក្ស័យធន
- បានអនុវត្តសិទ្ធិដើម្បីដកខ្លួនចេញពីក្រុមហ៊ុន
- ត្រូវបានបណ្ដេញចេញពីក្រុមហ៊ុន[30]
- បានទទួលសាលក្រមតុលាការអនុញ្ញាតឲ្យដកខ្លួនចេញ ឬបញ្ជាឲ្យរឹបអូសអត្ថប្រយោជន៍បុគ្គលនោះ

## ១.៤.ការរំលាយ និងការជម្រះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

### ១.៤.១ ការរំលាយ ឬការបញ្ចប់ នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

ក្រុមហ៊ុនកម្មសិទ្ធិករទូទៅ នៅក្នុងការរំលាយគឺមិនខុសពីការរំលាយក្រុមហ៊ុន ឬសហគ្រាសផ្សេងនោះទេ ការរំលាយត្រូវបានកំណត់មូលហេតុធំៗចំនួនពីរ៖

#### ១.៤.១.១ មូលហេតុដែលមានចែងក្នុងកិច្ចសន្យា

នៅក្នុងកិច្ចសន្យារបស់ក្រុមហ៊ុន បានកំណត់អំពីគោលបំណងនៃអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់ ឬគ្មានលទ្ធភាពក្នុងការបន្តអាជីវកម្មរបស់ខ្លួនបាន និងមានការព្រមព្រៀងគ្នាជាឯកច្ឆ័នក្នុងការរំលាយក្រុមហ៊ុននេះដោយសហកម្មសិទ្ធិករទាំងអស់ ដែលជាម្ចាស់ភាគហ៊ុនិក សរុបមកវិញយើងឃើញមានចំណុចសំខាន់០៣ (បី)ដែលក្រុមហ៊ុនត្រូវបានរំលាយតាមកិច្ចសន្យានោះគឺ៖

- ចំណុចទី១ គោលបំណងនៃការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់
- ចំណុចទី២ ក្រុមហ៊ុនគ្មានលទ្ធភាព ឬធនធានក្នុងការបន្តអាជីវកម្មបានទៀត
- ចំណុចទី៣ ការព្រមព្រៀងជាឯកច្ឆ័នរបស់សហកម្មសិទ្ធិករទូទៅដែលត្រូវជាម្ចាស់ភាគហ៊ុន

#### ១.៤.១.២ ការរំលាយក្រុមហ៊ុនដោយតុលាការ

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបានរំលាយដោយមូលហេតុស្របច្បាប់របស់តុលាការ ។ នៅពេលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានរំលាយពីតុលាការ ក្រុមហ៊ុននោះអាចត្រូវធ្វើការជម្រះបញ្ជីបាន ប៉ុន្តែប្រសិនបើ

[28] មាត្រា៤៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[29] មាត្រា៣២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[30] មាត្រា៥២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនេះបង្កើតឡើងដោយមានការកំណត់ អាចត្រូវបានបន្តអាជីវកម្មរបស់ខ្លួនបានដោយការយល់ព្រមគ្នាជាឯកច្ឆ័នរបស់សហកម្មសិទ្ធិករទាំងអស់ ។

### ១.៤.២ សិទ្ធិរបស់កម្មសិទ្ធិករនៅពេលរំលាយ

សិទ្ធិរបស់សហកម្មកម្មសិទ្ធិករ ដែលត្រូវជាម្ចាស់ភាគហ៊ុនិកត្រូវបានបញ្ចប់នៅពេលដែលក្រុមហ៊ុនត្រូវបានរំលាយ ( ការរំលាយមានពីរករណី ) លើកលែងតែសកម្មភាពទាំងឡាយណាដែលជាផលវិបាកដែលកើតចេញពីពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនដែលមិនទាន់បានបំពេញចប់សព្វគ្រប់ ។ ប៉ុន្តែក៏មានករណីមួយចំនួនដែលកើតមានចំពោះកម្មសិទ្ធិករផងដែរនោះគឺការមិនបានដឹងពីការរំលាយរបស់ក្រុមហ៊ុន ហើយបានបន្តធ្វើពាណិជ្ជកិច្ចរបស់ខ្លួនជាធម្មតា ហេតុនេះហើយនាំឲ្យសកម្មភាពដែលជាពាណិជ្ជកិច្ចនោះ ត្រូវបានជាប់កាតព្វកិច្ចដល់ក្រុមហ៊ុននិងសហកម្មសិទ្ធិករទាំងអស់ ។

### ១.៤.៣ សិទ្ធិរបស់តតិយជនពេលរំលាយ

ចំពោះតតិយជនវិញ នៅពេលក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅត្រូវបានរំលាយ គឺមិនមានអ្វីប៉ះពាល់ ឬកើតជាផលវិបាកទៅនឹងសិទ្ធិរបស់តតិយជន ឬភ្នាក់ងារណាម្នាក់របស់ក្រុមហ៊ុនដែលធ្វើសកម្មភាពក្នុងនាមជាក្រុមហ៊ុននោះទេ ក្នុងករណីដែលបុគ្គលនោះបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនដោយភាពស្មោះត្រង់ ។

### ១.៤.៤ នីតិវិធីនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺមាននីតិបុគ្គលិកលក្ខណៈ រហូតដល់ពេលចប់នៃការជម្រះបញ្ជីរបស់ក្រុមហ៊ុន ។ សហកម្មសិទ្ធិករទូទៅត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុន និងត្រូវចាត់តាំងអ្នកជម្រះបញ្ជី ?

## ២.ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

### ២.១ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត គឺជាប្រភេទក្រុមហ៊ុនដែលត្រូវបានបែងចែកចេញពីក្រុមហ៊ុនសហកម្មសិទ្ធិ ដែលមានក្រុមហ៊ុនសហកម្មសិទ្ធិទូទៅផង និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតផងដែរ ។ យើងបានដឹងរួចមកហើយថាក្រុមហ៊ុនទាំងពីរមានត្រកូលដូចគ្នា គឺក្រុមហ៊ុនសហកម្មសិទ្ធិ ហេតុនេះហើយការបង្កើតក៏ដូចជាដំណើរការផ្សេងៗគឺមានភាពមិនខុសគ្នានោះទេ គឺមានភាពស្រដៀងគ្នាស្ទើរទាំងស្រុង ប៉ុន្តែមានចំណុចចំនួន០៣(បី)ដែលត្រូវកំណត់សម្គាល់ពីភាពខុសគ្នារវាងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតថាតើចំណុចទាំង០៣(បី)ដែលគួរកត់សម្គាល់នោះមានអ្វីខ្លះ? ជាបន្តមកទៀតនេះ យើងនឹងទៅដឹងទាំងអស់គ្នាពីចំណុចដែលមានភាពខុសគ្នានោះ និងអ្នកសិក្សាស្វែងយល់គួរយកចិត្តទុកដាក់ និងពិចារណាថា ចំណុចទាំង០៣(បី)នោះខុសគ្នាដែរទេ ?

### ២.១.១ និយមន័យ និងលក្ខណៈនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

#### ២.១.១.១ និយមន័យ

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត[31] គឺជាកិច្ចសន្យាដែលធ្វើឡើងរវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ដែលមានបុគ្គលម្នាក់ ត្រូវបានអនុញ្ញាតឲ្យគ្រប់គ្រងនិងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតម្នាក់ ឬច្រើននាក់ដែលមានកាតព្វកិច្ចបង់ភាគទុននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះ ។

#### ២.១.១.២ លក្ខណៈនៃសមាជិក

ហេតុអ្វីត្រូវនិយាយពីលក្ខណៈនៃសមាជិករបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត? ថាតើឋានៈរបស់សហកម្មសិទ្ធិករមានកម្រិតមានភាពខុសគ្នាពីសហកម្មសិទ្ធិករទូទៅដែរឬយ៉ាងណា?

លក្ខណៈនៃសហកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មានភាពខុសគ្នាពីសហកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដោយមូលហេតុថា សហកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មានឋានៈពីរ គឺជាសហកម្មសិទ្ធិករទូទៅផង និងជាសហកម្មសិទ្ធិករមានកម្រិតផង បន្ថែមលើនេះទៀត បុគ្គលប្រភេទនេះត្រូវមានសិទ្ធិ និងកាតព្វកិច្ចជាសហកម្មសិទ្ធិករទូទៅ[32] ។ ប៉ុន្តែនៅបណ្តាលប្រទេសមួយចំនួនក៏មិនបានឯកភាពនឹងឲ្យបុគ្គលម្នាក់មានឋានៈពីរក្នុងពេលតែមួយបានដែរ ដូចជាប្រទេសអង់គ្លេសមិនបានទទួលស្គាល់ឋានៈពីរក្នុងពេលតែមួយនៃសហកម្មសិទ្ធិករនេះទេ ហើយក៏មានប្រទេសមួយចំនួនទៀតក៏បានបដិសេធមិនទទួលស្គាល់ផងដែរ ។

### ២.១.២ ការបង្កើត

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ក៏មិនខុសពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅប៉ុន្មានដែរ ដោយកើតឡើងតាមកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ តែងអត្ថិភាព[33] នៃក្រុមហ៊ុននេះត្រូវប្រកាសជាសាធារណៈ (តាមរយៈការចុះបញ្ជី) ដោយមានមូលហេតុថាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនេះ គឺមានសហកម្មសិទ្ធិករខ្លះទទួលខុសត្រូវត្រឹមភាគទុនវិនិយោគរបស់ខ្លួន ។

ការប្រកាសជាសាធារណៈនេះ ជាការដាស់តឿនឲ្យបានដឹងថា សហកម្មសិទ្ធិករណាមួយមានការទទួលខុសត្រូវគ្មានកម្រិត និងសហកម្មសិទ្ធិករណាខ្លះមានការទទួលខុសត្រូវមានកម្រិត ។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ដាច់ខាតត្រូវតែចុះបញ្ជី ប្រសិនបើមិនបានចុះបញ្ជីបានត្រឹមត្រូវស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មនោះទេ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត នឹងមិនទទួលបាននីតិបុគ្គលភាពគតិយុត្តតាមផ្លូវ

[31] មាត្រា ៦៤ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[32] មាត្រា៦៥ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[33] អត្ថិភាព មានន័យថា ភាវៈមាន ភាពមាននៃអ្វីមួយ យោងតាមវចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត

ច្បាប់នោះទេ ។ ហើយបើក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនេះមិនបានចុះបញ្ជីនោះទេ គឺត្រូវបានចាត់ទុក ឬសន្មត់ថាជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។ ហេតុនេះសហកម្មសិទ្ធិករទាំងទូទៅ និងមានកម្រិតត្រូវទទួលខុសត្រូវមិនមានកំណត់ ។

### ២.១.៣ នាមករណ៍

នាមករណ៍ ឬហៅសាមញ្ញថាឈ្មោះ របស់ក្រុមហ៊ុនសហកម្មសិទ្ធមានកម្រិតត្រូវបញ្ចូលឈ្មោះសហកម្មសិទ្ធិករទូទៅណាម្នាក់ ឬច្រើននាក់ហើយនៅខាងក្រោម ឬខាងក្រោយត្រូវដាក់ពាក្យថា “ **ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត** ” សហកម្មសិទ្ធិករមានកម្រិតណាម្នាក់ដែលមានឈ្មោះនៅក្នុងនាមករណ៍របស់ក្រុមហ៊ុន ត្រូវមានកាតព្វកិច្ចដូចគ្នានិងសហកម្មសិទ្ធិករទូទៅផងដែរ ប៉ុន្តែមានករណីលើកលែងខ្លះប្រសិនបើមានចែងនៅក្នុងកិច្ចសន្យារបស់ក្រុមហ៊ុន ។

### ២.១.៤ ការបង់ភាគហ៊ុន

នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិករមានកម្រិត ភាពទុនរបស់សហកម្មសិទ្ធិករមានកម្រិត គឺអាចមានជាទឹកប្រាក់ ឬទ្រព្យសម្បត្តិតែប៉ុណ្ណោះ ។ ហេតុអ្វីបានសហកម្មសិទ្ធិករមានកម្រិត អាចដាក់ទុនបានតែទឹកប្រាក់ និងទ្រព្យសម្បត្តិ ?

ការដែលនាំឲ្យសហកម្មសិទ្ធិករអាចដាក់បានតែទឹកប្រាក់ និងទ្រព្យសម្បត្រិ និងមិនអាចដាក់អ្វីដទៃទៀតបានដូចសហកម្មសិទ្ធិករទូទៅបាន គឺមានការលើកឡើងថាមកពីពួកគេជាអ្នកវិនិយោគទុន ការបង់ភាគទុននៃសហកម្មសិទ្ធិករមានកម្រិតនេះ អាចធ្វើបានតែការបង់ភាគទុនជាសាច់ប្រាក់ ឬជាវត្ថុតែប៉ុណ្ណោះ[34] ។ ការបង់ជាវត្ថុត្រូវបានគណនាជាសាច់ប្រាក់ដូចគ្នាក្នុងករណីសហកម្មសិទ្ធិករទូទៅដែរ ។

ក្រៅពីការកំណត់ នូវប្រភេទភាគទុនសម្រាប់សហកម្មសិទ្ធិករទាំងពីរ នៅក្នុងនោះដែរក៏មានការកំណត់ពីទំហំនៃភាគទុនរបស់សហកម្មសិទ្ធិករទាំងពីរបន្ថែមទៀត គឺភាគទុនរបស់សហកម្មសិទ្ធិករមានកម្រិតក៏ត្រូវបានកំណត់មិនឲ្យលើសពី ភាគទុនរបស់សហកម្មសិទ្ធិករទូទៅនោះទេ ។ ប៉ុន្តែនៅក្នុងច្បាប់ជាធរមាន គឺមិនបានកំណត់ច្បាស់លាស់ពីចំនួននៃភាគទុនរបស់សហកម្មសិទ្ធិករទាំងពីរឲ្យបានច្បាស់នោះទេ គ្រាន់តែឲ្យជាគោលការណ៍ប៉ុណ្ណោះ ។

[34] មាត្រា៧០ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

## ២.២ ការប្រព្រឹត្តិទៅ នៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

### ២.២.១ សិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករទូទៅ

សិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករទូទៅ គឺដូចគ្នានឹងសិទ្ធិ និងករណីកិច្ចរបស់សហកម្មសិទ្ធិករទូទៅនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ។ សហកម្មសិទ្ធិករទូទៅ ត្រូវរាយការណ៍ពីការគ្រប់គ្រងជូនទៅសហកម្មសិទ្ធិករមានកម្រិតទាំងឡាយ[35] ។ សហកម្មសិទ្ធិករទូទៅត្រូវទទួលខុសត្រូវរួម និង ដាច់ដោយឡែកពីគ្នានូវបំណុលទាំងឡាយណារបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ចំពោះតតិយជន[36] ។ លើសពីនេះទៀតសហកម្មសិទ្ធិទូទៅមានកាតព្វកិច្ចទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិរបស់សហកម្មសិទ្ធិករមានកម្រិត ដែលមាននៅក្នុងដើមទុនរបស់ក្រុមហ៊ុន ហើយចំណុចនេះគឺ កិច្ចសន្យារបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនអាចជៀសវៀងកាតព្វកិច្ចនេះបានជាដាច់ខាត ។

### ២.២.២ សិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករមានកម្រិត

សហកម្មសិទ្ធករមានកម្រិត គឺមានសិទ្ធិ និងកាតព្វកិច្ច ទទួលនូវចំណែកនៃប្រាកចំណេញ ឬហៅថាភាគលាភរបស់ខ្លួន ប៉ុន្តែប្រសិនបើប្រាក់ចំណេញនោះ បង្កឲ្យក្រុមហ៊ុនមានឱនភាពដល់ដំណើរការរបស់ក្រុមហ៊ុននោះសហកម្មសិទ្ធិករមានកម្រិតទាំងអស់ ត្រូវបង្វិលប្រាក់ចំណេញនោះមកឲ្យក្រុមហ៊ុនវិញ ។

ម្យ៉ាងទៀតនៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវបានបង្កើតឡើងហើយ សហកម្មសិទ្ធិករមានកម្រិត មិនអាចដកចំណែកណាមួយនៃភាគទុនរបស់ខ្លួនបានឡើយ លើកលែងតែការដកនោះមិនប៉ះពាល់ដល់សមត្ថភាពរបស់ក្រុមហ៊ុន ក្នុងការដោះបំណុល និងត្រូវមានការយល់ព្រមពីសម្លេងភាគច្រើនដាច់ខាតពីសហកម្មករទាំងអស់[37] ។ សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗ ក៏អាចធ្វើការផ្ទេរអត្ថប្រយោជន៍របស់ខ្លួន ដែលមាននៅក្នុងក្រុមហ៊ុនដោយពុំចាំបាច់មានការយល់ព្រមជាឯកច្ឆន្ទៈពីសហកម្មសិទ្ធិករដទៃទៀតឡើយ[38] ។

លើសពីនេះទៀត សហកម្មសិទ្ធិករមានកម្រិត គ្រាន់តែជាអ្នកវិនិយោគ ដើម្បីទទួលបានប្រាក់ចំណេញតែប៉ុណ្ណោះ ហេតុនេះហើយ សហកម្មសិទ្ធិករម្នាក់ៗ មិនមានសិទ្ធិចូលរួមក្នុងការចាត់ចែងក្រុមហ៊ុននោះទេ ការងារគ្រប់គ្រងក្រុមហ៊ុនទាំងអស់ គឺសហកម្មសិទ្ធិករទូទៅ ជាអ្នកគ្រប់គ្រងទាំងស្រុង ប៉ុន្តែប្រសិនបើសហកម្មសិទ្ធិករមានកម្រិត ដែលបានចូលរួមតួនាទីគ្រប់គ្រងណាមួយ ដែលជាសមត្ថកិច្ចរបស់សហកម្មសិទ្ធិករទូទៅ ត្រូវចាត់ទុកថាបានបោះបង់ឋានៈជាអ្នកទទួលខុសត្រូវមានកម្រិត ទាក់ទងជាមួយការងារដែលកម្មសិទ្ធិករនោះធ្វើ ។

---

[35] មាត្រា៧៤ ច្បាប់ស្តីពីសហគ្រាសពណិជ្ជកម្ម ឆ្នាំ២០០៥

[36] មាត្រា ៧៤ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[37] យោងតាមសៀវភៅ នីតិក្រុមហ៊ុន បោះពុម្ពលើកទី៣ ឆ្នាំ២០២៤ រៀបចំដោយ មេធាវី កង ស៊ីផាន់ណារ៉ា ទំព័រ៩៣ និង៩៤

[38] យោងតាមសៀវភៅ នីតិសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០២៣ រៀបចំដោយសាស្ត្រាចារ្យ ខាត់ ធី ទំព័រ៦៥

**ដើម្បីជាអំណោះអំណាង៖** សហកម្មសិទ្ធិករមានកម្រិតម្នាក់ឈ្មោះ **ធីតា** បានទៅចុះហត្ថលេខាខ្ចីប្រាក់ពីធនាគារក្នុងនាមជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតឈ្មោះ **ធីតា** នោះត្រូវទទួលខុសត្រូវចំពោះបំណុលមួយនោះប៉ុន្តែ **ធីតា** មិនបានក្លាយខ្លួនជាសហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុន ហើយត្រូវជាប់កាតព្វកិច្ចចំពោះបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនឡើយ ។

## ២.៣ ការរំលាយ ឬការបញ្ចប់នៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

សហកម្មសិទ្ធិករទូទៅ គឺជាអ្នកគ្រប់គ្រងផ្នែករដ្ឋបាលដែលជាការងារស្នូលដល់សំខាន់របស់ក្រុមហ៊ុន ប៉ុន្តែប្រសិនបើសហកម្មសិទ្ធិទូទៅមិនអាចបំពេញការងារពាណិជ្ជកម្មរបស់ក្រុមហ៊ុនបន្តទៅទៀតបានទេ សហកម្មសិទ្ធិករមានកម្រិតអាចបំពេញការងារទាំងនោះជំនួសសហកម្មសិទ្ធិករទូទៅ ដើម្បីឲ្យក្រុមហ៊ុនអាចបន្តពាណិជ្ជកម្មរបស់ខ្លួនបាន ។ ប៉ុន្តែក្នុងករណីដែលសហកម្មសិទ្ធិករទូទៅទាំងអស់មិនត្រូវបានជំនួសនៅក្នុងរយៈពេល១២០ថ្ងៃនោះទេ ក្រុមហ៊ុនសហកម្មសិទ្ធិករមានកម្រិតនឹងត្រូវបានរំលាយ ។ ម្យ៉ាងទៀតយើងបានដឹងរួចមកហើយថាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមានអាយុកាល និងល័ក្ខខ័ណ្ឌមួយទៀតដែលនាំឲ្យក្រុមហ៊ុនត្រូវបានរំលាយ ល័ក្ខខ័ណ្ឌនោះរួមមាន៖

- ការមិនស្នើសុំបន្តរបស់ក្រុមហ៊ុន នៅពេលកំណត់៩៩ឆ្នាំ
- ការជម្រះបញ្ជីតាមផ្លូវតុលាការនៅពេលក្ស័យធន
- តាមរយៈការសម្រេចរបស់សមាជិកភាគហ៊ុន
- ការរំលាយដោយតុលាការក្នុងករណីបំពានលើកម្មវត្ថុអាជីវកម្មដោយប្រព្រឹត្តខុសច្បាប់
- មរណៈភាពរបស់សហកម្មសិទ្ធិករណាម្នាក់ ។

**កំណត់ចំណាំ៖** មានការសម្គាល់ថាសហកម្មសិទ្ធិករមានកម្រិត ជាវិនិយោគទុន ឬអាចហៅថាជាអ្នកជំនួញ ហើយសហកម្មសិទ្ធិករទូទៅ ជាអ្នកប្រតិបត្តិ ឬហៅថាជាក្បាលម៉ាស៊ីនរបស់ក្រុមហ៊ុន ដែលសហកម្មករមានកម្រិតមិនអាចជំនួសការងាររបស់សហកម្មសិទ្ធិករទូទៅបានទេ ប្រសិនបើសហកម្មសិទ្ធិករទូទៅអាចដឹកនាំ និងបន្តពាណិជ្ជកម្មរបស់ក្រុមហ៊ុនបានល្អ ហេតុនេះសហកម្មករទូទៅជាមនុស្សសំខាន់ដែលក្រុមហ៊ុនមិនអាចខ្វះបាន និងដកចេញបានភ្លាមៗនោះទេ ហេតុនេះនៅក្នុងមាត្រា៤៨ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ បានកំណត់ពី ការអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ បានកំណត់យ៉ាងច្បាស់ពីល័ក្ខខ័ណ្ឌនេះថា បុគ្គលណាមួយអស់សិទ្ធិជា សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនៅពេលបុគ្គលនោះ៖

- បានផ្ទេរផលប្រយោជន៍របស់ខ្លួន
- បានទទួលមរណភាព
- ត្រូវបានដាក់ក្រោមការពិនិត្យអង្កេតពេលក្ស័យធន

- បានអនុវត្តន៍សិទ្ធិដើម្បីដកខ្លួនចេញ
- ត្រូវបានបណ្តេញចេញពីក្រុមហ៊ុន
- បានទទួលសាលក្រមតុលាការអនុញ្ញាតឲ្យដកខ្លួនចេញ ឬបញ្ជាឲ្យរឹបអូសអត្ថប្រយោជន៍របស់បុគ្គលនោះ ។

ហេតុនេះហើយពេលបុគ្គលណាម្នាក់ដែលអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនៅក្នុងក្រុមហ៊ុន គឺបង្កឲ្យមានការរំលាយជាស្វ័យប្រវត្តិនូវក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ប្រសិនបើកិច្ចសន្យារបស់ក្រុមហ៊ុនមិនបានចែងពីចំណុចនេះទេ (ការអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ) ។ ប៉ុន្តែប្រសិនបើក្រុមហ៊ុនចង់បន្តដំណើរការពាណិជ្ជកម្មរបស់ខ្លួនបន្តទៀត អាចបន្តបានដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ និងតម្រូវឲ្យអនុវត្តន៍តាមលក្ខខណ្ឌនៃការតម្កល់ និងការចុះបញ្ជីដើម្បីបង្ហាញពីការកែប្រែនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

## ផ្នែកទី៣ ក្រុមហ៊ុនមូលធន

តាមច្បាប់សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥[39] បានកំណត់ថាក្រុមហ៊ុនមូលធនមានពីរប្រភេទ ឬពីរកម្រិត គឺក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ។

### ១.ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

### ១.១ ការបង្កើត

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត គឺជាទម្រង់មួយនៃក្រុមហ៊ុនមូលធន ហើយត្រូវមានលក្ខណៈសម្គាល់ដូចជា៖

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចមានសមាជិកភាគហ៊ុនពី០២(ពីរ)នាក់រហូតដល់៣០(សាមសិប)នាក់ ។ ប៉ុន្តែបុគ្គលម្នាក់ក៏អាចបង្កើតក្រុមហ៊ុនបានដែរ តែជាប្រភេទសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតវិញ ។

ជាទូទៅយើងបានឃើញថាសម្រាប់ក្រុមហ៊ុនមូលធន អាចមាននីតិបុគ្គល ឬរូបវន្តបុគ្គលមួយ ឬច្រើនដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ គឺអាចបង្កើតក្រុមហ៊ុនមូលនេះបានហើយ ប៉ុន្តែត្រូវបំពេញលក្ខខណ្ឌស្របតាមបញ្ញត្តិច្បាប់ដែលបានកំណត់ថែមទៀតប៉ុណ្ណោះ ។ យើងសង្កេតឃើញថា ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលបានបង្កើតឡើងក្រោមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ គឺមិនត្រូវបានអនុញ្ញាតឲ្យធ្វើអាជីវកម្មលើផ្នែកមួយចំនួនដូចជា ផ្នែកធនាគារ ផ្នែកធានារ៉ាប់រង និងក្រុមហ៊ុនឥណទាន

[39] មាត្រា៨៥ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

បានឡើយ[40] ។ ដូច្នេះហើយយើងនឹងទៅសិក្សាពីលក្ខខណ្ឌនានាដែលច្បាប់តម្រូវឲ្យបំពេញដើម្បីក្លាយជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ។

### ១.១.១ សមត្ថភាព និងដើមទុន

#### ១.១.១.១ សមត្ថភាព

សមត្ថភាពរបស់សមាជិកភាគហ៊ុន នៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត គឺមិនតម្រូវឲ្យសមាជិភាពហ៊ុននោះ ជាពាណិជ្ជករនោះទេ ប៉ុន្តែសមាជិកភាគហ៊ុននោះត្រូវតែមានសមត្ថភាពខាងរដ្ឋប្បវេណី មានន័យថា សមាជិកភាគហ៊ុនទាំងនោះត្រូវតែមានសមត្ថភាពដែលបានកំណត់តាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដែលសមាជិកភាគហ៊ុននោះមិនត្រូវជាគំហាតជន ឬអនីតិជនឡើយ ។

#### ១.១.១.២ ភាគទុន ឬដើមទុន

យើងបានដឹងរួចមកហើយថាភាគទុន ឬដើមទុននេះសមាជិកភាគហ៊ុនទាំងអស់អាចដាក់បានច្រើនប្រភេទដូចជា ប្រាក់ វត្ថុ សេវាកម្ម ចំណេះដឹង ...។ ប៉ុន្តែក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបានកំណត់យ៉ាងច្បាស់ពីប្រភេទភាគហ៊ុនដែលសមាជិកភាគហ៊ុនម្នាក់ៗ អាចដាក់បានគឺមានតែ ភាគហ៊ុនជាប្រាក់ ជាវត្ថុ និងចំណេះដឹងលើកលែងតែភាគហ៊ុនជាសេវាដែលមិនត្រូវបានអនុញ្ញាតឲ្យដាក់បញ្ចូលតែប៉ុណ្ណោះ ក្រៅពីនេះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចដាក់បញ្ចូលបាន ប៉ុន្តែក្រៅពីភាគហ៊ុនជាប្រាក់ ក៏មិនបានកំណត់ពីទំហំច្បាស់លាស់ណាមួយដែរ ថាតម្រូវឲ្យមានប៉ុន្មានភាគរយលើភាគហ៊ុនសរុបរបស់ក្រុមហ៊ុននោះឡើយ ។

សមាជិកភាគទុនម្នាក់ៗ តម្រូវឲ្យផ្ទេរនូវកម្មសិទ្ធិ ឬសិទ្ធប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួនទៅឲ្យក្រុមហ៊ុនរបស់ខ្លួន ដើម្បីទទួលបានមកវិញនូវចំណែកភាគហ៊ុនដែលខ្លួនទទួលខុសត្រូវ ។ មានន័យថា ខ្លួនមិនមានសិទ្ធិលើទ្រព្យសម្បត្តិរបស់ខ្លួនទៀតទេ ព្រោះទ្រព្យសម្បត្តិទាំងនោះនឹងក្លាយជាទ្រព្យអវិភាគ[41]របស់ក្រុមហ៊ុន ។

**ចំពោះភាគហ៊ុនជាប្រាក់** ដែលសមាជិកភាគហ៊ុន បានសន្យានៅក្នុងកិច្ចសន្យាក្រុមហ៊ុនរួចមកហើយថាតើថាខ្លួនបានដាក់ភាគហ៊ុននោះជាសាច់ប្រាក់សមាជិកភាគហ៊ុននោះត្រូវមានកាតព្វកិច្ចបង់ជាប្រាក់ជូនក្រុមហ៊ុនដោយធ្វើការផ្ទេរចូលទៅកាន់គណនីរួមរបស់ក្រុមហ៊ុន ដែលក្រុមហ៊ុនបានបង្កើតឡើង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយភាគហ៊ុនជាសាច់ប្រាក់នោះ នឹងក្លាយជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។ ប្រសិនបើសមាជិកភាគហ៊ុនណាម្នាក់បានខកខានមិនបានបង់ប្រាក់ជូនក្រុមហ៊ុនបានទាន់ពេលវេលា ឬកាលកំណត់នោះទេសមាជិកភាគហ៊ុននឹងត្រូវទទួលរងនូវទណ្ឌកម្មខាងវិន័យតាមការកំណត់របស់ក្រុមហ៊ុន ។

---

[40] មាត្រា៨៥ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[41] ***ទ្រព្យអវិភាគ ឬកម្មសិទ្ធិអវិភាគ*** គឺសំដៅលើសិទ្ធិលើកម្មសិទ្ធិលើវត្ថុ ដែលកម្មសិទ្ធិករច្រើននាក់មាននៅលើវត្ថុតែមួយ ដែលមិនអាចបំបែកបាន ។

**ចំពោះភាគហ៊ុនជាវត្ថុ** សមាជិកក្រុមហ៊ុនអាចធ្វើការដាក់នូវភាគទុនរបស់ខ្លួនជាវត្ថុក៏បាន ទោះបីវាជាចលនវត្ថុក្តី ឬអចលនវត្ថុក្តី ប៉ុន្តែឲ្យតែជាតម្រូវការរបស់ក្រុមហ៊ុនសមាជិកភាគហ៊ុននោះអាចធ្វើការដាក់ជាភាគទុនបាន ។ ហេតុនេះហើយភាគទុនិកអាចដាក់នូវទ្រព្យរបស់ខ្លួនដែលជាវត្ថុនោះ ជាកម្មសិទ្ធិទាំងមូលក៏បាន ឬត្រឹមកម្រិតណាមួយក៏បាន ប៉ុន្តែភាគទុនជាវត្ថុនេះត្រូវវាយតម្លៃជាសាច់ប្រាក់ និងតាមការព្រមព្រៀង ។

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត តាមច្បាប់កំណត់មិនត្រូវបានអនុញ្ញាតឲ្យមានការលក់ភាគហ៊ុន ឬមូលបត្រជាសាធារណៈបានឡើយ ប៉ុន្តែបានអនុញ្ញាតឲ្យធ្វើការអនុប្បទានទៅសមាជិកគ្រួសារទៅសមាជិកភាគហ៊ុន ឬ អ្នកគ្រប់គ្រងបាន ។ ក្នុងករណីធ្វើអនុប្បទានទៅឲ្យតតិយជនបាន លុះត្រាតែមានការយល់ព្រមដោយសម្លេងភាគច្រើនពីសមាជិកភាគហ៊ុនដទៃទៀត[42] ។

### ១.១.២ កម្មវត្ថុ និងលក្ខន្តិកៈនៃអាជីវកម្ម

#### ១.១.២.១ កម្មវត្ថុនៃអាជីវកម្ម

យើងបានដឹងរួចមកហើយថាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មានគោលបំណងអាជីវកម្មបានច្រើនយ៉ាង ប៉ុន្តែលើកលែងតែបង្កើតឡើងក្នុងគោលដៅអាជីវកម្មក្នុងទម្រង់ជាធនាគារ ធានារ៉ាប់រង និងក្រុមហ៊ុនឥណទាន ជាដើម ។ ដូច្នេះហើយកម្មវត្ថុក្នុងការមិនឲ្យធ្វើអាជីវកម្មរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតគឺប្រភេទអាជីវកម្មទាំងបីខាងលើ ។

#### ១.១.២.២ លក្ខន្តិកៈនៃជីវកម្ម

មុននឹងស្វែងយល់ពីលក្ខន្តិកៈរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត យើងគួរតែស្វែងយល់ពីខ្លឹមសារសំខាន់មួយ ហើយមិនអាចរំលងបាននោះគឺពាក្យ **លក្ខន្តិកៈ** ។ បើយោងតាមសន្ធានុក្រមក្នុងក្រមរដ្ឋប្បវេណី **លក្ខន្តិកៈ**[43] គឺសំដៅលើលិខិតបង្កើតនីតិបុគ្គល ដែលមានចុះនិទ្ទេសចាំបាច់ ខ្វះមិនបាន អំពីចំណុចសំខាន់ៗដូចជា គោលបំណង នាមករណ៍ ទីតាំងនៃទីស្នាក់ការកណ្តាល ។ល។

តាមអត្ថន័យដែលបានចង្អុលបង្ហាញនៅក្នុងក្រមរដ្ឋប្បវេណី យើងអាចកត់សម្គាល់ឃើញថាលក្ខន្តិកៈរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតតាមរូបភាពជាឯកជនដែលមានន័យថាធ្វើឡើយរវាងសមាជិករបស់ក្រុមហ៊ុនទាំងអស់ ឬតាមបែបជាលិខិតសាការី និងត្រូវមានការចុះហត្ថលេខាពីសមាជិកទាំងអស់នៅលើនោះ ។

តាមបញ្ញត្តិរបស់ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បានកំណត់ពីចំណុចសំខាន់ៗដែលត្រូវបំពេញនូវក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនមានដូចជា៖

[42] សៀវភៅនីតិក្រុមហ៊ុន តាក់តែងដោយលោកមេធាវី កង ស៊ីផាន់ណារ៉ា បោះពុម្ពលើកទី៣ ទំព័រ១០៤

[43] សន្ធានុក្រមផ្នែករដ្ឋប្បវេណី ល.រ ១២៩ លក្ខន្តិកៈ

១.នាមករណ៍របស់ក្រុមហ៊ុន

២.ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា

៣.កម្មវត្ថុនៃអាជីវកម្មនៃក្រុមហ៊ុន និងការកំណត់នូវអាជីវកម្មដែលក្រុមហ៊ុននោះធ្វើពាណិជ្ជកិច្ច ។ កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនអាចមានមួយ ឬច្រើនប្រភេទដែលមិនផ្ទុយទៅនឹងបញ្ញត្តិណាមួយនៃច្បាប់ ។

៤.ដើមទុនត្រូវប្រកាសជារូបិយវត្ថុជាតិ (ប្រាក់រៀល)

៥.ចំណាត់ប្រភេទ និងចំនួនអតិបរិមានៃភាគហ៊ុនព្រមទាំងតម្លៃចារឹកលើប័ណ្ណភាគហ៊ុនដែលត្រូវបានអនុញ្ញាតឲ្យបោះចេញដោយក្រុមហ៊ុននោះ ។

៦.ក្នុងករណីក្រុមហ៊ុនត្រូវអនុញ្ញាតឲ្យបោះប័ណ្ណភាគហ៊ុនលើសពីមួយប្រភេទក្រុមហ៊ុននោះ លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចែងចំនួនភាគហ៊ុនអតិបរិមា និងតម្លៃចារឹកលើប័ណ្ណភាគហ៊ុន ហើយត្រូវរៀបរាប់ពីសិទ្ធិឯកសិទ្ធិការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃប័ណ្ណភាគហ៊ុននោះ ។

៧.ក្នុងករណីប្រភេទភាគហ៊ុនត្រូវបោះជាសេរី លក្ខន្តិកៈក្រុមហ៊ុននោះ ត្រូវអនុញ្ញាតឲ្យអភិបាលកំណត់ចំនួនភាគនៃសេរីនីមួយៗ ដើម្បីកំណត់ប្លង់បែងចែកសេរីនីមួយៗ ហើយឈានទៅកំណត់សិទ្ធិឯកសិទ្ធិការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងសេរីនីមួយៗនោះ ។

៨.ក្នុងករណីការបោះចេញ ការផ្ទេរ ឬកាន់កាប់ប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវហាមឃាត់ ពេលនោះត្រូវរាយការណ៍ពីប្រសិទ្ធិភាព និងមានរបាយការណ៍ពីការកម្រិតនោះ ។

៩.ឈ្មោះ និងអាសយដ្ឋានពិតប្រាកដរបស់សមាជិកក្រុមហ៊ុនម្នាក់ៗ

១០.ចំនួនអភិបាល ឬ ចំនួនអប្បបរមា និងអតិបរមានៃអភិបាលរបស់ក្រុមហ៊ុននោះ ។

លក្ខន្តិកៈ ត្រូវបានតម្កល់ទុកនៅមន្ត្រីគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនៅពេលដែលធ្វើការចុះបញ្ជីក្រុមហ៊ុន ។ បន្ទាប់ពីការចុះបញ្ជីពាណិជ្ជកម្មចប់សព្វគ្រប់ ក្រុមហ៊ុននឹងទទួលបានបុគ្គលភាពគតិយុត្តិតាមច្បាប់ដោយទទួលបាននូវនីតិបុគ្គលិកលក្ខណៈក្លាយជានីតិបុគ្គល ។ ការក្លាយជានីតិបុគ្គលពេញសិទ្ធិនេះធ្វើឲ្យក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចធ្វើសកម្មភាពរបស់ខ្លួន ឬធ្វើពាណិជ្ជកិច្ចរបស់ខ្លួនបានទូទាំងប្រទេសកម្ពុជា ប៉ុន្តែក្រុមហ៊ុនក៏អាចធ្វើពាណិជ្ជកិច្ចខាងក្រៅប្រទេសបានដែរ ប្រសិនបើក្រុមហ៊ុនដែលធ្វើពាណិជ្ជកិច្ចជាមួយនោះអនុញ្ញាត ។

### ១.១.៣ នាមករណ៍ និងសញ្ជាតិ

#### ១.១.៣.១ នាមករណ៍

នាមករណ៍ ឬហៅសាមញ្ញថាឈ្មោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ពិតជាសំខាន់នឹងមានភាពទាក់ទាញសម្រាប់ធ្វើពាណិជ្ជកិច្ច នាមករណ៍របស់ក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតាមច្បាប់នៃ

ព្រះរាជាណាចក្រកម្ពុជាគឺត្រូវតែជាអក្សរខ្មែរ និងធំជាងអក្សរបរទេសប្រសិនបើក្រុមហ៊ុននោះត្រូវការដាក់នាមករណ៍ជាភាសាបរទេសបន្ថែម ។

នាមករណ៍របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវដាក់ពាក្យថា “ **ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត** ” ឬអាចសរសេរកាត់ដោយដាក់ខាងចុង ឬខាងក្រោមរបស់នាមករណ៍ក្រុមហ៊ុន **ឯ.ក** ។ នាមករណ៍របស់ក្រុមហ៊ុនអាចដាក់ទៅបាន លុះត្រាតែបានឆ្លងកាត់ការត្រួតពិនិត្យពីមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម ថាពិតជាត្រឹមត្រូវតាមច្បាប់កំណត់ និងមិនមានការភាន់ច្រឡំជាមួយនាមករណ៍របស់ក្រុមហ៊ុនផ្សេងដែលបានចុះបញ្ជីរួចរាល់ហើយ ។ ការកំណត់បែបនោះដោយគោរពតាមគោលការណ៍ការប្រកួតប្រជែងមួយដែលមានភាពត្រឹមត្រូវ និងស្មោះត្រង់ ។

### ១.១.៣.២ សញ្ជាតិ

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចត្រូវបានចាត់ទុកថាមានសញ្ជាតិខ្មែរលុះត្រាតែ[44]៖

១.ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្ម និងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា

២.ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី៥១% ( ហាសិបមួយភាគរយ ) ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ ។

### ១.១.៤ ថេរវេលា និងការបង់វិភាគទុន

### ១.១.៤.១ ថេរវេលា

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម មិនបានបង្ហាញសញ្ញាណណាមួយច្បាស់លាស់ស្តីពីថេរវេលារបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនេះទេ ប៉ុន្តែស្ថិតក្នុងការអនុវត្តន៍ជាក់ស្តែង គេសង្កេតឃើញថាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅក្នុងការស្នើចុះបញ្ជី គេមិនដែលឃើញមានការអនុញ្ញាតណាមួយក្នុងការចុះបញ្ជីឲ្យលើសពី៩៩ឆ្នាំនោះទេ មានន័យថា ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ប្រសិនបើចង់បន្តថ្មីនៅពេលចប់៩៩ឆ្នាំ[45] អាចបន្តថ្មីបាន តាមការស្នើសុំ ។

### ១.១.៤.២ ការបង់ភាគទុន

ការដាក់ភាគទុន នៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតគឺ ត្រូវបង់ភាគទុនជា៖

- ភាគទុនជាសាច់ប្រាក់
- ភាគទុនជាវត្ថុ
- សេចក្តីសម្រេចរបស់រដ្ឋាភិបាលក្នុងការទទួលបានយកភាគទុនជាសេវាកម្ម ពីមុនត្រូវបានទទួលយក

[44] មាត្រា១០១ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

[45] មាត្រា៦៦ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

ប្រសិនបើគ្មានការក្លែងបន្លំពាក់ព័ន្ធក្នុងរឿងនោះទេ[46] ។

## ១.២ ការប្រព្រឹត្តទៅនៃអភិបាល

### ១.២.១ អភិបាល និងគុណភាពអភិបាល

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ចាំបាច់ត្រូវមានអភិបាលម្នាក់ ឬច្រើននាក់ ។ ម្ចាស់ភាគហ៊ុនទាំងអស់ត្រូវបោះឆ្នោតតាមរយៈសេចក្តីសម្រេចសាមញ្ញនៃម្ចាស់ភាគហ៊ុនដែលមានសិទ្ធិក្នុងការបោះឆ្នោត ។

បន្ទាប់ពីបោះឆ្នោតជ្រើសរើសបានអភិបាលរួចរាល់ហើយ ក្រុមអភិបាលដំបូងគេដែលត្រូវបានជ្រើសរើសនោះត្រូវធ្វើការចាត់ចែងរៀបចំមហាសន្និបាតលើកទី១ របស់ម្ចាស់ក្រុមហ៊ុនក្នុងអំឡុងពេលមួយឆ្នាំដែលក្រុមហ៊ុននោះត្រូវបានបង្កើតឡើង ។ ការធ្វើមហាសន្និបាតនោះត្រូវមានជាលិខិតជូនដំណឹង ដែលត្រូវប្រគល់ជូនសមាជិកដែលនឹងត្រូវចូលរួមឲ្យបានមុន២០(ម្ភៃ)ថ្ងៃ ។ លើសពីនេះទៅទៀតលិខិតជូនដំណឹងនោះត្រូវភ្ជាប់ជាមួយខ្លឹមសារសំខាន់ដូចជា៖

១.កាលបរិច្ឆេទនៃមហាសន្និបាត

២.ទីកន្លែងដែលមហាសន្និបាតប្រារព្ធធ្វើឡើង និង

៣.អ្វីដែលសំខាន់បំផុតនៅក្នុងលិខិតជូនដំណឹងពីមហាសន្និបាតនោះគឺ របៀបវារៈនៃមហាសន្និបាត ។

ប្រសិនបើនិយាយពីអភិបាលវិញប្រហែលជាមានចម្ងល់ជាច្រើនថា តើដើម្បីឈរឈ្មោះជាអភិបាលបានត្រូវមានលក្ខណៈសម្បត្តិអ្វីខ្លះ ? នៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្ម មិនបានកំណត់ពីលក្ខណៈសម្បត្តិច្រើនទេពីអភិបាល ប៉ុន្តែអភិបាលត្រូវមានសមត្ថភាពមានអាយុ១៨ឆ្នាំ អាចបម្រើការងារជាអភិបាល ឬ ជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនបាន ។ ហើយក៏មានចម្ងល់បន្ថែមទៀតថា អភិបាលចាំបាច់ត្រូវតែជាម្ចាស់ក្រុមហ៊ុនឬយ៉ាងណា ? តើអភិបាលត្រូវមានលក្ខណៈសម្បត្តិអ្វីបន្ថែមពីចំណុចខាងលើដែរឬទេ ?

អភិបាលត្រូវបានគេកត់សម្គាល់ឃើញថា ជាក្បាលម៉ាស៊ីនដ៏សំខាន់របស់ក្រុមហ៊ុន ហេតុនេះត្រូវតែជាមនុស្សមានបទពិសោធន៍ និងសមត្ថភាពខ្ពស់ក្នុងការដឹកនាំ ប៉ុន្តែដើម្បីឆ្លើយនូវសំណួរខាងលើថា អភិបាលចាំបាច់ត្រូវតែជាម្ចាស់ក្រុមហ៊ុនដែរទេ ចម្លើយនោះគឺ អភិបាលមិនចាំបាច់ជាម្ចាស់ក្រុមហ៊ុននោះទេ ក្រៅពីម្ចាស់ក្រុមហ៊ុនក៏អាចធ្វើជាអភិបាលបានដែរ ហើយមិនចាំបាច់បន្ថែមលក្ខណៈសម្បត្តិណាផ្សេងទៀតក្រៅពីបានរៀបរាប់ខាងលើនោះទេ លើកលែងតែមានការចែងបន្ថែមណាមួយនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនតម្រូវតែប៉ុណ្ណោះ ។ ក្នុងករណីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនបានចែងអំពីអាណត្តិទេ អភិបាលម្នាក់ៗត្រូវមានអាណត្តិ០២(ពីរ)ឆ្នាំ ហើយអាចត្រូវបោះឆ្នោតសាជាថ្មីទៀត[47] មានន័យថាប្រសិនបើនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនបានកំណត់ពីអាណត្តិរបស់

[46] មាត្រា១២០ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

[47] មាត្រា១២១ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

អភិបាលនោះទេ គឺអាណត្តិរបស់អភិបាលត្រូវកំណត់ដោយច្បាប់ ប៉ុន្តែប្រសិនបើនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន បានកំណត់ពីអាណត្តិរបស់អភិបាល នាំឲ្យអាណត្តិរបស់អភិបាលត្រូវគោរពតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

### ១.២.២ សិទ្ធិអំណាចរបស់អភិបាល

យើងបានដឹងបានស្គាល់ខ្លះៗរួចមកហើយអំពីអភិបាល អភិបាល គឺជាសមាជិកនៃក្រុមប្រឹក្សាភិបាល ដែលមានតួនាទីដឹកនាំ និងគ្រប់គ្រងក្រុមហ៊ុន ។ អភិបាល អាចជាស្ថាបនិកក្រុមហ៊ុន ឬជាអ្នកតំណាងឲ្យសមាជិកក្រុមហ៊ុន ។ ហេតុនេះហើយអភិបាល ត្រូវមានសិទ្ធិអំណាចក្នុងការចាត់ចែងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន ហើយសិទ្ធិអំណាចអភិបាលទៀតសោធត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ដែលត្រូវមានសិទ្ធិអំណាចដូចជា[48]៖

១. តែងតាំង និងដកហូតអ្នកគ្រប់គ្រងទាំងអស់ និងកំណត់នូវសិទ្ធិ ច្បាស់លាស់សម្រាប់អ្នកគ្រប់គ្រងទាំងអស់ ។

២.កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់អ្នកគ្រប់គ្រងទាំងនោះ ។

៣.កម្រិតប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗសម្រាប់អភិបាលទាំងឡាយហើយដាក់ជូនម្ចាស់ភាគហ៊ុនដើម្បីសុំសម្រេច ។

៤.ចេញប័ណ្ណកំណត់សន្យា សញ្ញាប័ណ្ណ និងលិខិតស្នាមដែលបញ្ជាក់ថាមានបំណុល និងតឹកតាងផ្សេងៗនៃបំណុលរបស់ក្រុមហ៊ុន និងកំណត់នូវលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់លិខិតស្នាមទាំងឡាយ

៥.ស្នើសុំម្ចាស់ហ៊ុនដើម្បីធ្វើការកែប្រែលក្ខន្តិកៈ ឬលុបចោលលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

៦.ស្នើសុំម្ចាស់ភាគហ៊ុននូវកិច្ចសន្យារំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬរួមគ្នារវាងក្រុមហ៊ុន និងបុគ្គលផ្សេងណាមួយ ។

៧.ស្នើសុំម្ចាស់ក្រុមហ៊ុនដើម្បីលក់ទ្រព្យសម្បត្តិ ក្រុមហ៊ុនទាំងអស់ ឬមួយភាគ

៨.ស្នើសុំម្ចាស់ភាគហ៊ុនដើម្បីរំលាយក្រុមហ៊ុន ឬជម្រះបញ្ជីក្រុមហ៊ុន ។

៩.ប្រកាសភាគលាភទៅតាមគោលការណ៍គណនេយ្យ និងលក្ខខណ្ឌនៃការដាក់ភាគហ៊ុនប្រភេទនីមួយៗដែលមានសិទ្ធិទទួលបានភាគលាភ ។

១០.ចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនទៅតាមវិសាលភាព ដែលបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន

១១.ខ្ចីប្រាក់ (អាចធ្វើការខ្ចីប្រាក់ពីគេ និងឲ្យគេខ្ចីប្រាក់ ប៉ុន្តែការសម្រេចនេះត្រូវឆ្លងកាត់សន្និបាតរបស់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនជាមុនសិន ) ។

១២.បោះចេញសារជាថ្មី ឬលក់មូលបត្ររបស់ក្រុមហ៊ុន

១៣.ចុះកិច្ចសន្យាធានាក្នុងនាមក្រុមហ៊ុន ។

១៤.ធ្វើហ៊ីប៉ូតែក ចុះកិច្ចសន្យាបញ្ចាំ បើមិនដូច្នេះទេបង្កើតផលប្រយោជន៍ពីមូលបត្រចំពោះទ្រព្យសម្បត្តិទាំងអស់

[48] សៀវភៅនីតិសហគ្រាសពាណិជ្ជកម្ម រៀបរៀងដោយសាស្ត្រាចារ្យ ខាត់ ធី ទំព័រទី៧១ និង៧២

ឬទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុន ដើម្បីធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន ។
១៥.រៀបចំបិទបញ្ជីគណនេយ្យនៃកាលបរិច្ឆេទនីមួយៗជូនក្រុមហ៊ុន និងស្នើចាត់ចែងលទ្ធផលប្រចាំឆ្នាំ ដាក់ជូនមហាសន្និបាតនៃម្ចាស់ហ៊ុន ។

### ១.២.៣ ការបញ្ចប់តួនាទីរបស់អភិបាល

យើងបានដឹងរួចមកហើយថា អភិបាលត្រូវបានជ្រើសរើសដោយការបោះឆ្នោត ហេតុនេះហើយការបញ្ចប់តួនាទីរបស់អភិបាលគឺត្រូវបានដកហូតចេញពីមុខតំណាងកើតឡើងដោយការបោះឆ្នោតដូចគ្នាគឺសម្លេងភាគច្រើនដាច់ខាតនៃម្ចាស់ហ៊ុនដែលមានសិទ្ធិក្នុងការបោះឆ្នោត ទោះជាមាន ឬគ្មានមូលហេតុក៏ដោយ[49] ។

អភិបាលក៏អាចលាលែងពីមុខដំណែង នៅពេលណាក៏បានដោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមហ៊ុន ។ ការលាលែងពីមុខតំណែងរបស់អភិបាលនេះ ត្រូវមានសុពលភាពភ្លាម ឬមានប្រសិទ្ធិភាពចាប់ពីពេលដែលបានចែងនៅក្នុងលិខិតជូនដំណឹងនោះ[50] ។ នៅក្នុងមាត្រា១២៥ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក៏បានបញ្ជាក់ថា អភិបាល ក៏ត្រូវបានជំនួសភ្លាមៗផងដែរប្រសិនបើមានការលាលែងពីអភិបាលមុន ប៉ុន្តែចំណុចដែលអភិបាលត្រូវគិតនិងពិចារណាឲ្យបានល្អ និងមិនគួរមើលរំលងនោះគឺ ថាតើខ្លួនជាអភិបាលចុងក្រោយរបស់ក្រុមហ៊ុន ឬមានអភិបាលបន្ទាប់ ដើម្បីបន្តពីខ្លួន ។ ប្រសិនបើអភិបាលដែលបានលាលែងនោះជាអភិបាលចុងក្រោយក្នុងក្រុមហ៊ុន គឺត្រូវទទួលខុសត្រូវចំពោះការខូតខាតដែលបានបង្កឡើងដល់ក្រុមហ៊ុន ដោយសារការលាលែងរបស់ខ្លួន ។ ម្យ៉ាងទៀតអភិបាលក៏ត្រូវបានបញ្ចប់តួនាទីរបស់ខ្លួនដោយការបញ្ចប់អាណត្តិរបស់ខ្លួនផងដែរ អាណត្តិរបស់អភិបាលតាមច្បាប់កំណត់មានរយៈពេល២ឆ្នាំ ប៉ុន្តែប្រសិនបើលក្ខន្តិកៈរបស់ក្រុមហ៊ុនមានការចែងផ្សេងពីនេះត្រូវកំណត់យកតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ។ ហេតុនេះអភិបាលត្រូវដែលត្រូវបានបញ្ចប់តួនាទីរបស់ខ្លួនតាមអាណត្តិ ត្រូវបន្តការងាររបស់ខ្លួនជូនក្រុមហ៊ុនសិន រហូតដល់មានការបោះឆ្នោតជ្រើសរើសអភិបាលជំនួសថ្មី[51] ។

## ១.៣ ការបញ្ចប់ក្រុមហ៊ុន

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចត្រូវបានរំលាយដោយមានមូលហេតុជាច្រើនដូចជាៈ តាមការព្រមព្រៀងគ្នានៅក្នុងក្រុមហ៊ុន ការផុតកំណត់នៃរយៈពេលអាជីវកម្ម ក្ស័យធន ជាដើម ។

អភិបាល ម្ចាស់ភាគហ៊ុនអាចបោះឆ្នោតនៅពេលមហាសន្និបាត ម្ចាស់ភាគហ៊ុនក៏អាចស្នើឲ្យមានការជម្រះបញ្ជី និងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្តបានផងដែរ ដែលនេះបង្ហាញពីការព្រមព្រៀងផងគ្នាបញ្ចប់ក្រុមហ៊ុន

[49] មាត្រា១២៤ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[50] មាត្រា១២៥ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
[51] មាត្រា ១២៦ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ដោយការព្រមព្រៀងគ្នានៅក្នុងក្រុមហ៊ុន ។ តើការរំលាយក្រុមហ៊ុនឯកជនទទួលមានកម្រិតបញ្ចប់ត្រឹមការព្រមព្រៀងគ្នានេះឬ ?

នៅពេលព្រមព្រៀងគ្នាពីការបញ្ចប់ក្រុមហ៊ុនរួចហើយ ក្រុមហ៊ុនត្រូវគិតគូរពីទ្រព្យសម្បត្តិដែលនៅសល់ ឬហៅថាភាគលាភ និងទ្រព្យសម្បត្តិអកម្មរបស់ក្រុមហ៊ុន (បំណុល) ប្រសិនបើក្រុមហ៊ុនមិនមានទ្រព្យសម្បត្តិ ឬគ្មានបំណុលនោះទេ ក្រុមហ៊ុនអាចធ្វើការរំលាយតាមរយៈសេចក្ដីសម្រេចចិត្តពិសេសរបស់ភាគហ៊ុនិក ។

ក្នុងករណីដែលក្រុមហ៊ុនត្រូវបានរំលាយ ទោះបីការរំលាយនេះកើតពីមូលហេតុណាមួយក៏ដោយក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចាំបាច់ត្រូវតែធ្វើការជម្រះបញ្ជី ។ នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនមានអត្ថិភាពសម្រាប់ត្រូវការនៃការជម្រះបញ្ជីរហូតដល់ពេលបិទការជម្រះបញ្ជី និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ។

នីតិវិធីនៃការជម្រះបញ្ជីត្រូវធ្វើឡើយដោយអ្នកជម្រះបញ្ជីម្នាក់ ឬច្រើននាក់ដែលត្រូវបានតែងតាំងដោយម្ចាស់ក្រុមហ៊ុនផ្ទាល់តាមសម្លេងភាគច្រើនធម្មតា ឬភាគច្រើនដាច់ខាត ឬជាឯកច្ឆ័ន ។ អ្នកជម្រះបញ្ជីដែលត្រូវបានតែងតាំងដោយសម្លេងភាគច្រើនធម្មតា ឬភាគច្រើនដាច់ខាត ឬឯកច្ឆ័ន ត្រូវបានជ្រើសរើសចេញពីម្ចាស់ភាគហ៊ុន ឬតតិយជន ។ ហេតុនេះក្រោយពីបានជ្រើសតាំងរួចរាល់មក ហើយបានយល់ព្រមលើសេចក្ដីសម្រេចជម្រះបញ្ជី និងរំលាយក្រុមហ៊ុន ក្រុមហ៊ុនត្រូវធ្វើសេចក្ដីប្រកាសពីគោលបំណងនៃការរំលាយក្រុមហ៊ុនជាទម្រង់លម្អិតជូនទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

បន្ទាប់ពីទទួលបានសេចក្ដីសម្រេចពីការរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកក្រុមហ៊ុនត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុននោះ ។ ក្រោយពីទទួលបានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងពីក្រសួងពាណិជ្ជកម្មហើយ ក្រុមហ៊ុនត្រូវធ្វើការចុះផ្សាយលិខិតជូនដំណឹងនៃការរំលាយជាបន្ទាន់សម្រាប់រយៈពេល២(ពីរ) សប្ដាហ៍ជាប់ៗគ្នានៅក្នុងសារព័ត៌មានដែលបានបោះពុម្ពផ្សាយ ឬចែកចាយក្នុងកន្លែងដែលក្រុមហ៊ុនមានស្នាក់ការចុះបញ្ជីពិតប្រាកដ ឬបោះពុម្ពផ្សាយដទៃទៀតដូចបានកំណត់ក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម ។

## ២.ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាទ្រង់ទ្រាយមួយប្រភេទរបស់ក្រុមហ៊ុនមូលធន ដែលយើងបានដឹងរួចមកហើយថាការបង្កើត ក៏ដូចជាការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមូលធននេះ ។ ហេតុនេះហើយប្រសិនបើក្រុមហ៊ុនប្រភេទនេះធ្វើអាជីវកម្ម ដែលមានកម្មវត្ថុពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរបស់ច្បាប់មួយផ្សេងទៀតនោះការបង្កើតរបស់ក្រុមហ៊ុននេះក៏ត្រូវអនុលោមទៅតាមការកំណត់របស់ច្បាប់ទាំងអស់នោះផងដែរ ។

### ២.១ ការបង្កើត

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺជាទម្រង់មួយនៃក្រុមហ៊ុនមូលធន ហេតុនេះការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនេះ ត្រូវបានអនុញ្ញាតដោយច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ។ ច្បាប់

នេះក៏មិនបានបែងចែក ឬចែងឲ្យមានភាពច្បាស់លាស់ណាមួយក្នុងការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនោះទេ ប៉ុន្តែបើយើងក្រឡេកមើលពីដំណើរការក្នុងការបង្កើតក្រុមហ៊ុនវិញគឺក្រុមហ៊ុនត្រូវបានបង្កើតឡើងតាមរយៈដំណើរការមួយដែលតម្រូវឲ្យមានដាក់លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងទៅកាន់មន្ត្រីទទួលបន្ទុកគ្រប់គ្រង ។

## ២.១.១ ការបង្កើត និងការចុះបញ្ជីនៃក្រុមហ៊ុន

### ២.១.១.១ ការបង្កើត

យោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ ត្រង់ចំណុចមាត្រា៩១ បានចែងថា ៖ នីតិបុគ្គល ឬរូបវន្តបុគ្គលមួយ ឬច្រើន ដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់អាចបង្កើតក្រុមហ៊ុនមូលធន ដោយធ្វើការបំពេញតម្កល់លក្ខន្តិកៈទៅឲ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។ ហេតុនេះក៏យើងអាចសន្មត់បានថាការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលជាទ្រង់ទ្រាយមួយរបស់ក្រុមហ៊ុនមូលធន ផងដែរនោះ ហេតុនេះបែបបទនៃការបង្កើតក្រុមហ៊ុននេះត្រូវអនុលោមតាមមាត្រា៩១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ ។

### ២.១.១.២ ការចុះបញ្ជីនៃក្រុមហ៊ុន

គ្រប់ក្រុមហ៊ុនដែលបានធ្វើសកម្មភាពពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវការចុះបញ្ជីពាណិជ្ជកម្ម តាមបែបបទច្បាប់របស់ក្រសួងពាណិជ្ជកម្មរបស់កម្ពុជា ទោះបីបែបបទក្នុងការបង្កើតក្រុមហ៊ុន និងចិរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ ក៏ការចុះឈ្មោះរបស់ក្រុមហ៊ុននេះត្រូវធ្វើឡើងដោយបណ្ណាធិការ ឬអភិបាលនៃក្រុមហ៊ុនក្នុងខែនៃការបង្កើតក្រុមហ៊ុន និង១៥(ដប់ប្រាំ)ថ្ងៃ មុនកាលបរិច្ឆេទបើកប្រត្តិបត្តិការនៃពាណិជ្ជកម្ម ។

អ្នកស្នើសុំចុះឈ្មោះ ត្រូវទៅដល់ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍[52]ចំនួន ០២ច្បាប់ មានចុះហត្ថលេខារបស់សាមីខ្លួនអ្នកស្នើសុំ ព្រមទាំងតម្កល់លក្ខន្តិកៈក្រុមហ៊ុនផង ។ ប្រតិវេទន៍ដែលមន្ត្រីចុះបញ្ជីផ្តល់ជូនជាគម្រូនោះមានចែងអំពី៖ នាមត្រកូល នាមខ្លួន រហស្សនាម (ឈ្មោះហៅក្រៅ) របស់សមាជិកក្រុមហ៊ុន ថ្ងៃខែឆ្នាំ ទីកន្លែងកំណើត ស្ថានភាពគ្រួសារ និងសញ្ជាតិ ។

១.ផ្លាកសញ្ញារបស់ក្រុមហ៊ុន

២.កម្មវត្ថុនៃក្រុមហ៊ុន

៣.ទីកន្លែងទាំងឡាយដែលក្រុមហ៊ុនមានគ្រឹះស្ថានដើម មានសាខា ឬទីកន្លែងភ្នាក់ងារជាដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា

[52] វចនានុក្រមព្រះសង្ឃរាជ ជួន ណាត **ប្រតិវេទន៍** មានន័យថា ការពិតទូល ការជម្រាបប្រាប់ សេចក្តីប្រកាសប្រាប់ ដំណឹងជាលាយលក្ខណ៍អក្សរ ។

៤.នាមរបស់សមាជិក ឬតតិយជន ដែលបានអនុញ្ញាតឲ្យគ្រប់គ្រង ចាត់ចែង និងចុះហត្ថលេខា ជំនួសមុខក្រុមហ៊ុន ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើតនៃសមាជិកទាំងអស់នោះ

៥.ដើមទុនរបស់ក្រុមហ៊ុន ប្រភពដើមទុន និងចំនួនទឹកប្រាក់ ឬវត្ថុដែលជាដើមទុនមានតម្លៃ ដែលត្រូវបានផ្តល់ដោយសមាជិកភាគហ៊ុន

៦.ថ្ងៃខែឆ្នាំ ដែលក្រុមហ៊ុនបានចាប់ផ្តើម និងថ្ងៃខែឆ្នាំក្រុមហ៊ុនដែលត្រូវបញ្ចប់

៧.ទ្រង់ទ្រាយក្រុមហ៊ុន

៨.ហត្ថលេខាគម្រូរបស់សមាជិក ឬតតិយជន ដូចមានចែងនៅចំណុចលេខ៥ នៃមាត្រា១៧ និងស្នាមត្រាគម្រូរបស់ក្រុមហ៊ុន

៩.លិខិតបញ្ជាក់ពីការតម្កល់ដើមទុន ដែលចេញដោយធនាគារ

១០.សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថា គ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្មរដ្ឋប្បវេណី ឬព្រហ្មទណ្ឌឡើយ ។

### ២.១.២ នាមករណ៍ និងលក្ខន្តិកៈក្រុមហ៊ុន

#### ២.១.២.១ នាមករណ៍

នាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់ពាក្យថា “ **ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** ” ឬសរសេរពាក្យកាត់ដោយដាក់ខាងចុង ឬខាងក្រោមដោយអក្សរកាត់ **ម.ក** ឬ **PLC** ។ នាមករណ៍ដែលត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនក្នុងការធ្វើពាណិជ្ជកិច្ចរបស់ខ្លួន ក្រុមហ៊ុនមិនអាចប្រើប្រាស់ឈ្មោះផ្សេងក្រៅពីនេះបានទេ ប្រសិនបើក្រុមហ៊ុនប្រើប្រាស់ឈ្មោះផ្សេងដើម្បីធ្វើពាណិជ្ជកិច្ចរបស់ខ្លួន ក្រុមហ៊ុននឹងត្រូវទទួលរងនូវការដាក់ទណ្ឌកម្មតាមច្បាប់ជាធរមាន ។

លើសពីនេះទៅទៀតមន្ត្រីទទួលបន្ទុកគ្រប់គ្រងពាណិជ្ជកម្ម ត្រូវត្រួតពិនិត្យនូវនាមករណ៍ដែលបានស្នើសុំចុះបញ្ជីពីបណ្តាក្រុមហ៊ុនទាំងនោះ ហើយអាចបដិសេធនូវនាមករណ៍ ណាដែលមានភាពប្រហាក់ប្រហែលគ្នាធ្វើឲ្យមានការភាន់ច្រឡំទៅនឹងនាមករណ៍របស់ក្រុមហ៊ុនផ្សេងទៀត ដែលបានចុះបញ្ជីរួចរាល់មុន ឬនាមករណ៍របស់ក្រុមហ៊ុនបានស្នើមកចុះបញ្ជីមានភាពមិនសមរម្យដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ។

ការសម្រេចរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដែលពាក់ព័ន្ធជាមួយនាមករណ៍របស់ក្រុមហ៊ុន ជាការសម្រេចចុងក្រោយថាឯកភាពព្រមទទួលឈ្មោះរបស់ក្រុមហ៊ុននោះចុះបញ្ជីតាមការស្នើសុំ ឬមិនអនុញ្ញាតឲ្យចុះបញ្ជីដោយមូលហេតុផ្ទុយច្បាប់ ឬសណ្តាប់ធ្នាប់សាធារណៈ ។

### ២.១.២.២ លក្ខន្តិកៈក្រុមហ៊ុន

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវបំពេញលក្ខន្តិកៈមួយចំនួន និងចាំបាច់បំផុតរួមមាន៖

១.នាមករណ៍របស់ក្រុមហ៊ុន

២.ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុននៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា

៣.កម្មវត្ថុនៃអាជីវកម្មនៃក្រុមហ៊ុន និងការកំណត់នូវអាជីវកម្មដែលក្រុមហ៊ុនធ្វើពាណិជ្ជកិច្ច ។ កម្មវត្ថុនៃអាជីវកម្មរបស់ក្រុមហ៊ុនអាចមានមួយ ឬច្រើនជាងមួយ ដែលមិនផ្ទុយនឹងបញ្ញត្តិណាមួយនៃច្បាប់ ។

៤.ដើមទុនរបស់ក្រុមហ៊ុនត្រូវប្រកាសជារូបិយវត្ថុជាតិ (កម្ពុជា ប្រើប្រាស់រូបិយវត្ថុជា ប្រាក់រៀល)

៥.ចំណាត់ប្រភេទ និងចំនួនអតិបរមានៃភាគហ៊ុន ព្រមទាំងតម្លៃចារឹកលើប័ណ្ណភាគហ៊ុនដែលត្រូវបានអនុញ្ញាតឲ្យបោះចេញដោយក្រុមហ៊ុននោះ

៦.ក្នុងករណីក្រុមហ៊ុនត្រូវអនុញ្ញាតឲ្យបោះប័ណ្ណភាគហ៊ុនលើសពីមួយប្រភេទក្រុមហ៊ុននោះ លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវថែងចំនួនភាគហ៊ុនអតិបរមា និងតម្លៃចារឹតលើប័ណ្ណភាគហ៊ុន ហើយត្រូវរៀបរាប់ពីសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃប័ណ្ណភាគហ៊ុននោះ ។

៧.ក្នុងករណីភាគហ៊ុនត្រូវបានបោះជាសេរី លក្ខន្តិកៈក្រុមហ៊ុននោះត្រូវបានអនុញ្ញាតឲ្យអភិបាលកំណត់ចំនួនភាគហ៊ុននៃស៊េរីចំនួននីមួយៗ ដើម្បីកំណត់ប្លង់បែងចែកស៊េរីនីមួយៗ ហើយឈានទៅកំណត់សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងស៊េរីនីមួយៗនោះ ។

៨.ក្នុងករណីការបោះចេញ ការផ្ទេរ ឬការកាន់កាប់ប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវបានហាមឃាត់ ពេលនោះត្រូវមានរបាយការណ៍ពីប្រសិទ្ធិភាព និងមានរបាយការណ៍ពីការកម្រិតនោះ ។

៩.ឈ្មោះ និងអាសយដ្ឋានពិតប្រាកដរបស់សមាជិកក្រុមហ៊ុនម្នាក់ៗ

១០.ចំនួនអភិបាល ឬចំនួនអប្បបរមា និងអតិបរមានៃអភិបាលរបស់ក្រុមហ៊ុននោះ ។

នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុននេះយើងឃើញថា លក្ខន្តិកៈអាចត្រូវបានធ្វើឡើងជាលិខិតរវាងឯកជន ឬជាលិខិតសារការី ហើយគ្រប់ទំព័ររបស់លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចុះហត្ថលេខា ឬចុះជាហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់របស់ក្រុមហ៊ុន ។

### ២.១.៣ សមត្ថភាព និងសិទ្ធិរបស់ក្រុមហ៊ុន

ក្រោយពីបានតម្កល់លក្ខន្តិកៈរបស់ក្រុមហ៊ុន និងក្រោយពីបានទទួលសោហ៊ុយនៃការតម្កល់លក្ខន្តិកៈរបស់ក្រុមហ៊ុនរួចមក មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញជាលិខិតបញ្ជាក់មួយជាសម្គាល់ជូនទៅក្រុមហ៊ុន ។ បន្ទាប់ពីបានធ្វើការចុះបញ្ជីរួចរាល់មក ក្រុមហ៊ុននឹងទទួលបានបុគ្គលភាពគតិយុត្តិ

ស្របតាមផ្លូវច្បាប់ ជានីតិបុគ្គលិកលក្ខណៈ ដែលមានសមត្ថភាពសិទ្ធិ និងបុព្វសិទ្ធិដូចរូបវន្តបុគ្គល[53]ដែរ ។ ហេតុនេះបានបញ្ជាក់ឲ្យឃើញច្បាប់ថាក្រុមហ៊ុនទទួលបានបុគ្គលិកលក្ខណៈពេញលេញជានីតិបុគ្គល នៅពេលបានចុះបញ្ជីស្របតាមបញ្ញាតិច្បាប់ និងអាចបំពេញពាណិជ្ជកិច្ចរបស់ខ្លួនបានទូទាំងព្រះរាជាណាចក្រកម្ពុជា និងអាចប្រកបពាណិជ្ជកិច្ចដែលជាកិច្ចការជំនួញ ជួញដូររបស់ខ្លួនទាំងក្នុង និងក្រៅប្រទេសបាន លុះត្រាតែមានច្បាប់ដែលជាដៃគូរសហការក្នុងការធ្វើពាណិជ្ជកិច្ចនោះអនុញ្ញាត ។ ទោះបីក្រុមហ៊ុនបានទទួលនីតិបុគ្គលិកលក្ខណៈជានីតិបុគ្គលបែបនេះក្តី ក៏ក្រុមហ៊ុនមិនអាចអនុញ្ញាតឲ្យប្រកបពាណិជ្ជកិច្ចរបស់ខ្លួន ឬអនុវត្តន៍សិទ្ធិណាមួយឲ្យផ្ទុយពីលក្ខន្តិកៈរបស់សាមីក្រុមហ៊ុនបានឡើយ ។

## ២.២ ការប្រព្រឹត្តទៅនៃក្រុមហ៊ុន

### ២.២.១ ការគ្រប់គ្រងក្រុមហ៊ុន

បើយើងក្រឡេកមើលពីការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតវិញ គឺត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលដោយយោងតាមច្បាប់លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ។ ចំណែកក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺឃើញថាមានការគ្រប់គ្រងពីអភិបាលយ៉ាងតិច០៣រូប ។ អភិបាលទាំងអស់នោះត្រូវបានជ្រើសរើសដោយការបោះឆ្នោតពីម្ចាស់ហ៊ុនទាំងអស់ដែលមានសិទ្ធិក្នុងការបោះឆ្នោត ។ លើសពីនេះទៅទៀតថាតើអភិបាលដែលជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវមានលក្ខណៈសម្បត្តិតម្រូវអ្វីខ្លះដើម្បីអាចឈរឈ្មោះជាអភិបាលក្នុងការបោះឆ្នោតជ្រើសរើសពីម្ចាស់ភាគហ៊ុនបាន ។

អភិបាលត្រូវបានកំណត់ជាអ្នកដឹកនាំគ្រប់គ្រងក្រុមហ៊ុនក៏មានភាពឆ្លាតវៃ និងប៉ិនប្រសប់បំផុតនៅក្នុងការដឹកនាំ តើអភិបាលត្រូវមានលក្ខណៈសម្បត្តិអ្វីខ្លះ ? ហើយអភិបាលត្រូវតែជាម្ចាស់ក្រុមហ៊ុនឬ ?

រូបវន្តបុគ្គលដែលមានសមត្ថភាព មានអាយុលើសពី១៨ឆ្នាំ លក្ខខណ្ឌទាំងពីរនេះអាចធ្វើឲ្យរូបវន្តបុគ្គលនោះអាចបម្រើការងារ ឬជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនបាន ។ អភិបាល គឺមិនចាំបាច់ ឬតម្រូវត្រូវតែជាម្ចាស់ក្រុមហ៊ុននោះទេ ឬមិនតម្រូវឲ្យមានលក្ខណៈសម្បត្តិណាផ្សេងទៀតនោះទេ លើកលែងតែមាននៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនបានកំណត់ផ្សេងប៉ុណ្ណោះ ។ លើសពីនេះទៅទៀតក្រុមប្រឹក្សាភិបាលត្រូវចាត់ចែងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន ហើយនៅក្នុងលក្ខន្តិកៈក្រុមហ៊ុនត្រូវចែងពីសិទ្ធិរបស់អភិបាលជាអាទិ៍ ដែលត្រូវទទួលបានសិទ្ធិ និងអំណាច ដែលបានចង្អុលបង្ហាញក្នុងច្បាប់សហគ្រាសពាណិជ្ជកម្ម ត្រង់មាត្រា១៩៩ រួមមាន១៥ចំណុច ៖

១.តែងតាំង និងដកហូតអ្នកគ្រប់គ្រងទាំងអស់ និងកំណត់នូវសិទ្ធិច្បាស់លាស់សម្រាប់អ្នកគ្រប់គ្រងទាំងនោះ ។

២.កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់អ្នកគ្រប់គ្រងទាំងនេះ

---

[53] មាត្រា៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ រូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលបានសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលបានសិទ្ធិនេះ នៅពេលទទួលមរណភាព ។

៣.កម្រិតប្រាក់បៀវត្ស ឬប្រាក់បំណាច់ផ្សេងៗសម្រាប់អភិបាលទាំងឡាយ ហើយដាក់ជូនម្ចាស់ក្រុមហ៊ុនដើម្បីសុំសេចក្តីសម្រេច ។

៤.ចេញប័ណ្ណកំណត់សន្យា សញ្ញាប័ណ្ណ និងលិខិតស្នាមដែលបញ្ជាក់ថាមានបំណុលរបស់ក្រុមហ៊ុន និងកំណត់នូវលក្ខណៈដាច់ខាតនិងលក្ខណៈធៀបរបស់លិខិតស្នាមទាំងឡាយនោះ ។

៥.ស្នើសុំម្ចាស់ហ៊ុន ដើម្បីធ្វើការកែប្រែលក្ខន្តិកៈ ឬលុបចោលលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

៦.ស្នើសុំម្ចាស់ហ៊ុននូវកិច្ចសន្យារំលាយចូលគ្នា ឬរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលផ្សេងណាមួយ ។

៧.ស្នើសុំម្ចាស់ហ៊ុន ដើម្បីលក់ទ្រព្យសម្បត្តិក្រុមហ៊ុនទាំងអស់ ឬមួយភាគ ។

៨.ស្នើសុំម្ចាស់ហ៊ុន ដើម្បីរំលាយ ឬជម្រះបញ្ជីក្រុមហ៊ុន ។

៩.ប្រកាសភាគលាភទៅតាមគោលការណ៍គណនេយ្យ និងតាមលក្ខខណ្ឌនៃការដាក់ភាគហ៊ុន ប្រភេទនីមួយៗដែលមានសិទ្ធិទទួលបានភាគលាភ ។

១០.ចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនទៅតាមវិសាលភាពដែលបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន

១១.ខ្ចីប្រាក់

១២.បោះចេញ បោះចេញសាជាថ្មី ឬលក់មូលបត្ររបស់ក្រុមហ៊ុន

១៣.ចុះកិច្ចសន្យាធានា ក្នុងនាមក្រុមហ៊ុន

១៤.ធ្វើហ៊ីប៉ូតែក ចុះកិច្ចសន្យាបញ្ចាំ បើមិនដូច្នេះទេបង្កើតផលប្រយោជន៍ពីមូលបត្រចំពោះទ្រព្យសម្បត្តិទាំងអស់ ឬទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុនដើម្បីធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន ។

១៥.រៀបចំការបិទបញ្ជីគណនេយ្យនៃកាលបរិច្ឆេទនីមួយៗជូនម្ចាស់ហ៊ុន និងស្នើចាត់ចែងលទ្ធផលប្រចាំឆ្នាំដាក់ជូនមហាសន្និបាតនៃម្ចាស់ហ៊ុន ។

### ២.២.២ ទីស្នាក់ការចុះបញ្ជី សៀវភៅបញ្ជី និងកំណត់ហេតុ

#### ២.២.២.១ ទីស្នាក់ការចុះបញ្ជី

គ្រប់ពេលវេលាក្រុមហ៊ុនត្រូវមានទីស្នាក់ការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចដែលបានបញ្ជាក់នៅក្នុងលក្ខន្តិកៈរបស់កក្រុមហ៊ុន ។ ក្រុមហ៊ុនត្រូវផ្តល់ឲ្យទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនូវសេចក្តីជូនដំណឹងអំពីទីតាំង ទីស្នាក់ការចុះបញ្ជីជាមួយគ្នា និងលក្ខន្តិកៈដែលស្តីពីទីតាំង ឬពីការផ្លាស់ប្តូរទីស្នាក់ការ ការចុះបញ្ជីនោះ ។

លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរទីតាំង របស់ទីស្នាក់ការចុះបញ្ជីត្រូវផ្ញើរទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានផ្លាស់ប្តូរទីតាំងនោះ ។

ក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីរបស់ខ្លួននូវៈ

- លក្ខន្តិកៈ និងគ្រប់គ្រងការប្រែទាំងអស់
- កំណត់ហេតុអង្គប្រជុំ និងសេចក្តីសម្រេចទាំងឡាយរបស់ម្ចាស់ហ៊ុន
- ឯកសារនៃសេចក្តីសម្រេចជូនដំណឹងតម្រូវឲ្យផ្ញើ ឬតម្កល់ទុកឯកសារ
- បញ្ជីមូលបត្រ[54]

### ២.២.២.២ សៀវភៅបញ្ជី និងកំណត់ហេតុ

សៀវភៅបញ្ជី របស់ក្រុមហ៊ុនត្រូវបានរក្សាទុកសៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនដោយប្រុងប្រយ័ត្ន និងការពារឲ្យបានត្រឹមត្រូវ ។ ក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រងសម្រាប់រយៈពេល១០(ដប់)ឆ្នាំបន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ ។ ក្នុងករណីបញ្ជីគណនេយ្យត្រូវបានរក្សាទុកនៅក្រៅព្រះរាជាណាចក្រកម្ពុជា ឯកសារច្បាប់ចម្លងនៃបញ្ជីគណនេយ្យនោះក៏ត្រូវបានរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីផងដែរ ។

កំណត់ហេតុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំ និងរក្សាទុកកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាលទាំងឡាយ និងសេចក្តីសម្រេចរបស់គណៈកម្មាធិការអភិបាលឲ្យបានគ្រប់ចំនួន ។ កំណត់ហេតុប្រជុំនីមួយៗត្រូវរក្សាទុកនៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬនៅកន្លែងដទៃទៀតដែលអភិបាលបានយល់ឃើញថាសមស្រប ហើយឯកសារទាំងនោះត្រូវបានបើកចំហរ ដើម្បីឲ្យអភិបាលធ្វើការពិនិត្យបានគ្រប់ពេល ។

### ២.២.៣ ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

ក្រុមហ៊ុនពីរ ឬច្រើនអាចត្រូវបានរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយបាន ឬអាចបង្រួមចូលគ្នាជាក្រុមហ៊ុនថ្មីមួយផ្សេងទៀតបាន និងក្រុមហ៊ុនដែលបានរំលាយហៅថា **ក្រុមហ៊ុនដើម** ដោយក្រុមហ៊ុនដែលទទួលបន្ទុកធ្វើអាជីវកម្មតទៅទៀតហៅថា **ក្រុមហ៊ុនថ្មី** ។ ក្រុមហ៊ុននីមួយៗមាននីតិបុគ្គលិកលក្ខណៈ របស់ខ្លួនរៀងខ្លួន ហេតុនេះនៅពេលក្រុមហ៊ុនពីរត្រូវបានត្រូវបានរំលាយបញ្ចូលគ្នា  ក្រុមហ៊ុនដើមនឹងត្រូវបាត់បង់នូវនីតិបុគ្គលិកលក្ខណៈចាប់ពីថ្ងៃដែលក្រសួងពាណិជ្ជកម្មចេញ វិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននីមួយៗ ដែលស្នើរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវអនុម័តនូវសេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងនៃការរំលាយបញ្ចូលគ្នា ។ លើកលែងតែមានចែងនៅក្នុងលក្ខន្តិកៈការអនុម័តនេះត្រូវផ្អែកលើចំនួនភាគច្រើន ដាច់ខាតនៃអភិបាលទាំងអស់ ។ កិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចែងអំពី ៖

- ចំណុចសំខាន់ៗ និងលក្ខខណ្ឌនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា
- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តធ្វើអាជីវកម្ម

[54] សៀវភៅនីតិក្រុមហ៊ុន របស់លោកមេធាវី អ៊ីវ ប៉ូលី ឆ្នាំ២០០៨ ទំព័រ ៧៩ និង៨០

- បែបបទនៃការផ្លាស់ប្តូរភាគហ៊ុននៃប្រភេទនីមួយៗរបស់ក្រុមហ៊ុនដើមឲ្យទៅជាភាគហ៊ុនឬមូលបត្រផ្សេងៗ របស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម ។
- របាយការណ៍ស្តីពីសាច់ប្រាក់ សិទ្ធិ មូលបត្រ ឬកម្មសិទ្ធិផ្សេងៗទៀត ដែលអ្នកកាន់កាប់ភាគហ៊ុនត្រូវទទួលក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ប្រសិនបើភាគហ៊ុនណាមួយរបស់ក្រុមហ៊ុនដើម មិនត្រូវប្តូរទៅជាភាគហ៊ុនរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្មនោះទេ
- ព័ត៌មានដទៃទៀតដែលម្ចាស់ក្រុមហ៊ុនក្នុងប្រភេទនីមួយៗ ចង់ដឹងដើម្បីជាមូលដ្ឋានធ្វើការសម្រេចចិត្តក្នុងការបោះឆ្នោតរំលាយក្រុមហ៊ុនបញ្ចូលគ្នា
- ព័ត៌មានលម្អិតនៃកិច្ចសម្របសម្រួលចាំបាច់ ដើម្បីឲ្យប្រសើរឡើង និងដើម្បីផ្តល់ដល់ការគ្រប់គ្រងព្រមទាំងប្រត្តិបត្តការនាពេលបន្ទាប់នៃក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកពាណិជ្ជកម្ម

ក្រោយពីទទួលបានសេចក្តីសម្រេចពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដើមនីមួយៗ ម្ចាស់ក្រុមហ៊ុនថ្មីត្រូវជូនដំណឹងទៅឲ្យម្ចាស់ក្រុមហ៊ុនស្តីពីការប្រជុំម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតនូវព័ត៌មានដូចតទៅ ៖

- នៅក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយកិច្ចព្រមព្រៀងនេះ ក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនដើមនីមួយៗ ត្រូវធ្វើមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីបោះឆ្នោតសម្រេចលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។
- លិខិតជូនដណឹងត្រូវភ្ជាប់ជាមួយនឹងច្បាប់ចម្លងនៃកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា
- ក្រុមហ៊ុននីមួយៗត្រូវផ្តល់លិខិតជូនដំណឹងស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុនយ៉ាងតិច២០(ម្ភៃ)ថ្ងៃមុន

នៅក្នុងការរំលាយក្រុមហ៊ុន បញ្ចូលគ្នាត្រូវមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុនពីរភាគបី (២/៣) នៃក្រុមហ៊ុនដើមនីមួយៗ ។ ទោះបីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនអនុញ្ញាតឲ្យប្រភេទក្រុមហ៊ុនណាមួយមានសិទ្ធិទូទៅ ក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទភាគហ៊ុននោះនឹងនៅមានសិទ្ធិ ដោយឡែកក្នុងការបោះឆ្នោតនៅតាមប្រភេទភាគហ៊ុនរបស់ខ្លួន ដើម្បីសម្រេចលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ដែលអាចនឹងកែប្រែដោយផ្ទាល់ និងប្រយោលនូវសិទ្ធិឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌនៃប្រភេទ ឬស៊េរីនៃក្រុមហ៊ុនផ្សេងៗ ។

អំណាចបោះឆ្នោតដែលបង្កើតឡើងក្នុងច្បាប់នេះមិនអាចបដិសេធ ឬកែប្រែដោយលក្ខន្តិកៈរបស់ក្រុមហ៊ុនតាមរបៀបណាផ្សេងទៀតបានឡើយ ។

អភិបាលរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្តត្រូវតម្កល់ឯកសារទុកនៅក្រសួងពាណិជ្ជកម្មដែលមានជាអាទិ៍៖

- កិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

- សេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុន បញ្ចូលគ្នានៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងនៃមហាសន្និបាតម្ចាស់ភាគហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត
- សេចក្តីប្រកាសរបស់អភិបាល ឬអ្នកគ្រប់គ្រងនៃក្រុមហ៊ុនដើមនីមួយៗ ដែលធ្វើឡើងតាមការទាមទារពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម សេចក្តីប្រកាសនោះត្រូវមានមូលហេតុសមរម្យដូចតទៅ ៖ “ ក្រុមហ៊ុនដើម និងក្រុមហ៊ុនថ្មីដែលទទួលអាជីវកម្មបន្តនីមួយៗ គឺមានលទ្ធភាពសងបំណុលរបស់ខ្លួន តាមពេលវេលាដែលត្រូវសង ធនធានសរុបរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត មិនត្រូវតិចជាងចំនួនសរុបនៃបំណុលដែលខ្លួនជំពាក់ និងដើមទុនចុះបញ្ជីនៃក្រុមហ៊ុនដើម គ្មានម្ចាស់បំណុលណាមួយទទួលការខូចខាតដោយសារការរំលាយក្រុមហ៊ុនបញ្ចូលគ្នានោះទេលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវបានប្រគល់ឲ្យម្ចាស់បំណុលទាំងអស់របស់ក្រុមហ៊ុនដើម ហើយគ្មានម្ចាស់បំណុលណាមួយធ្វើការជំទាស់ដែលមានមូលហេតុស្របទៅលើការរំលាយបញ្ចូលគ្នានោះទេ នៅពេលទទួលបានលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ក្រសួងពាណិជ្ជកម្មត្រូវបានចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ចាប់ពីកាលបរិច្ឆេទដែលមានចុះនៅលើវិញ្ញាបនបត្រនេះ[55] ” ។

## ២.៣ ការបញ្ចប់ក្រុមហ៊ុន

ក្រុមហ៊ុនមួយ អាចត្រូវបានបញ្ចប់សកម្មភាពប្រត្តិបត្តការរបស់ខ្លួនដូចបានកំណត់ក្នុងលក្ខន្តិកៈការព្រមព្រៀង ឬកង្វះសមត្ថភាពដោយការក្ស័យធនជាដើម សុទ្ធសឹងតែជាមូលហេតុដែលនាំឲ្យក្រុមហ៊ុនត្រូវបានបញ្ចប់ ។ ប៉ុន្តែយើងសង្កេតឃើញថា ក្រុមហ៊ុនដែលមិនបានចេញប័ណ្ណភាគហ៊ុនណាមួយ អាចត្រូវបានរំលាយឬបញ្ចប់ដោយមានល័ក្ខខ័ណ្ឌងាយស្រួល និងមិនមានភាពស្មុគស្មាញនោះទេ គឺអាចធ្វើការរំលាយនៅពេលណាក៏បានតាមរយៈសេចក្តីសម្រេចរបស់អភិបាលទាំងអស់ ។

ម្យ៉ាងវិញទៀតប្រសិនបើក្រុមហ៊ុនបានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទ នោះការរំលាយក្រុមហ៊ុនមិនអាចសម្រេចត្រឹមអភិបាលទាំងអស់បានទេ ដែលជាភាគស្មុគស្មាញមួយមិនដូចក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលមិនចេញប័ណ្ណនោះទេការសម្រេចរំលាយក្រុមហ៊ុនត្រូវធ្វើតាមរយៈ សេចក្តីសម្រេចចិត្តពិសេសរបស់អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ ទោះបីម្ចាស់ក្រុមហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតក៏ដោយ[56] ។

[55] សៀវភៅនីតិក្រុមហ៊ុន របស់លោកមេធាវី អ៊ីវ ប៉ូលី ឆ្នាំ២០០៨ ទំព័រ ១១៧

[56] មាត្រា២៥១ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

ការស្នើសុំរំលាយក្រុមហ៊ុននេះ ត្រូវបានប្រព្រឹត្តទៅ តាមការស្នើសុំទៅកាន់ក្រសួងពាណិជ្ជកម្ម ដើម្បីបញ្ជាក់ពីការរំលាយក្រុមហ៊ុនផ្លូវការ ដែលមានន័យសំដៅថាក្រុមហ៊ុននេះ លែងជានីតិបុគ្គលតទៅទៀតហើយ ក្រោយពីការចេញវិញ្ញាបនបត្របញ្ជាក់ពីក្រសួងពាណិជ្ជកម្ម ។

### ២.៣.១ ការបញ្ចប់អត្ថិភាព

ការបញ្ចប់ក្រុមហ៊ុនដោយការព្រមព្រៀង គឺជាបញ្ចប់ដោយស្មគ្រ័ចិត្ត តាមការកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។ ការព្រមព្រៀងរបស់ក្រុមហ៊ុន ឬក្រុមប្រឹក្សាភិបាល តាមប្រភេទក្រុមហ៊ុននីមួយៗ ។ រំលាយក្រុមហ៊ុន ក្រសួងពាណិជ្ជកម្មតម្រូវឲ្យតំណាងក្រុមហ៊ុនបំពេញឯកសារមួយចំនួនមាន៖

| | |
|---|---|
| ១.ពាក្យសុំគម្រូ ក | ០៣ ច្បាប់ (០២ច្បាប់ដើម ០១ ច្បាប់ថតចម្លង) |
| ២.ប័ណ្ណជម្រះបញ្ជីសារពើពន្ធចេញដោយនាយកដ្ឋានពន្ធដារ | ០៣ ច្បាប់ (០១ច្បាប់ដើម ០២ ច្បាប់ថតចម្លង) |
| ៣.អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់ម្ចាស់ហ៊ុន ឬអភិបាលដែលបានចុះហត្ថលេខា ឬស្នាមមេដៃដែលមកបង្ហាញខ្លួន នៅក្រសួងពាណិជ្ជកម្ម ដើម្បីចុះហត្ថលេខាលើពាក្យស្នើសុំ | ០៣ ច្បាប់ |
| ៤.រូបថតទំហំ ៤ X ៦ របស់ម្ចាស់ភាគហ៊ុន ឬអភិបាលដែលមកបង្ហាញខ្លួននៅក្រសួងពាណិជ្ជកម្ម ដើម្បីចុះហត្ថលេខាលើពាក្យស្នើសុំ | ០៣ សន្លឹក |
| ៥.លក្ខន្តិកៈក្រុមហ៊ុនដែលបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម | ០៣ ច្បាប់ |
| ៦.អាជ្ញាប័ណ្ណអាជីវកម្មចេញដោយក្រសួងពាណិជ្ជកម្ម | ០១ ច្បាប់ដើម |
| ៧.វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មចេញដោយក្រសួងពាណិជ្ជកម្ម | ០១ ច្បាប់ដើម |
| ៨.លិខិតស្នើសុំពីក្រុមហ៊ុន | ០១ ច្បាប់ដើម |
| ៩.កំណត់ហេតុរំលាយក្រុមហ៊ុន (របស់ក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគហ៊ុន) | ០១ ច្បាប់ដើម |
| ១០.សេចក្តីសម្រេចរបស់ក្រុមហ៊ុនមេ (ប្រសិនបើពាក់ព័ន្ធ) | ០១ ច្បាប់ដើម |
| ១១. កម្រៃសោហ៊ុយរដ្ឋបាល | ២០០.០០០ រៀល |

### ២.៣.២ ការជម្រះបញ្ជី និងចំណូល

ការជម្រះបញ្ជី គឺជាការដោះស្រាយកិច្ចការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬបុគ្គលជាទូទៅដោយធ្វើការបំលែងទៅជាសាច់ប្រាក់នូវទ្រព្យសកម្មទាំងឡាយ ដើម្បីចែកចាយទៅឲ្យឥណទាយក ។ ការជម្រះបញ្ជីនេះត្រូវបានបែងចែកចេញពីពាក្យ **ការរំលាយ** ដែលជាការបញ្ចប់អត្ថិភាពស្របច្បាប់របស់នីតិបុគ្គល (ក្រុមហ៊ុន) ។

ហេតុនេះក្រោយពីបានចេញវិញ្ញាបនបត្របញ្ជាក់ពីគោលបំណងនៃការរំលាយក្រុមហ៊ុន ដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវ៖

១.ផ្ញើរលិខិតជូនដំណឹងពីគោលបំណងនៃការរំលាយជាបន្ទាន់របស់ក្រុមហ៊ុន ទៅឲ្យម្ចាស់បំណុលរបស់ក្រុមហ៊ុន ឬឥណនទាយក

២.ចុះផ្សាយលិខិតជូនដំណឹងស្តីពីគោលបំណងនៃការរំលាយជាបន្ទាន់សម្រាប់រយៈពេល០២(ពីរ)សប្តាហ៍ជាប់គ្នានៅក្នុងសារព័ត៌មានដែលបានបោះផ្សាយ ឬចែកចាយក្នុងកន្លែងដែលក្រុមហ៊ុនមានទីស្នាក់ការចុះបញ្ជីពិតប្រាកដ ឬបោះពុម្ពផ្សាយដទៃទៀតដូចបានកំណត់ក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម[57] ។

ម្យ៉ាងវិញទៀតក្រោយពីបានចេញវិញ្ញាបនបត្រនៃបំណងនៃការរំលាយក្រុមហ៊ុនត្រូវមានភារកិច្ចមួយចំនួនដូចខាងក្រោម៖

១.ប្រមូលទ្រព្យសម្បត្តិទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម

២.រក្សាទុកទ្រព្យសម្បត្តិជាវត្ថុដែលមិនអាចធ្វើការបែងចែកទៅឲ្យម្ចាស់ហ៊ុន

៣.បំពេញកាតព្វកិច្ចទាំងអស់ដែលនៅសល់ ឬមិនទាន់បានបំពេញរួចរាល់

៤.ធ្វើសកម្មភាពផ្សេងៗទៀតដែលតម្រូវសម្រាប់ការជម្រះបញ្ជី ។

ក្រោយពីការទទួលបានដំណឹងពីការរំលាយ និងទទួលបានប្រាក់សំណងគ្រប់ ឬការបញ្ឈប់សកម្មភាពទាំងអស់របស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិដែលនៅសល់រួមមានទាំងកម្មសិទ្ធិជាសាច់ប្រាក់ ឬជាវត្ថុទៅឲ្យប្រាក់ហ៊ុនដែលមានសិទ្ធិទទួលទ្រព្យសម្បត្តិទាំងនោះ ។

អ្នកដាក់ពាក្យសុំត្រូវផ្តល់ឲ្យក្រសួងពាណិជ្ជកម្មនូវលិខិតជូនដំណឹងស្តីពីការអនុវត្ត ហើយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុនពាណិជ្ជកម្មមានសិទ្ធិបង្ហាញតុលាការដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង ។

លើសពីនេះទៅទៀតនីតិវិធីនៃការរំលាយ និងការជម្រះបញ្ជីខាងលើមិនត្រូវបានអនុវត្តចំពោះក្រុមហ៊ុនដែលដាក់ពាក្យសុំក្ស័យធនទៅតុលាការឡើយ ។

[57] មាត្រា២៥៤ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

# ជំពូកទី៣
# គុណសម្បត្តិ គុណវិបត្តិ
# បញ្ហាប្រឈម
# និងដំណោះស្រាយ

# ជំពូកទី៣
# គុណសម្បត្តិ គុណវិបត្តិ បញ្ហាប្រឈម និងដំណោះស្រាយ នៅក្នុងនីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា

## ផ្នែកទី១ គុណសម្បត្តិនៃការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា

### ១. ការវិនិយោគទុន

ការបង្កើតសហគ្រាសពាណិជ្ជកម្មនៅកម្ពុជា គឺត្រូវបានពឹងផ្អែកទាំងស្រុងលើការវិនិយោគទុនពីក្រៅប្រទេស ក៏ប៉ុន្តែមិនមែនមានន័យថានៅក្នុងប្រទេសមិនមានការវិនិយោគទុននោះទេ ។ កម្ពុជា ដែលជាប្រទេសមានទីផ្សារសេរី បើកទទួលរាល់ការវិនិយោគទុនពីគ្រប់ទិសទី ដែលជាកត្តាជំរុញសេដ្ឋកិច្ចជាតិឲ្យមានការរីកចម្រើន និងមានការកើនឡើងជាប្រចាំនៅក្នុងរយៈពេលចុងក្រោយនេះ ។ ការរីកចម្រើននេះ គឺជាសញ្ញាណថ្មីបន្ថែមទៀតពីការអភិវឌ្ឍប្រទេសជាតិឲ្យទទួលបានសេដ្ឋកិច្ចមធ្យម និងខ្ពស់ ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ។

លើសពីនេះទៅទៀត ការទាក់ទាញការវិនិយោគទុន គឺជាផ្នែកមួយយ៉ាងសំខាន់ដែលកម្ពុជាត្រូវការក្នុងការកសាងនឹងអភិវឌ្ឍន៍ប្រទេសឲ្យមានការរីកចម្រើន ប៉ុន្តែការទទួលបានការវិនិយោគទុនចូលមកវិនិយោគនៅកម្ពុជានេះ មិនមែនជារឿងងាយស្រួលនោះទេ ប្រសិនបើនីតិវិធីនៃការបង្កើតសហគ្រាសពាណិជ្ជកម្មនៅកម្ពុជាមានភាពសុាំញ៉ាំ និងស្មុគស្មាញដែលជាបញ្ហាចោទនោះ ។ ប៉ុន្តែយ៉ាងណាមិញនៅក្នុងនីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា តាមការរៀបរាប់ និងបកស្រាយខាងលើ គឺឃើញថាមិនសូវមានភាពសុាំញ៉ាំ និងស្មុគស្មាញនោះទេ ប៉ុន្តែត្រូវការអ្នកជំនាញ ផ្នែកពាណិជ្ជកម្មក្នុងការជួយសម្រួល និងត្រូវការស្វែងយល់បន្ថែម ទាំងបែបបទនៃការបង្កើតក្រុមហ៊ុន ក៏ដូចជាច្បាប់សហគ្រាសពាណិជ្ជកម្មជាដើម ដើម្បីជាសញ្ញាណឲ្យអ្នកវិនិយោគមានការទុកចិត្ត និងជឿជាក់ក្នុងការបង្កើតអាជីវកម្មនៅលើទឹកដីកម្ពុជា ។

### ២. ការចូលរួមជាមួយអាស៊ាន

បើក្រឡេកមើលពីអតីតកាលកម្ពុជា ជាប្រទេសមួយដែលគេស្គាល់ថាហែកហួរដោយសារសង្គ្រាម និងធ្លាប់ល្បីថាជាវាលពិឃាតជាតំបន់អសន្តិសុខ និងជាចម្ការមីន ដែលគេភ័យខ្លាចគ្រប់គ្នា បានប្រែក្លាយជារដ្ឋអធិបតេយ្យ និងឯករាជ្យ ដែលមានសន្តិភាពមាននីតិរដ្ឋ និងស្ថិរភាពនយោបាយ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និងមាន ព្រះមហាក្សត្រជាទីគោរពសក្ការៈគង់ប្រថាប់ជាម្លប់ ។

ការកែប្រែខ្លួនយ៉ាងឆាប់រហ័សនេះ គឺកើតតាមរយៈការធ្វើសមាហរណកម្មពេញលេញនៅក្នុងរចនាសម្ព័ន្ធ និងនិម្មាបនកម្មតំបន់ សកលបានដើរតួយ៉ាងសំខាន់ក្នុងការរក្សាសណ្តាប់ធ្នាប់ និងសន្តិភាពនៃសកលលោក ។ ពិសេសមូលដ្ឋានសេដ្ឋកិច្ចកម្ពុជា បានប្រែក្លាយពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្មតាមបែបប្រពៃណីទៅជាប្រទេសមានមូលដ្ឋានសេដ្ឋកិច្ចទូលាយ និងរឹងមាំ ដែលអាចចាប់យកឧស្សាហកម្មថ្មីៗ និងការវិនិយោគពី

ប្រទេសក្នុងតំបន់ និងអន្តរជាតិ ។

នៅក្នុងឱកាសប្រទេសកម្ពុជា បានចូលជាសមាជិកនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ឬហៅកាត់ថា **អាស៊ាន** កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ គឺជាមុខមាត់ថ្មីសម្រាប់កម្ពុជាព្រមជាមួយអត្ថប្រយោជន៍ និងជាឱកាសដែលកម្ពុជាអាចបង្កើតទីផ្សាររបស់ខ្លួននៅលើឆាកអន្តរជាតិ ជាមួយសមាជិកទាំងអស់នៅក្នុងតំបន់ ។ ការធ្វើទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសជាសមាជិកគឺកាន់តែសំខាន់ និងចំណេញសម្រាប់កម្ពុជាដែលជាឱកាសប្រកួតប្រជែងសេដ្ឋកិច្ចដ៏មានសារៈសំខាន់នៅក្នុងតំបន់ ។

### ៣. ការរីកចម្រើននៃទីផ្សារពាណិជ្ជកម្ម

ការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា មិនត្រឹមតែទទួលបានការវិនិយោគពីក្នុង និងក្រៅប្រទេសនោះទេការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនោះ ក៏បានធ្វើឲ្យកម្ពុជាក្លាយជាគូរប្រជែងមួយ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ឬហៅកាត់ថា អាស៊ាន បានស្គាល់និងបានដឹងពីកម្ពុជាកាន់តែច្បាស់នៅលើឆាកអន្តរជាតិតាមរយៈវិស័យពាណិជ្ជកម្មនេះ ។ ការបង្កើតឲ្យមានក្រុមហ៊ុនពាណិជ្ជកម្មច្រើននៅកម្ពុជា ជាសញ្ញាណថ្មីមួយក្នុងការប្រកួតប្រជែងគ្នារវាងពាណិជ្ជករ ដើម្បីរកបានប្រាក់ចំណេញពីការធ្វើពាណិជ្ជកម្មរបស់ខ្លួន ។

យើងបានដឹងរួចមកហើយថាប្រទេសកម្ពុជា នៅក្នុងវិស័យពាណិជ្ជកម្មនេះមានច្បាប់មួយដែលបានកំណត់យ៉ាងច្បាស់ និងជាក់លាក់ពីវិស័យមួយនេះ គឺច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ ដែលជាច្បាប់ដែលត្រូវបានអនុម័តឲ្យប្រើប្រាស់នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៥ ដែលជាច្បាប់មួយត្រូវបានបង្កើតឡើងក្នុងគោលបំណងឲ្យការប្រតិបត្តិការអាជីវកម្មនៅកម្ពុជាដែលត្រូវប្រព្រឹត្តតាមច្បាប់នេះជាគោល។ ច្បាប់នេះគ្របដណ្តប់គ្រប់ទម្រង់ទាំងអស់នៃអាជីវកម្ម ដែលបានប្រព្រឹត្ត ក៏ដូចជាបានធ្វើអាជីវកម្មរបស់ខ្លួននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ លើសពីនេះទៅទៀតច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ នេះក៏រាប់បញ្ចូលទាំងកម្មសិទ្ធិផ្តាច់មុខ ភាពជាដៃគូ និងសាជីវកម្ម ដែលត្រូវយកមកអនុវត្តន៍ផងដែរ ។

បន្ថែមពីនេះទៀត ការធ្វើអាជីវកម្មនេះក៏តម្រូវឲ្យមានបែបបទឲ្យម្ចាស់អាជីវកម្មបំពេញតាមដើម្បីជាការការពារនៅលើអាជីវកម្មរបស់ខ្លួន ដូចជាការចុះឈ្មោះអាជីវកម្មរបស់ខ្លួន ដើម្បីអាចដំណើរបានស្របច្បាប់ដែលការចុះឈ្មោះនោះតម្រូវឲ្យមានបែបបទ និងនីតិវិធីតាមច្បាប់កំណត់ ។

## ផ្នែកទី២ គុណសម្បត្តិនៃការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា

### ១. ប្រភពដើមទុន

នៅក្នុងវិស័យពាណិជ្ជកម្ម ដើមទុនជាកត្តាសំខាន់មួយក្នុងចំណោមកត្តាផ្សេងៗទៀតដែលម្ចាស់អាជីវកម្មចាំបាច់ត្រូវតែមានមិនអាចខ្វះបាន ព្រោះនេះជាដំណាក់ដំបូងមុនពេលចាប់ផ្តើមអាជីវកម្មរបស់ខ្លួន ។

## ១.១ ធនាគារ និងស្ថាប័នហិរញ្ញវត្ថុ

ធានាគារ ឬស្ថាប័នហិរញ្ញវត្ថុជាច្រើននៅកម្ពុជា បាននឹងកំពុងដើរតួយ៉ាងសំខាន់នៅក្នុងការផ្តល់ដើមទុនទាំងនោះ ដល់ម្ចាស់អាជីវកម្មសហគ្រាស និងវិនិយោគិនកំពុងត្រូវការក្នុងការបង្កើតអាជីវកម្មដោយខ្លួនឯង។ ការផ្តល់ឥណទានពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុក្នុងស្រុកនេះ បាននាំមកនូវឱកាសមួយក្នុងការបង្កើតអាជីវកម្មដល់ម្ចាស់អាជីវកម្មសហគ្រាស និងវិនិយោគិន ។ ឥណទានទាំងនោះ អាចខ្លះជាឥណទានខ្នាតតូច ឬអាចហៅកាត់ថា Microfinace និងឥណទានខ្លះជាឥណទានខ្នាតធំ ដែលការផ្តល់ឲ្យនេះពីធានាគារ ឬស្ថាប័នហិរញ្ញវត្ថុ ។ ប៉ុន្តែម្ចាស់អាជីវកម្មសហគ្រាស និងវិនិយោគិនក៏បានដឹង និងបានគិតទុកជាមុនរួចជាសម្រេចនូវហានិភ័យដែលអាចកើតឡើងដោយសារការយកឥណទានពីធានាគារ និងស្ថាប័នហិរញ្ញវត្ថុមកធ្វើជាដើមទុន ក្នុងការបើកអាជីវកម្មរបស់ខ្លួន ។

លើសពីនេះទៅទៀត ម្ចាស់អាជីវកម្មសហគ្រាស និងវិនិយោគិន បានដឹងរួចមកហើយថា ឥណទានដែលបានមកពីធនាគារ ឬស្ថាប័នហិរញ្ញវត្ថុគឺចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌតម្រូវយ៉ាងតឹងតែង និងមានភាពស្មុគស្មាញក្នុងការទទួលបានឥណទាននោះ ជាក់ស្តែងដូចជាការដាក់ប្លង់(អចលនវត្ថុ)សម្រាប់ការធានាលើឥណទាននោះជាដើម ។

ហេតុនេះម្ចាស់អាជីវកម្មសហគ្រាស និងវិនិយោគិន ពិតជាពិបាកណាស់ក្នុងការសម្រេចគិតពីការជ្រើសរើសដើមទុនអាជីវកម្មរបស់ខ្លួន និងធានាហានិភ័យអាជីវកម្មរបស់ខ្លួន ដើម្បីអាចបើកដំណើរការអាជីវកម្មរបស់ខ្លួន ដូចនេះយើងបានដឹងហើយថា ដើមទុនសម្រាប់ដំណើរការអាជីវកម្ម ពិតជាសំខាន់ដែលមិនអាចខ្វះបាន ប៉ុន្តែការជ្រើសរើសដើមទុនមកធ្វើអាជីវកម្ម គឺរឹតតែសំខាន់សម្រាប់ម្ចាស់អាជីវកម្មសហគ្រាស និងវិនិយោគិនព្រោះដើមទុននេះបើម្ចាស់អាជីវកម្មសហគ្រាស និងវិនិយោគិនជ្រើសរើសត្រូវអាចធ្វើឲ្យអាជីវកម្មមានការរីកចម្រើន និងអភិវឌ្ឍន៍ទៅមុខ ប៉ុន្តែប្រសិនបើម្ចាស់អាជីវកម្មសហគ្រាស និងវិនិយោគិនជ្រើសរើសដើមទុននេះខុស នឹងធ្វើឲ្យការបើកដំណើរការអាជីវកម្ម នឹងមិនទទួលបានការរីកចម្រើន និងមានហានិភ័យខ្ពស់ថែមទៀត ។

## ១.២ វិនិយោគបរទេស

ជម្រើសនៃការជ្រើសរើសដើមទុនរបស់ម្ចាស់អាជីវកម្មសហគ្រាស និងវិនិយោគិនមានច្រើនមិនថាការជ្រើសរើសដើមទុន តាមរយៈឥណទានផ្ទាល់ពីខាងធានាគារ ឬស្ថាប័នហិរញ្ញវត្ថុ ឬដើមទុនដែលជាការវិនិយោគពីបរទេសនោះទេ គឺសុទ្ធតែសំខាន់ និងទទួលបានការរីកចម្រើន ប្រសិនបើម្ចាស់អាជីវកម្មសហគ្រាស និងវិនិយោគិនអាចព្យាករណ៍បានពីហានិភ័យ និងការចេះរៀបចំប្រព័ន្ធហិរញ្ញវត្ថុអាជីវកម្មឲ្យបានត្រឹមត្រូវ និងមានរយៈពេលវែងនៅពេលអនាគត ។ ការវិនិយោគបរទេស ចូលមកកម្ពុជាមានចំនួនជាច្រើនលើវិស័យផ្សេងៗគ្នាជាច្រើនដែលនៅក្នុងនោះក៏មានវិស័យពាណិជ្ជកម្មផងដែរ ដែលជាហេតុនាំឲ្យម្ចាស់អាជីវកម្មសហគ្រាស និងវិនិយោគិនមាន

ឱកាសក្នុងការទាក់ទាញវិនិយោគទុនពីបរទេសមកពីការវិនិយោគលើអាជីវកម្មរបស់ខ្លួន ឬជាដៃគូរសហការគ្នាក្នុងអាជីវកម្ម ថែមទៀតផង ។

ទោះបីជាយ៉ាងណាក្តី ការវិនិយោគពីបរទេស ដែលជាប្រភពដើមទុនមួយយ៉ាងសំខាន់មកលើវិស័យពាណិជ្ជកម្មនៅកម្ពុជានេះ ក៏បានជៀសឥទ្ធិពលមិនល្អជាច្រើនមកលើម្ចាស់អាជីវកម្ម សហគ្រាស និងវិនិយោគិនផងដែរ ។ ដោយមូលហេតុថាប្រទេសកម្ពុជាមានកម្រិតសេដ្ឋកិច្ចមធ្យម និងឈានដល់កម្រិតខ្ពស់នៅពេលអនាគត ប៉ុន្តែការវិនិយោគបរទេសមិនបានសិក្សាឲ្យបានស៊ីជម្រៅ និងមិនបានសិក្សាពីទិសដៅសេដ្ឋកិច្ចនាពេលអនាគតរបស់កម្ពុជាដែលជាមូលហេតុនាំឲ្យការវិនិយោគនោះមិនទទួលបានប្រាក់ចំណេញ និងមានហានិភ័យខ្ពស់សម្រាប់ម្ចាស់អាជីវកម្មសហគ្រាសនិងវិនិយោគិន ដែលជាម្ចាស់ទីតាំងនៅកម្ពុជា ។

ការវិនិយោគទុនពីបរទេស គឺជាដើមទុនពាណិជ្ជកម្មមួយយ៉ាងសំខាន់នៅកម្ពុជា ដែលមានសក្កានុពល និងឱកាសជាច្រើនដល់ម្ចាស់អាជីវកម្មសហគ្រាស និងវិនិយោគិន ក៏ប៉ុន្តែការចេះគ្រប់គ្រងហិរញ្ញវត្ថុដែលមានសារៈសំខាន់ និងចាំបាច់ជាទីបំផុតសម្រាប់ ម្ចាស់អាជីវកម្ម សហគ្រាស និងវិនិយោគិន ដើម្បីកំណត់ និងធានាថាដើមទុនដែលបានមកពីការវិនិយោគនោះអាចយកមកប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព នៅក្នុងដំណើរការអាជីវកម្ម និង កំណត់ពីការវិនិយោគទុននោះឲ្យទទួលបានការរីកចម្រើន និងទិសដៅក្នុងការអភិវឌ្ឍនៅពេលអនាគត ។

## ១.៣ ដើមទុនផ្ទាល់ខ្លួន

ជាការពិតណាស់ ការចាប់ផ្តើមអាជីវកម្ម គឺពឹងផ្អែកទាំងស្រុងទៅលើទំហំនៃដើមទុន និងគោលបំណងនៃអាជីវកម្ម ហេតុនេះហើយមុនពេលចាប់ផ្តើមអាជីវកម្មមួយៗ ម្ចាស់អាជីវកម្ម សហគ្រាស និងវិនិយោគិន បានគិតគូរយ៉ាងល្អិតល្អន់ ពីទំហំនៃដើមទុន និងហានិភ័យដែលអាចកើតមានចំពោះអាជីវកម្មរបស់ខ្លួន ។ ហេតុនេះហើយម្ចាស់សហគ្រាស បានគិតពិចារណាគ្រប់ជ្រុងជ្រោយមុនពេលដែលសម្រេចថាគួរជ្រើសរើសដើមទុនមួយណាដែលជាដើមល្អ និងសមស្របតាមអាជីវកម្មរបស់ខ្លួន ដែលដើមទុនទាំងនោះអាចបានមកពីឥណទានពីធានាគារ ឬស្ថាប័នហិរញ្ញវត្ថុ ឬបានមកពីការវិនិយោគបរទេស ឬជាដើមទុនផ្ទាល់ខ្លួនរបស់ម្ចាស់អាជីវកម្ម សហគ្រាស និងវិនិយោគិន ជាដើម ។

ហេតុនេះហើយការចាប់ផ្តើមអាជីវកម្មជាមួយដើមទុនផ្ទាល់ខ្លួន គឺជាការល្អមួយក្នុងការរួចផុតពីហានិភ័យជាច្រើនក្នុងអាជីវកម្មរបស់ខ្លួន ប៉ុន្តែគឺមានភាគរយតិចណាស់ដែលម្ចាស់អាជីវកម្ម ឬអ្នកចង់ធ្វើអាជីវកម្មមានដើមទុនផ្ទាល់ដែលជារបស់ខ្លួនក្នុងការបង្កើតអាជីវកម្មរបស់ខ្លួនបាន ជាក់ស្តែងតាមការសង្កេតឃើញ គឺភាគច្រើនមានដើមទុនផ្ទាល់ខ្លួនពាក់កណ្តាល និងដើមទុនពីការខ្ចីឥណទានពាក់កណ្តាលដើម្បីបង្កើតអាជីវកម្ម ។

## ២. ការទាមទារផ្នែកច្បាប់

បើនិយាយពីក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា ចាប់តាំងពីការចាប់ផ្តើមការដំណើរការ ឬការប្រព្រឹត្តទៅ

រហូតដល់ពេលបញ្ចប់ គឺត្រូវការទាមទារផ្នែកច្បាប់សំខាន់បំផុតមិនអាចខ្វះបានក្នុងការធានាថាក្រុមហ៊ុនបានអនុវត្តតាមច្បាប់របស់កម្ពុជា និងមិនផ្ទុយពីបញ្ញត្តិច្បាប់ជាធរមាន ។ លើសពីនេះទៀតការបានស្វែងយល់ពីច្បាប់នៅក្នុងប្រទេសមួយបានល្អិតល្អន់ និងស៊ីជម្រៅជារឿងដែលល្អ និងងាយស្រួលបំផុតក្នុងការប្រកបអាជីវកម្មនៅលើប្រទេសដែលយើងបានសិក្សាច្បាប់នោះ ។ ហេតុនេះហើយបញ្ហាផ្នែកច្បាប់ ជារឿងដែលសំខាន់មួយដែលមិនអាចខ្វះបានឡើយនៅក្នុងការដំណើរការរបស់អាជីវកម្ម ។ ក្រុមហ៊ុនពាណិជ្ជកម្ម គឺចាំបាច់ត្រូវមានអ្នកច្បាប់ ឬផ្នែកច្បាប់របស់ក្រុមហ៊ុន ដែលជាក្រុមមនុស្សដ៏សំខាន់សម្រាប់ក្រុមហ៊ុន ដែលអាចហៅថាជា **អ្នកពិភាក្សា** ផ្នែកច្បាប់ និងប្រឹក្សាដ៏សំខាន់បំផុត ដើម្បីឲ្យម្ចាស់អាជីវកម្ម មានភាពងាយស្រួលក្នុងការសម្រេចចិត្តពេលក្រុមហ៊ុនមានបញ្ហា និងជាក្រុមមនុស្សដែលជួយដោះស្រាយបញ្ហារបស់ក្រុមហ៊ុនពេលក្រុមហ៊ុនជួបបញ្ហា ឬវិវាទផ្សេងៗ ។

## ៣. ការប្រកួតប្រជែង ការបង់ពន្ធ និងហានិភ័យ

ការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម គឺពិតជាបានបង្ហាញពីការងារអភិវឌ្ឍន៍ និងរីកច្រើនលើវិស័យពាណិជ្ជកម្មនៅកម្ពុជា ក៏ប៉ុន្តែទន្ទឹមនឹងនោះផងដែរការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មច្រើននាំឲ្យ ការប្រកួតប្រជែងក៏មានកាន់តែច្រើនដែលជាការពិបាកមួយដល់ក្រុមហ៊ុនដែលទើបតែបង្កើតថ្មីជាមួយក្រុមហ៊ុនដែលមានអាយុកាលជាយូរ និងបានឈរជើងយ៉ាងរឹងមាំ ។ ហេតុនេះហើយ ការបង្កើតក្រុមហ៊ុន គឺពិតណាស់ត្រូវការអ្នកមានបទពិសោធន៍នៅក្នុងការដឹកនាំក៏ដូចជាមានចំណេះជំនាញលើវិស័យពាណិជ្ជកម្មនេះយ៉ាងស្ទាត់ជំនាញ ផ្គួបផ្សំជាមួយការងារដឹកនាំការបញ្ហា មានភាពច្បាស់លាស់ ទើបក្រុមហ៊ុនទទួលបានលទ្ធផលល្អនៅក្នុងអាជីវកម្ម ។

លើសពីនេះទៀត ការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មក៏ចាំបាច់ និងមិនអាចរំលងបានលើការបង់ពន្ធដែលជាកម្រៃសេវា ទាំងផ្នែករដ្ឋបាលទូទៅ ពន្ធប៉ាតង់ និងថ្លៃសេវាផ្សេងៗជាដើម ។ ការបង់ពន្ធទាំងអស់នេះត្រូវបានកំណត់ជាកាតព្វកិច្ចរបស់ក្រុមហ៊ុនពាណិជ្ជកម្មនីមួយៗ ដែលតម្រូវឲ្យមានការបង់ជូនរដ្ឋជាប្រចាំ មូលហេតុនេះហើយដែលអ្នកគ្រប់គ្រងក្រុមហ៊ុន ឬម្ចាស់អាជីវកម្មត្រូវធានាបានថា អាជីវកម្មរបស់ខ្លួនត្រូវបានបង់ពន្ធជូនរដ្ឋបានទៀងទាត់ និងគ្រប់ចំនួន ដែលផ្នែកសំខាន់របស់ក្រុមហ៊ុន គឺផ្នែកហិរញ្ញវត្ថុត្រូវធានាថាបានរៀបចំបញ្ជីនៅក្នុងការបង់ពន្ធ សេវាផ្សេងៗនេះបានត្រឹមត្រូវ និងច្បាស់លាស់ ដើម្បីធានាដល់ការធ្វើអាជីវកម្មរបស់ខ្លួនបន្ត និងពេលអនាគត ។ ការបង់ពន្ធ និងថ្លៃសេវាផ្សេងៗនេះភាគច្រើន គេសង្កេតឃើញថាក្រុមហ៊ុនពាណិជ្ជកម្មដែលទើបង្កើតថ្មីគឺត្រូវទទួលបន្ទុកច្រើនលើកិច្ចការទាំងអស់នេះ ដើម្បីឲ្យក្រុមហ៊ុនពាណិជ្ជកម្មដែលទើបបង្កើតរបស់ខ្លួនត្រូវបានគោរពតាមលក្ខខណ្ឌច្បាប់ និងលក្ខខណ្ឌទម្រង់បានត្រឹមត្រូវ ក្នុងការប្រកបអាជីវកម្ម ។

នៅក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម បានបង្ហាញឲ្យឃើញថាពេលខ្លះទទួលបានប្រាក់ចំណេញច្រើនជាងប្រាក់ចំណាយរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ប៉ុន្តែក៏គេសង្កេតឃើញថាក្រុមហ៊ុនពាណិជ្ជកម្ម ដែលបានបង្កើតឡើងមួយចំនួនក៏ត្រូវបានផ្អាក ឬបញ្ចប់អាជីវកម្មរបស់ខ្លួនមុនកំណត់ផងដែរ ។ ក្នុងករណីនេះបង្ហាញថាក្រុមហ៊ុន

ពាណិជ្ជកម្ម នៅក្នុងការប្រកបអាជីវកម្ម គឺមានផ្លូវពីរដែលមិនអាចគេចផុតបានគឺ ការខាតបង់ និងការទទួលបានប្រាក់ចំណេញពីអាជីវកម្មរបស់ខ្លួន ។ ហេតុនេះហើយក្រុមហ៊ុនអាជីវកម្ម ត្រូវតែធានាឲ្យបានក្នុងការខាតបង់របស់ក្រុមហ៊ុន ពិសេសក្រុមហ៊ុនពាណិជ្ជកម្ម ដែលទើបបង្កើតថ្មីដែលមិនទាន់មានអតិថិជន ឬមានការគាំទ្រច្រើនដែលជាហេតុនាំឲ្យប្រឈមនឹងការខាតបង់ ជាជាងទទួលបានប្រាក់ចំណេញពីអាជីវកម្មរបស់ខ្លួន ។ ពិសេសជាងនេះក្រុមហ៊ុនអាជីវកម្ម ត្រូវតែមានផែនការអាជីវកម្មរបស់ខ្លួនឲ្យបានល្អ ល្អិតល្អន់ជាទីបំផុតដើម្បីធានាហានិភ័យដែលកើតមានអំឡុងពេលដំណើរការអាជីវកម្មរបស់ខ្លួន ក្នុងការធានាឲ្យបានដល់ដំណើរការ និងស្ថេរភាពរបស់ក្រុមហ៊ុន ប្រសិនបើក្រុមហ៊ុនមានផែនការ និងមានចង្អុលច្បាស់លាស់ក្នុងវិស័យច្បាប់ក្នុងការប្រកបអាជីវកម្មក្រុមហ៊ុនអាជីវកម្មនោះនឹងទទួលបានប្រាក់ចំណេញ ដែលជាដើមទុនបន្ថែមក្នុងការដំណើរការអាជីវកម្មរបស់ខ្លួនទៅពេលអនាគត ។

## ផ្នែកទី៣ បញ្ហាប្រឈមនៃការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា

## ១.បញ្ហាប្រឈមក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងមានកម្រិត

ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មានឃើញថាមានអត្ថប្រយោជន៍ជាច្រើន ប៉ុន្តែវាតែងតែមាននៅបញ្ហាប្រឈមជាច្រើនផងដែរ ដែលយើងចាំបាច់បំផុតត្រូវគិតគូរផងដែរ ។ នេះជាប្រឈមមួយចំនួនដែលកើតមាន៖

- ការទទួលខុសត្រូវគ្មានដែនកំណត់ សហគ្រិនទាំងអស់ដែលស្ថិតក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវទទួលខុសត្រូវផ្ទាល់ ចំពោះបំណុល និងបញ្ហាផ្សេងៗ របស់ក្រុមហ៊ុនដោយគ្មានដែនកំណត់។ នេះមានន័យថាប្រសិនបើក្រុមហ៊ុនមានបំណុលនោះ សហគ្រិនអាចត្រូវបានប្រើប្រាស់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនដើម្បីសងបំណុលនោះផងដែរ ។
- ការគ្រប់គ្រងសម្របសម្រួលក្នុងការគ្រប់គ្រង ការសម្រេចចិត្តក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវការការសម្របសម្រួលល្អរវាងសហគ្រិនទាំងអស់ ។ ប្រសិនបើការខ្វះការយល់ព្រមអាចនាំឲ្យមានភាពតានតឹងនឹងមានបញ្ហាផ្សេងៗទៀត ។
- ការប្រមូលមូលនិធិ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅអាចមានការលំបាកក្នុងការប្រមូល នៅមូលនិធិពីអ្នកវិនិយោគ ពីព្រោះវាមិនមានស្ថាប័នផ្លូវការដូចក្រុមហ៊ុនសាធារណៈ ។
- ការផ្តាច់សម្ព័ន្ធភាព ប្រសិនបើមានសហគ្រិន ម្នាក់ណាចាកចេញ ឬស្លាប់ វាអាចនាំឲ្យមានការផ្តាច់សម្ព័ន្ធភាពទាំងមូល ។

តាមជាក់ស្តែង បញ្ហាប្រឈមដែលសំខាន់បំផុតនោះ គឺការខ្វះខាតលិខិតបទដ្ឋានគតិយុត្ត បញ្ហានយោបាយ និង បញ្ហាសេដ្ឋកិច្ច ។

## ២ បញ្ហាប្រឈមនៃការខ្វះខាតលិខិតបទដ្ឋានគតិយុត្ត

បញ្ហាប្រឈម នៃការខ្វះខាតលិខិតបទដ្ឋានគតិយុត្តក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតការខ្វះខាតច្បាប់អាចមានច្បាប់ និងបទបញ្ជាដែលមិនច្បាស់លាស់ ឬមិនទាន់សម័យ ដែលកំណត់អំពីការបង្កើត និងការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ការខ្វះខាតផ្នែកច្បាប់សម្រាប់ការពារអ្នកវិនិយោគ និងការជាក់ស្តែងអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់មេដឹកនាំ និងសមាជិកក្រុមហ៊ុន។ ការខ្វះរបៀប និងបទបញ្ជាសម្រាប់ការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត អាចនឹងមានការប្រឈមមុខ ជាមួយការមិនស្របច្បាប់ ឬការចុះបញ្ជីដែលមិនទាន់សម័យ។ ការស្វែងរក និងការចុះកិច្ចសន្យាជាមួយអាជ្ញាធរមានសមត្ថកិច្ចអាចមានភាពស្មុគស្មាញ និងមិនច្បាស់លាស់។ ការដោះស្រាយបញ្ហាអំពីកិច្ចសន្យា និងសិទ្ធិរបស់សមាជិកក្នុងការគ្រប់គ្រងក្រុមហ៊ុនអាចមានភាពពិបាក។ ការបង្កើតគោលការណ៍ និងបច្ចេកទេសសម្រាប់ការអនុវត្តការងារ ក្នុងក្រុមហ៊ុនអាចមានការខ្វះខាត ឬមិនទាន់សម័យ។ ការបង្កើតសមត្ថភាពក្នុងការគ្រប់គ្រងទិន្នន័យ និងការប្រកាសព័ត៌មានរបស់ក្រុមហ៊ុនអាចមានការលំបាក ។

នៅក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ បានបណ្តោយឲ្យជួបនឹងបញ្ហាប្រឈមជាច្រើន ព្រោះការខ្វះខាតលិខិតបទដ្ឋានគតិយុត្ត ទាក់ទងទៅនឹងច្បាប់និងបទប្បញ្ញត្តិសំខាន់ៗ ។ នេះជាបញ្ហាប្រឈមមួយចំនួនដែលអាចកើតមាន៖

- ការរក្សាកំណត់ត្រា និងកិច្ចសន្យាប្រសិនបើគ្មានការបញ្ជាក់ច្បាស់លាស់លើបែបបទនៃកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលអាចបង្កការភាន់ច្រឡំក្នុងការបែងចែកអំណាចនិងទំនួលខុសត្រូវរបស់សហគ្រិនការរក្សាកំណត់ត្រា និងការគ្រប់គ្រង ហិរញ្ញវត្ថុអាចមានភាពមិនប្រក្រតីដោយសារគ្មានបទប្បញ្ញត្តិច្បាស់លាស់ ។
- ការខ្វះខាតផ្នែកច្បាប់សម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺថានៅកម្ពុជាមានច្បាប់ជាច្រើនសម្រាប់ការគ្រប់គ្រង និងការចុះបញ្ជីក្រុមហ៊ុនជាពិសេសសម្រាប់ក្រុមហ៊ុនឯកជន និងក្រុមហ៊ុនផ្សេងៗទៀតប៉ុន្តែសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនៅតែមានការខ្វះខាត។
- បទបញ្ជាសម្រាប់ ការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅអាចមានភាពមិនច្បាស់លាស់ ឬមិនបានធ្វើឲ្យទាន់សម័យ ដែលធ្វើឲ្យមានបញ្ហាផ្សេងៗក្នុងការបង្កើត និងគ្រប់គ្រង។
- ប្រព័ន្ធក្នុងការ ចុះបញ្ជីរបស់រាជរដ្ឋាភិបាលអាចមិនបានរួមបញ្ចូល នូវការសំដៅពិសេសសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលអាចធ្វើឲ្យមានបញ្ហាក្នុងការចុះបញ្ជីនិងការអនុវត្តច្បាប់សម្រាប់ក្រុមហ៊ុននោះ។
- ការយល់ដឹងរបស់ប្រជាជន និងមន្ត្រីរដ្ឋាភិបាលអំពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅអាចនិងមានភាពតិចតួចដែលធ្វើឲ្យមានការយល់ច្រឡំ និងការពិបាកក្នុងការអនុវត្តច្បាប់។

## ៣ បញ្ហាប្រឈមនៃកង្វះធនធានមនុស្ស និងថវិកា

បច្ចុប្បន្នយើងសង្កេតឃើញថាកំណើនសេដ្ឋកិច្ចកម្ពុជា ជាសញ្ញាណថ្មីមួយនៅក្នុងវិស័យពាណិជ្ជកម្ម ដែលជាវិស័យសំខាន់របស់កម្ពុជា ។ កត្តានេះហើយបានធ្វើឲ្យប្រទេសកំពុងអភិវឌ្ឍន៍ដូចកម្ពុជា ត្រូវការធនធានមនុស្សជាចាំបាច់នៅក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិឲ្យកាន់តែរីកច្រើន បញ្ហាប្រឈមនៃធនធានមនុស្សមានដូចជា៖

ធនធានមនុស្ស ក៏ត្រូវបានកត់សម្គាល់ថាជាបញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាជាច្រើនទៀតនៅក្នុងផ្នែកពាណិជ្ជកម្ម ដែលជាបញ្ហាដ៏គួរឲ្យព្រួយបារម្ភ នឹងប្រឈមជាងខ្លាំងនៅក្នុងផ្នែកពាណិជ្ជកម្ម ។ ធនធានមនុស្ស គឺពិតជាសំខាន់នៅក្នុងការកសាងប្រទេសជាតិ លើគ្រប់វិស័យ មិនថាតែវិស័យពាណិជ្ជកម្មតែមួយនោះទេ គឺជាតម្រូវចាំបាច់ដែលមិនអាចខ្វះបានលើគ្រប់វិស័យ ។ ប៉ុន្តែជាក់ស្តែងនៅកម្ពុជា ជាពិសេសនិស្សិតគឺមិនសូវមានចំណាប់អារម្មណ៍ ឬផ្តោតការយកចិត្តទុកដាក់សិក្សាស្រាវជ្រាវលើផ្នែកពាណិជ្ជកម្មនេះប៉ុន្មានទេ ជាមូលហេតុធ្វើឲ្យខ្វះខាតលើធនធានមនុស្សផ្នែកពាណិជ្ជកម្មនេះជាច្រើន ។ លើសពីនេះទៅទៀត ធនធានមនុស្សក្នុងផ្នែកពាណិជ្ជកម្មនេះ គឺបានដើរតួយ៉ាងសំខាន់ក្នុងការធ្វើពាណិជ្ជកិច្ច ការងារគ្រប់គ្រង ការងារដឹកនាំ របស់ក្រុមហ៊ុនពាណិជ្ជកម្ម ។ ការបណ្តុះបណ្តាលបុគ្គលិក ដែលមានជំនាញនិងការងារបច្ចេកទេស នៅកម្ពុជាមិនទាន់មានគ្រប់គ្រាន់ដែលអាចបញ្ចូលទៅក្នុងក្រុមហ៊ុន។ កង្វះការអប់រំ និងការបណ្តុះបណ្តាលអាជីវកម្មដែលមានគុណភាពអាចធ្វើឲ្យបញ្ហាក្នុងការអភិវឌ្ឍន៍អាជីវកម្ម ។

ចំណែកបញ្ហាធនធានថវិកា អាចត្រូវបាននិយាយថាជាសរសៃឈាមនៅលើគ្រប់វិស័យមិនថាវិស័យរដ្ឋ ឬវិស័យឯកជន ។ ធនធានថវិកា ឬថវិកាបានដើរតួយ៉ាងសំខាន់ជាទីបំផុតក្នុងការងារកសាង និងអភិវឌ្ឍន៍ស្ថាប័ន ឬអង្គភាព ហេតុនេះហើយប្រសិនបើស្ថាប័ន ឬអង្គភាពនោះពុំមានលទ្ធភាព ឬថវិកាទ្រទ្រង់នោះទេ គឺពុំអាចប្រតិបត្តិការ ឬដំណើរការបាននោះទេ ។ នៅក្នុងផ្នែកពាណិជ្ជកម្ម ធនធានថវិកា ត្រូវបានគិតគូរយ៉ាងល្អិតល្អន់ និងត្រូវបានរៀបចំផែនការចំណូល ចំណាយមានភាពច្បាស់លាស់ទៅពេលអនាគត ដែលជាការគិតគូររបស់ម្ចាស់អាជីវកម្ម ក្នុងការធ្វើពាណិជ្ជកិច្ចរបស់ខ្លួន ។ ដូច្នេះហើយធនធានថវិកានេះជាបញ្ហាប្រឈមនៅក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា ដែលជាបញ្ហាដែលម្ចាស់អាជីវកម្ម សហគ្រាស ត្រូវតែរៀបចំផ្នែកហិរញ្ញវត្ថុនេះឲ្យបានត្រឹមត្រូវស្របតាមទិសដៅសេដ្ឋកិច្ចរបស់កម្ពុជា និងត្រូវមានធនធានបម្រុងនៅក្នុងពេលប្រទេសជួបបញ្ហាសេដ្ឋកិច្ច ។ ជាក់ស្តែងបញ្ហាវិបត្តិជាសកលនៃជំងឺកូវីដ ១៩ ក្នុងអំឡុងឆ្នាំ២០២០ បានធ្វើឲ្យប៉ះពាល់ដល់សហគ្រាសពាណិជ្ជកម្ម និងក្រុមហ៊ុនជាច្រើននៅកម្ពុជា ដោយមូលហេតុមិនបានបម្រុងទុកនៅធនធានថវិកានៅក្នុងក្រុមហ៊ុនសម្រាប់បញ្ហានេះ ។

## ៤ បញ្ហាប្រឈមនៃសេដ្ឋកិច្ច

ការបង្កើតក្រុមហ៊ុន នៅកម្ពុជាបានជួបនឹងបញ្ហាប្រឈម ជាច្រើនដែលទាក់ទងនឹងសេដ្ឋកិច្ច ។ បញ្ហាប្រឈមទាក់ទងនឹងសេដ្ឋកិច្ចរួមមាន៖ ការអភិវឌ្ឍឥណទាននិងការវិនិយោគ ការទទួលបានឥណទាន និងធនធានហិរញ្ញវត្ថុអាចមានការលំបាកដោយសារការខ្វះប្រព័ន្ធមូលនិធិឥណទាន សម្រាប់អាជីវកម្មខ្នាតតូច និងខ្នាតមធ្យម ។ ការវិនិយោគទូទៅអាចមានការមិនច្បាស់លាស់ដោយសារអត្រាការប្រាក់ខ្ពស់ និងការអះអាងហិរញ្ញវត្ថុមានភាពមិនប្រក្រតី ។ ក្នុងនោះផងដែរការប្រកួតប្រជែងក្នុងទីផ្សារ ក៏អាចជាបញ្ហាផងដែរព្រោះការប្រកួតប្រជែងក្នុងទីផ្សារសេរី អាចមានការរងផលប៉ះពាល់ដោយសារតម្រូវការ និងសមត្ថភាពប្រកួតប្រជែងខ្ពស់ពីអាជីវកម្មផងដែរ ។រីឯស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក វាពិតជាមានការប្រែប្រួលជាខ្លាំងនៃស្ថានភាពសេដ្ឋកិច្ចជាតិ និងអន្តរជាតិដែលអាចបង្កការ រងផលប៉ះពាល់ដល់អាជីវកម្ម។ អត្រាមិនមានការងារធ្វើច្រើន អាចបង្កមានការទូទាត់ប្រាក់ខ្ពស់ និងមានបញ្ហាគ្មានស្ថិរភាពក្នុងការចំណាយ។ ការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ និងចំណូលចេញមិនបានប្រកបដោយប្រសិទ្ធភាពអាចបង្កការរងផលប៉ះពាល់ដល់ការរីកចម្រើនអាជីវកម្ម ។

បញ្ហាប្រឈមទាក់ទងនឹងសេដ្ឋកិច្ចរួមមានការរកឥណទានសម្រាប់គម្រោងអាជីវកម្មមិនមែនជារឿងដែលងាយស្រួលទេ ដោយសារទីផ្សារហិរញ្ញវត្ថុមានការកំណត់ និងការអត់ផ្តត់ជូនឥណទានខ្ពស់ ។ ស្ថានភាពសេដ្ឋកិច្ចអាចបង្កការខាតបង់ ដល់ក្រុមហ៊ុនដោយសារការប្រែប្រួលនៃតម្លៃបង្ហាញ និងតម្លៃផ្គត់ផ្គង់នៅក្នុងស្រុក និងទៅតាមតំបន់ ។ ស្ថានភាពអន្តរជាតិនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មអាចមានការប៉ះពាល់ដល់ការនាំចូល និងនាំចេញទំនិញរបស់ក្រុមហ៊ុន ។ ការប្រកួតប្រជែងពីក្រុមហ៊ុនទាំងក្នុងស្រុក និងអន្តរជាតិអាចជាបញ្ហាប្រឈមសំខាន់ដោយសារក្រុមហ៊ុនសហកម្មមានកម្រិតត្រូវប្រជែងទាំងតម្លៃ និងគុណភាព។ ការអភិវឌ្ឍន៍ក្នុងការគាំទ្ររបស់រដ្ឋាភិបាលដល់ក្រុមហ៊ុនមូលដ្ឋានអាចមានការកំណត់ និងមិនគ្រប់គ្រាន់ ។

# ផ្នែកទី៤ ដំណោះស្រាយនៃការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា

## ១.លិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្តជាឯកសារសំខាន់ និងចាំបាច់បំផុតនៅគ្រប់នីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា ដោយមូលហេតុថាលិខិតបទដ្ឋានគតិយុត្ត ប្រៀបបាននឹងត្រីវិស័យក្នុងការចង្អុលបង្ហាញក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា ។ គ្រប់បណ្តាលប្រទេសទាំងអស់សុទ្ធតែមានលិខិតបទដ្ឋានគតិយុត្តរៀងៗខ្លួនក្នុងការរៀបចំប្រទេសរបស់ខ្លួន នៅក្នុងនោះដែរកម្ពុជាក៏ជាប្រទេសដែលមួយដែលមានឯកសារគតិយុត្តដែលជារបស់ខ្លួនផងដែរ ក៏ប៉ុន្តែប្រទេសកម្ពុជាពីអតីតកាលជាប្រទេសដែលញាំញីទៅដោយសង្គ្រាមរ៉ាំរ៉ៃអស់ជាង៣សតវត្ស ដែលជាមូលហេតុមួយក្នុងចំណោម មូលហេតុផ្សេងទៀតធ្វើឲ្យប្រទេសកម្ពុជាកង្វះខាតនូវឯកសារគតិយុត្តជាច្រើនជាពិសេសផ្នែកពាណិជ្ជកម្មនេះតែម្តង ។

បញ្ហាលិខិតបទដ្ឋានគតិយុត្តសម្រាប់ក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជាគឺជាកត្តាសំខាន់បំផុតដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ហេតុនេះយើងគួរគិតពិចារណាអំពីដំណោះស្រាយមួយចំនួនដែលមានដូចខាងក្រោម ៖

- រដ្ឋាភិបាលកម្ពុជាត្រូវកំណត់ច្បាប់ និងបទបញ្ញាច្បាស់លាស់សម្រាប់ការបង្កើតនិងដំណើរការក្រុមហ៊ុនពាណិជ្ជកម្ម
- ដំណើរការចុះបញ្ជីនិងទទួលការអនុញ្ញាតមានភាពងាយស្រួល , ឆាប់រហ័ស និងទាន់ពេលវេលា
- ធ្វើឱ្យការអនុវត្តច្បាប់មានភាពជាក់លាក់ និងទទួលបានការគោរពពីអ្នកពាក់ព័ន្ធ
- ច្បាប់និងបទបញ្ញាទាំងនេះត្រូវតែច្បាស់លាស់, ស្របតាមស្ថានភាពជាក់ស្តែង និងមានភាពរឹងមាំ
- អាជ្ញាធរត្រូវធ្វើការកាត់បន្ថយនីតិវិធី និងលំនឹងនៃដំណើរការចុះបញ្ជី
- ការធ្វើឱ្យប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុមានភាពងាយស្រួលនិងមានប្រសិទ្ធភាពក៏អាចជួយដល់ក្រុមហ៊ុនពាណិជ្ជកម្មផងដែរ
- ការធ្វើឱ្យប្រព័ន្ធពន្ធមានភាពងាយស្រួល និងមានភាពច្បាស់លាស់
- ការផ្តល់ការណែនាំ និងជំនួយសម្រាប់ក្រុមហ៊ុនក្នុងការបង់ពន្ធ
- រដ្ឋាភិបាលត្រូវផ្តល់កម្មវិធីបណ្តុះបណ្តាលនិងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកក្នុងវិស័យពាណិជ្ជកម្ម
- ការបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញដើម្បីបំពេញតម្រូវការបុគ្គលិក
- ការសហការជាមួយវិទ្យាស្ថានអប់រំនិងសាកលវិទ្យាល័យដើម្បីបង្កើតកម្មវិធីសិក្សាផ្នែកពាណិជ្ជកម្ម
- ការបណ្តុះបណ្តាលនេះអាចជួយបង្កើនសមត្ថភាពរបស់បុគ្គលិកក្នុងការគ្រប់គ្រងក្រុមហ៊ុនពាណិជ្ជកម្ម

## ២.ធនធានមនុស្ស និងថវិកា

ធនធានមនុស្ស ជាធនធានដែលសំខាន់ និងពិបាកបណ្តុះបណ្តាលបំផុតនៅលើគ្រប់វិស័យ ហេតុនេះនៅក្នុងវិស័យពាណិជ្ជកម្ម ធនធានមនុស្សនេះ គឺជាបញ្ហាសំខាន់ដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាព និងភាពរឹងមាំរបស់ក្រុមហ៊ុន ហេតុនេះត្រូវមានផែនការនៅក្នុងការរៀបចំធនធានមនុស្សនេះ ដោយបានល្អដោយផ្តោតលើការរៀបចំធនធានមនុស្ស គឺពិតជាត្រូវការការរៀបចំដូចខាងក្រោម៖

១. ការគ្រប់គ្រងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព៖ នៅក្នុងនោះត្រូវការរៀបចំរចនាសម្ព័ន្ធសមស្របសម្រាប់ធុរកិច្ច ការកំណត់តួនាទីនិងការទទួលខុសត្រូវឱ្យច្បាស់លាស់ ការអភិវឌ្ឍន៍និងការរក្សាទុកបុគ្គលិកដែលមានសមត្ថភាព

២. ការអនុវត្តការគ្រប់គ្រងសមត្ថភាពបុគ្គលិក៖ ការអនុវត្តការគ្រប់គ្រងសមត្ថភាពបុគ្គលិក គឺក្នុងគោលបំណងទទួលបាន ការប្រឹក្សាយោបល់និងការអភិវឌ្ឍន៍បុគ្គលិក ការបណ្តុះបណ្តាលនិងការអប់រំបន្ត ការផ្តល់ឱកាសនិងការទទួលស្គាល់ការបំពេញការងារល្អ

៣. ការគ្រប់គ្រងទំនាក់ទំនង និងការទទួលខុសត្រូវ៖ នៅក្នុងការងារគ្រប់គ្រង និងការទទួលខុសត្រូវ គឺជារឿងពិបាកបំផុតនៅក្នុងការធ្វើវា ប៉ុន្តែត្រូវធ្វើឲ្យបានដើម្បីទទួលបាននូវ ការប្រសិទ្ធភាពនៃការទំនាក់ទំនងរវាងគ្រប់ជាន់ថ្នាក់ ការកំណត់និងការអនុវត្តនូវនីតិវិធីនិងគោលនយោបាយ ការធានាឱ្យមានការទទួលខុសត្រូវនិងគណនេយ្យភាព ។

៤. ការអនុវត្តការគ្រប់គ្រងផលិតភាព និងការកំណត់ឱ្យមានការរីកចម្រើន៖ គឺមានគោលបំណងដើម្បីទទួលបានការកំណត់និងការវាស់វែង ផលិតភាពនិងលទ្ធផល ការកំណត់គោលដៅនិងការកំណត់ឱ្យមានការវិវត្តន៍ ការធានាឱ្យមានកិច្ចសហការនិងការទទួលខុសត្រូវ ។

ការអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវការគ្រប់គ្រងធនធានមនុស្សទាំងនេះ អាចជួយឲ្យផ្នែកពាណិជ្ជកម្មទទួលបានធនធានមនុស្ស ដែលមានភាពរឹងមាំ និងសមត្ថភាពប្រកួតប្រជែងខ្ពស់ ។

## ៣. សេដ្ឋកិច្ច

នៅក្នុងដំណោះស្រាយនៃបញ្ហាសេដ្ឋកិច្ច គឺពិតជាពិបាក ក៏ប៉ុន្តែការធានាបាននូវហានិភ័យនានាដែលកើតមាននៅក្នុងបញ្ហាសេដ្ឋកិច្ចនៅក្នុងក្រុមហ៊ុនមួយ បានរួមចំណែកធ្វើឲ្យក្រុមហ៊ុននោះមានការរីកចម្រើន និងជៀសផុតពីការបិទដំណើរការ ឬក្ស័យធនជាដើម ។ បញ្ហានេះ គឺត្រូវឲ្យមានការរៀបចំដូចខាងក្រោម៖

១. ការគ្រប់គ្រងសាច់ប្រាក់ និងការគ្រប់គ្រងដើមទុន គឺត្រូវធ្វើការគ្រប់គ្រងសាច់ប្រាក់ដ៏មានប្រសិទ្ធភាព ដើម្បីធានាថាក្រុមហ៊ុនមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ប្រតិបត្តិការ និងការវិនិយោគ និងត្រូវប្រើប្រាស់ប្រភពដើមទុន ដូចជាការផ្តល់ឥណទានធនាគារ ឬការលក់ភាគហ៊ុន ដើម្បីទទួលបានធនធានថវិកាបន្ថែម ។

២.ការគ្រប់គ្រងចំណាយ និងការកាត់បន្ថយចំណាយ គឺត្រូវធ្វើការវិភាគចំណាយ និងកំណត់ចំណាយដែលអាចកាត់បន្ថយបាន ដើម្បីធ្វើឱ្យប្រតិបត្តិការក្រុមហ៊ុនមានប្រសិទ្ធភាព និងពិចារណាលើជម្រើសផ្សេងៗ ដូចជាការធ្វើកិច្ចសន្យាប្រតិបត្តិការ ការធ្វើឱ្យប្រសិទ្ធភាពកម្លាំងពលកម្ម ឬការផ្លាស់ប្តូរទីតាំងក្រុមហ៊ុន ដើម្បីកាត់បន្ថយចំណាយ ។

៣.ការផ្តល់ឥណទាន និងការកសាងទំនុកចិត្តពីអ្នកវិនិយោគ គឺត្រូវធ្វើការស្វែងរកប្រភពឥណទានថ្មីៗ ដូចជាឥណទានធនាគារ ឬការវិនិយោគពីវិនិយោគិន ដើម្បីទទួលបានធនធានថវិកា និងធ្វើឱ្យមានទំនុកចិត្តពីអ្នកវិនិយោគ ដោយបង្ហាញពីសមិទ្ធផលប្រតិបត្តិការ និងទិដ្ឋភាពវិជ្ជមានរបស់ក្រុមហ៊ុន ។

៤.ការជំរុញការលក់ និងការបង្កើនចំណូល គឺត្រូវធ្វើការវិភាគទីផ្សារ និងកំណត់យុទ្ធសាស្ត្រលក់ដែលមានប្រសិទ្ធភាព និងពង្រឹងផលិតផល និងសេវាកម្មដើម្បីបង្កើនចំណូល និងកម្រិតប្រាក់ចំណេញ ។

៥.ការរៀបចំផែនការវិនិយោគ និងការគ្រប់គ្រងហានិភ័យ គឺត្រូវធ្វើផែនការវិនិយោគយ៉ាងប្រុងប្រយ័ត្ន ដើម្បីធានាថាវិនិយោគនឹងផ្តល់ផលតបប្រាក់ចំណេញ និងកំណត់និងគ្រប់គ្រងហានិភ័យដែលអាចប៉ះពាល់ដល់

ប្រតិបត្តិការ និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

៦.ការបង្កើតកម្មវិធី និងសេវាកម្មហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនថ្មីនិងក្រុមហ៊ុនតូចៗ ការផ្តល់ឥណទាន ដោយមានការធានាពីរដ្ឋាភិបាលដើម្បីជួយក្រុមហ៊ុនទទួលបានមូលនិធិ ការបង្កើតកម្មវិធីបណ្តុះបណ្តាល និងផ្តល់ការណែនាំអំពីការគ្រប់គ្រងហិរញ្ញវត្ថុ ។

ជាមួយនឹងយុទ្ធសាស្ត្រទាំងនេះ ក្រុមហ៊ុនអាចទទួលបានធនធានថវិកាដែលចាំបាច់ និងគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការ និងការវិនិយោគ ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី " **នីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា** " រួចរាល់មក បានសង្កេតឃើញថា ការសិក្សាស្រាវជ្រាវនេះបានបកស្រាយជារួមពីទិដ្ឋភាពទូទៅនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា ដែលបានរំលេចចេញចាប់ពីការកកើតនៃក្រុមហ៊ុន លក្ខន្តិកៈ ដំណើរការ ឬការប្រព្រឹត្តទៅនៃក្រុមហ៊ុន ក៏ដូចជាការបញ្ចប់ ឬការរំលាយរបស់ក្រុមហ៊ុនជាដើម ។ លើសពីនេះទៅទៀត ការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើនីតិវិធីនៃការបង្កើតក្រុមហ៊ុន ក៏ពិតមែន ក៏ប៉ុន្តែក៏បានស្រាវជ្រាវពីសញ្ញាណទូទៅនៃក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា ដែលមាននៅក្នុងជំពូកទី១ ទម្រង់នៃក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា នៅក្នុងជំពូកទី២ និងគុណសម្បត្តិ គុណវិបត្តិ ដំណោះស្រាយ និងបញ្ហាប្រឈម នៅក្នុងជំពូកទី៣ ។

នៅក្នុងជំពូកនីមួយៗ បានធ្វើការសិក្សាស្រាវជ្រាវការ ក៏ដូចជាបកស្រាយមានភាពស៊ីចង្វាក់ និងប្រទាក់ក្រឡាគ្នាពីមួយចំណុច ទៅមួយចំណុច ដែលបានបកស្រាយបង្ហាញពីលក្ខណៈរបស់ក្រុមហ៊ុនទាំងអស់ដែលមាននៅកម្ពុជា ស្របតាមបញ្ញត្តិច្បាប់ ដែលពិសេសបានស្រាវជ្រាវ និងដកស្រង់ពីបញ្ញត្តិច្បាប់ដែលមាន និងបានផ្តោតសំខាន់លើច្បាប់សហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងឯកសារគតិយុត្តិពាក់ព័ន្ធសំខាន់ៗផ្សេងទៀតដែលជាឯកសារជំនួស នៅក្នុងការសិក្សាស្រាវនេះ ។

យើងបានដឹងរួចមកហើយថា ក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា មានច្រើនទម្រង់ និងលក្ខខណ្ឌនៃការបង្កើតមានភាពខុសគ្នា តាមទម្រង់នៃនីមួយៗនៃក្រុមហ៊ុន ហេតុនេះហើយ ការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជាទោះបីស្ថិតក្នុងទម្រង់ណាមួយក៏ដោយក៏ត្រូវបានទាមទារឲ្យបំពេញលក្ខខណ្ឌតាមការកំណត់របស់ច្បាប់កម្ពុជា ។ ដូច្នោះហើយនៅមុនពេលចាប់ផ្តើមនៅក្នុងការបង្កើតក្រុមហ៊ុន ទៅតាមទម្រង់ណាមួយដែលជាតម្រូវការចាំបាច់នៅក្នុងការធ្វើអាជីវកម្ម គឺប្រាកដណាស់ទាមទារឲ្យមានការព្រមព្រៀង ឬការជជែកគ្នារវាងសមាជិកភាគហ៊ុនទាំងអស់ ឬការប្រមូលដើមទុនក្នុងការបង្កើតអាជីវកម្ម ប្រសិនបើសម្រេចចិត្តថាមិនចូលរួមដើមទុនជាមួយនរណា ។ ការបកស្រាយបែបនេះ មកពីមូលហេតុថាទម្រង់នៃក្រុមហ៊ុននៅកម្ពុជាគឺមានទម្រង់ក្រុមហ៊ុនខ្លះគឺអាចបើអាជីវកម្មតែម្នាក់ឯង និងមានទម្រង់ក្រុមហ៊ុនខ្លះតម្រូវឲ្យមានគ្នាចាប់ពី០២នាក់ឡើយទៅដែលជាហេតុនាំឲ្យការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនីមួយៗ តម្រូវឲ្យមានការគិតគូរឲ្យបានល្អិតល្អន់ និងសមស្របតាមបញ្ញត្តិច្បាប់ជាធរមាន មុនពេលសម្រេចចិត្តថាបង្កើតក្រុមហ៊ុនអាជីវកម្ម ក្នុងទម្រង់ណាមួយដែលជាតម្រូវការរបស់ខ្លួនក្នុងការធ្វើអាជីវកម្មនៅកម្ពុជា ។

ជាការពិតណាស់នៅក្នុងការស្រាវជ្រាវនេះ បានបង្ហាញពីការបង្កើតក្រុមហ៊ុនទាំងអស់នៅកម្ពុជា ដែលជាភាពងាយស្រួលបន្ថែមទៀតនៅក្នុងការសម្រេចចិត្តបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា ក៏ដូចជាអាចជ្រើសរើសក្នុងការបង្កើតក្រុមហ៊ុនដែលមានភាពសមស្របជាមួយដើមទុនរបស់ខ្លួន ដែលជាកកត្តាសំខាន់មិនអាចខ្វះបាន

នៅក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម ។ លើសពីនេះទៀត ប្រសិនបើមានដើមទុនរួចរាល់ហើយ ទើបអាចធ្វើការសម្រេចចិត្តនៅក្នុងការជ្រើសរើសទម្រង់នៃអាជីវកម្មរបស់ខ្លួន ដើម្បីឲ្យការបង្កើតមានភាពសមស្រប និងទទួលបានជោគជ័យ ហេតុនេះនៅក្នុងជំពូកទី២ នៃការស្រាវជ្រាវលើប្រធានបទ “ **នីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា** ” នេះបានធ្វើការបកស្រាយបង្ហាញពីសហគ្រាស ឬក្រុមហ៊ុនពាណិជ្ជកម្មដែលមានទម្រង់ជា សហគ្រាសឯកបុគ្គល សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន ជាដើម ។

ហេតុនេះ នៅក្នុងការសិក្សាស្រាវជ្រាវ និងបកស្រាយនៅក្នុងជំពូកទី២ ទម្រង់នៃក្រុមហ៊ុនពាណិជ្ជកម្មគឺពិតជាសំខាន់ និងបានសិក្សាស្រាវជ្រាវយ៉ាងល្អិតពីការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនីមួយៗ តាមការកំណត់នៃច្បាប់ជាធរមានរបស់កម្ពុជា ដែលនៅក្នុងនោះ លក្ខន្តិកៈរបស់ក្រុមហ៊ុនពាណិជ្ជកម្មទាំងអស់ គឺជាចំណុចស្នូល និងជាចំណុចដែលសំខាន់ដែលម្ចាស់អាជីវកម្ម ឬសមាជិកភាគហ៊ុនទាំងអស់ ចាំបាច់គិតពិតចារណាឲ្យបានល្អិតល្អន់ មុនគេបង្កស់ ។ មិនត្រឹមតែប៉ុណ្ណោះ នៅពេលបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម រួចហើយក៏តម្រូវឲ្យមានការចុះបញ្ជីស្របតាមបញ្ញត្តិរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីក្រុមហ៊ុនទាំងអស់នោះអាចដំណើរការអាជីវកម្មសមស្របតាមច្បាប់របស់កម្ពុជា ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទ “ **នីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា** ” ដែលជាស្នាដៃស្រាវជ្រាវរបស់យើងខ្ញុំ នៅក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះមក បានឲ្យឃើញថាបន្ទាប់ពីបានស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ ក្នុងការប្រមូល និងចងក្រង ព្រមទាំងឯកសារគតិយុត្តិសំខាន់ផ្សេងៗ នៅលើប្រធានបទនេះរួចមកយើងខ្ញុំពិតជាទទួលបានចំណេះដឹងថ្មីបន្ថែម បទពិសោធថ្មី នៅក្នុងការស្រាវជ្រាវនេះ និងជាពិសេសបានចងក្រងស្នាដៃនេះទុកជាឯកសារសម្រាប់អ្នកសិក្សាស្រាវជ្រាវដូចគ្នា ។ លើសពីនេះទៀតនៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះយើងខ្ញុំបានសង្កេតឃើញថាមានចំណុចល្អជាច្រើននៅក្នុងនីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា ប៉ុន្តែយ៉ាងណាក៏នៅតែមានចំណុចខ្វះខាត និងខ្វះចន្លោះផងដែរ ។

ខាងក្រោមនេះជាមតិយោបល់បន្ថែម នៅក្នុងការកែសម្រួលនៅក្នុងនីតិវិធិនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា ដើម្បីឲ្យនីតិវិធីនៃការបង្កើតនេះដំណើរការបានរលូន និងជាភាពទាក់ទាញបន្ថែមទៀតត្រូវធ្វើការកែប្រែ និងបំពេញបន្ថែមនូវចំណុចដូចខាងក្រោម៖

**ចំណុចទី១៖** កែប្រែនីតិវិធីនៃការបង្កើតឲ្យមានភាពងាយស្រួល នៅក្នុងនីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា ហាក់ដូចជាមានការលក្ខខណ្ឌស្មុគស្មាញ និងតម្រូវឲ្យម្ចាស់សហគ្រាសបំពេញបែបបទច្រើន ដែលជាមូលហេតុរាំងស្ទះដល់ការសម្រេចចិត្តនៅក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា ។ ការកែប្រែនេះ គឺមិនផ្តោតសំខាន់លើការកែប្រែទាំងស្រុងនោះទេ គឺគ្រាន់តែកែសម្រួលនៅចំណុចដែលមានភាពមិនច្បាស់លាស់ ដែលនាំឲ្យម្ចាស់អាជីវកម្មពិបាកក្នុងការសម្រេចចិត្ត ព្រោះគ្រាន់តែចាប់ផ្តើមភ្លាមគឺមានរឿងស្មុគស្មាញច្រើនទៅហើយនៅក្នុងនីតិវិធីនៃការបង្កើតនេះ ហេតុនេះការកែប្របែបបទនៃការបង្កើតឲ្យមានភាពងាយស្រួល គឺជាការល្អបំផុតដើម្បីឲ្យនីតិវិធីនៃបង្កើតនេះជាចំណុចចាប់អារម្មណ៍ដល់ម្ចាស់អាជីវកម្ម និងវិនិយោគទុន ។

**ចំណុចទី២៖** លិខិតបទដ្ឋានគតិយុត្តិ គឺជាឯកសារដែលមានសារៈសំខាន់បំផុតនៅគ្រប់ផ្នែកទាំងអស់នៅក្នុងនីតិវិធីនៃការបង្កើតក្រុមហ៊ុននៅកម្ពុជា គឺពិតជាចាំបាច់ណាស់ក្នុងការចង្អុលបង្ហាញពីការបង្កើតក្រុមហ៊ុននានានៅកម្ពុជា ហេតុនេះហើយលិខិតបទដ្ឋានគតិយុត្តិកាន់តែច្រើន គឺកាន់តែមានប្រយោជន៍ដ៏ការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម ដោយមូលហេតុថា លិខិតបទដ្ឋានគតិយុត្តិ គឺជាឯកសារដែលត្រូវបានកំណត់ដោយច្បាប់ និងបទបញ្ញាផ្សេងៗ ដែលបានណែនាំដល់ការបង្កើតក្រុមហ៊ុន។ ប៉ុន្តែនៅក្នុងការស្រាវជ្រាវសារណារបស់យើងខ្ញុំនេះគឺបានសង្កេតឃើញពីបញ្ហាកង្វះខាតលិខិតបទដ្ឋានគិតយុត្តិ ដែលធ្វើឲ្យប៉ះពាល់ដល់ការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា ហេតុនេះយើងខ្ញុំក៏មានជាគំនិតយោបល់នៅក្នុងការចូលរួមដល់ការខ្វះខាតលិខិតបទដ្ឋានគតិយុត្តនេះដូចជាការបង្កើតនៅលិខិតបទដ្ឋានគតិយុត្តបន្ថែម វិសោធនកម្មមាត្រាឬផ្នែក ដើម្បីឲ្យទាន់បែបបទនៃពាណិជ្ជកម្មក្នុងពេលបច្ចុប្បន្ន នឹងអនាគត ឬពន្លឿនដល់លិខិតបទដ្ឋានគតិយុត្តដែលកំពុងនឹងព្រៀងឲ្យចូលជាស្ថាពរ ។

**ចំណុចទី៣៖** ធនធានមនុស្ស ការសង្កេតឃើញពីកង្វះធនធានមនុស្សនៅក្នុងផ្នែកពាណិជ្ជកម្មនេះបាន នឹងកំពុងជាបញ្ហាចោទនៅក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា ដោយមូលហេតុថាធនធានមនុស្ស គឺពិត ជាសំខាន់នៅក្នុងការអភិវឌ្ឍន៍ និងកសាងនៅគ្រប់ផ្នែកទាំងអស់ ព្រមទាំងផ្នែកពាណិជ្ជកម្មផងដែរ ។ ការបង្កើត ធនធានមនុស្សនៅក្នុងផ្នែកពាណិជ្ជកម្ម គឺជារឿងសំខាន់ដែលត្រូវធ្វើ និងចាំបាច់ជាទីបំផុត ពីព្រោះធនធានមនុស្ស ជាកាតាលីករជំរុញផ្នែកពាណិជ្ជកម្មនេះឲ្យកាន់តែរីកចម្រើន ហេតុនេះការបណ្តុះធនធានមនុស្សលើផ្នែកពាណិជ្ជកម្ម គឺជារឿងដែលត្រូវយកចិត្តទុកដាក់ និងត្រូវតាមដានជាប់ជាប្រចាំ ។

**ចំណុចទី៤៖** ពន្លឿនបែបបទនៃការចុះបញ្ជី គឺមិនមែនធ្វើឲ្យបែបបទនៃការចុះបញ្ជីត្រូវបានរំលង ឬមិនបាន បំពេញគ្រប់ដំណាក់កាលនោះទេ ក៏ប៉ុន្តែការពន្លឿនបែបបទនៃការចុះបញ្ជីរបស់ក្រុមហ៊ុននេះ ជាការដែលត្រូវយក ចិត្តទុកដាក់បំផុត ។ នៅកម្ពុជាកំណើតនៃការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មមានច្រើន ហេតុនេះហើយប្រសិនបើផ្នែក នៃការចុះបញ្ជីក្រុមហ៊ុន មានភាពយឺតយ៉ាវ និងមិនឆាប់រហ័សទៀតនេះ គឺជះឥទ្ធិពលមិនល្អដល់ផ្នែកពាណិជ្ជកម្ម នេះ ជាពិសេសនៅត្រង់ការយឺតយ៉ាវនៃបែបបទនៃការចុះបញ្ជីនេះតែម្តង ហេតុនេះការសម្រួលដល់ការចុះបញ្ជី គឺជា ការជម្រុញដល់ការបង្កើតបន្ថែមនៅក្រុមហ៊ុនពាណិជ្ជកម្មនៅកម្ពុជា ។

សរុបជារួមមកអនុសាសន៍ដែលយើងខ្ញុំបានរៀបរាប់ខាងលើ គ្រាន់តែជាទស្សនៈ និងការមើលឃើញរបស់ យើងខ្ញុំផ្ទាល់ដោយផ្អែកលើការសិក្សា ស្រាវជ្រាវលើប្រធានបទនេះកន្លងមក ។ អនុសាសន៍ខាងលើនេះគ្រាន់តែជា ការណែនាំ និងផ្តល់ជាមតិយោបល់បន្ថែម ដើម្បីធ្វើឲ្យវិស័យនេះកាន់តែមានភាពរីកច្រើន និងបន្ថែមភាពងាយស្រួល ដល់មិត្តអ្នកអានដែលបានបំណងចង់ក្លាយជាម្ចាស់អាជីវកម្មផ្ទាល់ខ្លួននៅពេលអនាគត ។

# ឯកសារយោង

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្ត

១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

២.ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

៣.ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

៤.ច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៩

៥.សារាចរណ៍ណែនាំស្តីពីការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៩៧

៦.សេចក្តីជូនដំណឹងលេខ០០៦ សជណ ពដ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៧ ស្តីពីបញ្ញត្តិសំខាន់ៗនៃច្បាប់សារពើពន្ធឆ្នាំ១៩៩៧

## សៀវភៅ និងអត្ថបទ

១.សៀវភៅនីតិក្រុមហ៊ុន រៀបរៀងដោយលោកមេធាវី កង់ ស៊ីផាន់ណារ៉ា

២.នីតិសហគ្រាសពាណិជ្ជកម្ម រៀបរៀងដោយសាស្ត្រាចារ្យ ខាត់ ធី

៣.នីតិក្រុមហ៊ុន រៀបរៀងដោយលោកមេធាវី អ៊ុំ ប៉ូលី

៤.សៀវភៅច្បាប់ក្រុមហ៊ុន របស់លោក កុយ នាម

## គេហទំព័រ

១.https://www.sacombank.com.kh/about-us/sacombank-cambodia-certificate-of-incorporation/ ចូលមើលថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៤

២.https://www.sacombank.com.kh/about-us/sacombank-cambodia-certificate-of-incorporation/ ចូលមើលថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤

៣.https://khuon-tour.com/kt/Les_statuts_societe_khuontour/Statuts.pdf ចូលមើលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤

៤.https://www.facebook.com/100064142851284/posts/137223340988896/ ចូលមើលថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ លក្ខន្តិកៈក្រុមហ៊ុន

ឧបសម្ព័ន្ធទី២៖ គម្រូនៃការចុះបញ្ជីក្រុមហ៊ុន

ឧបសម្ព័ន្ធទី៣៖ វិញ្ញាបនបត្រក្រុមហ៊ុន

# ឧបសម្ព័ន្ធទី១
# លក្ខន្តិកៈក្រុមហ៊ុន

# លក្ខន្តិកៈក្រុមហ៊ុន

# ARTICLES OF INCORPORATION

.............................................. ឯ.ក

.............................................. ., LTD.

**សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត**

SINGLE MEMBER PRIVATE LIMITED COMPANY

**ដើមទុន ៖ ៨០.០០០.០០០ រៀល**

(=20,000USD; អត្រា 4,000 រៀល/$)

# លក្ខន្តិកៈក្រុមហ៊ុន

## ........................................ ឯ.ក

## ........................................., LTD.

### សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

### ដើមទុន ៖ ៨០.០០០.០០០ រៀល

SINGLE MEMBER PRIVATE LIMITED COMPANY

CAPITAL : 80,000,000 Riels

## ជំពូក ១

### ទ្រព្យសម្បត្តិ-កម្មវត្ថុ-នាមករណ៍-ទីស្នាក់ការ-ថិរវេលា

### ប្រការ ១ ៖ ទ្រព្យសម្បត្តិ

ក្រុមហ៊ុនពាណិជ្ជកម្មមួយបានបង្កើតដោយ៖

- លោក ........................ ពាណិជ្ជករ សញ្ជាតិ ខ្មែរ
  ទីលំនៅ៖ ..........................................................

  អត្តសញ្ញាណប័ណ្ណលេខ៖..............ចុះថ្ងៃទី..................

ម្ចាស់ឯងជាម្ចាស់ ដែលមានទ្រព្យសម្បត្តិជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ដូចមានដើមទុន និងភាគហ៊ុនខាងក្រោម ។

ចាប់ពីថ្ងៃបានចុះក្នុងបញ្ជីពាណិជ្ជកម្មក សហគ្រាសនេះមាននីតិបុគ្គលិកលក្ខណៈ និងជា នីតិបុគ្គលមានសិទ្ធិ មានឈ្មោះ មានអាសយដ្ឋាន មានទ្រព្យសម្បត្តិផ្ទាល់របស់សហគ្រាស និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និង ក្រោមការ កំណត់នៃប្រការទាំងឡាយ ដែលមានចែងក្នុងលក្ខន្តិកៈរបស់សហគ្រាស ។

### ប្រការ ២ ៖ កម្មវត្ថុអាជីវកម្ម

សហគ្រាសមានសកម្មភាពដូចតទៅ៖

491 ការដឹកជញ្ជូនតាមផ្លូវដែក

49120 ការដឹកជញ្ជូនទំនិញតាមផ្លូវដែករវាងទីប្រជុំជន តំបន់ជាយក្រុង រវាងទីប្រជុំជន

49229 ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវគោកផ្សេងទៀត(៤)

49230 ការដឹកជញ្ជូនទំនិញតាមផ្លូវគោក

501 ការដឹកជញ្ជូននៅទឹកសមុទ្រជ្រៅ និងក្បែរតំបន់ឆ្នេរ

50110 ការដឹកជញ្ជូនអ្នកដំណើរតាមទឹកសមុទ្រជ្រៅ និងក្បែរតំបន់ឆ្នេរ

50120 ការដឹកជញ្ជូនតំបន់តាមទឹកសមុទ្រជ្រៅ និងក្បែរតំបន់ឆ្នេរ

502 ការដឹកជញ្ជូនតាមផ្លូវទឹកសាប

50212 ការដឹកជញ្ជូនអ្នកដំណើរតាមទន្លេ ព្រែក បឹង និងផ្លូវទឹកសាបដទៃទៀត រួមមានទាំងនៅក្នុងកំពង់ផែ

512 ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស

  51200 ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស

521 ការស្តុកទំនិញក្នុងឃ្លាំង និងការស្តុកទុក

  52100 សេវាកម្មស្តុកទំនិញក្នុងឃ្លាំង និងការស្តុកទុក

522 សកម្មភាពគាំទ្រការដឹកជញ្ជូន

  52219 សកម្មភាពសេវាកម្មអមផ្សេងៗទៀតសម្រាប់ការដឹកជញ្ជូនផ្លូវគោកដែលមិនបានរាប់បញ្ចូល(៥)

  52240 ការទុកដាក់ទំនិញ

  52291 ការបញ្ជូនទំនិញ

  52292 ការចេញ និងផ្គត់ផ្គង់ឯកសារដឹកជញ្ជូន

  52293 សកម្មភាពភ្នាក់ងាររៀបចំឯកសារគយ

410 ការសាងសង់អាគារ

  41001 អាគារលំនៅដ្ឋាន(២)

  41002 អាគារមិនមែនលំនៅដ្ឋាន(៣)

741 សកម្មភាពរចនាឯកទេស

  74100 សកម្មភាពរចនាឯកទេស

432 សកម្មភាពដំឡើងប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក និងសកម្មភាពដំឡើង ផ្សេងៗទៀត

  43290 ការដំឡើងសំណង់ដទៃទៀត

551 សកម្មភាពសេវាកម្មស្នាក់នៅ

  55101 សណ្ឋាគារនិងសណ្ឋាគាររីសត

  55109 សកម្មភាពសេវាកម្មស្នាក់នៅ ដទៃទៀតដែលពុំបានរាប់បញ្ចូល

561 សកម្មភាពសេវាកម្មភោជនីដ្ឋាន និងសេវាកម្មផ្គត់ផ្គង់អាហារចល័ត

  56101 ភោជនីដ្ឋាន និងកន្លែងស៊ីផឹករង្គសាល

  56102 កន្លែងលក់អាហាររហ័ស(២)

791 សកម្មភាពទីភ្នាក់ងារទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍

  79110 សកម្មភាពទីភ្នាក់ងារទេសចរណ៍(១)

  79120 សកម្មភាពប្រតិបត្តិករទេសចរណ៍(២)

332 ការដំឡើងផ្ដុំជាម៉ាស៊ីននិងគ្រឿងបរិក្ខារម៉ាស៊ីន

  33200 ការដំឡើងគ្រឿងម៉ាស៊ីននិងគ្រឿងបរិក្ខារម៉ាស៊ីន

731 ការផ្សាយពាណិជ្ជកម្ម

  73100 ការផ្សាយពាណិជ្ជកម្ម(១)

ការចូលរួមតាមគ្រប់មធ្យោបាយរបស់សហគ្រាសជាមួយរាល់សហគ្រាស ឬ ក្រុមហ៊ុនដទៃ ដែលមាន ឬដែលនឹងបង្កើត និងដែលមានជាប់ទាក់ទងដោយចំពោះ ឬមិនចំពោះដល់ កម្មវត្ថុអាជីវកម្ម ពិសេសតាមវិធី ក្រុមហ៊ុនថ្មី ភាគទុន ការចុះឈ្មោះ ឬ ទិញសិទ្ធិសមាជិក ការរំលាយបញ្ចូលគ្នា សម្ពន្ធភាព ឬការចូលរួមសហ ប្រការនានា ។

ជាទូទៅ សហគ្រាសធ្វើរាល់ប្រតិបត្តិការពាណិជ្ជកម្មដែលជាប់ទាក់ទងដោយចំពោះ ឬមិន ចំពោះ ឬប្រហាក់ប្រហែលគ្នា ឬប្រទាក់គ្នា នឹងសកម្មភាពខាងលើ ក្នុងគោលដៅធ្វើឱ្យសហគ្រាស មានការរីកចម្រើន ។

**ប្រការ ៣ ៖ នាមករណ៍**

សហគ្រាសធ្វើសកម្មភាពក្រោមនាមថា៖

**........................................ ឯ.ក**

**........................................ ., LTD.**

**សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត**

SINGLE MEMBER PRIVATE LIMITED COMPANY

សហគ្រាសមានត្រាសម្គាល់សម្រាប់សហគ្រាសប្រើប្រាស់ ដែលមាននាមករណ៍របស់ សហគ្រាសនៅក្នុងផ្ទៃត្រា ។ នៅក្នុងរាល់លិខិតស្នាម វិក្កយបត្រ ឯកសារផ្សព្វផ្សាយ និងឯកសារ ផ្សេងៗទៀតគ្រប់ប្រភេទ ដែលផ្សាយចេញពីសហគ្រាស ត្រូវតែមានថែងពីក្រោយ ឬ ពីក្រោម នាមករណ៍នូវពាក្យថា ៖ "សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត (SINGLE MEMBER PRIVATE LIMITED COMPANY)" ។

**ប្រការ ៤ ៖ ទីស្នាក់ការ**

ទីស្នាក់ការក្រុមហ៊ុនតាំងនៅ៖ ..............................................................

ទីស្នាកការនេះ អាចផ្ទេរទៅទីកន្លែងផ្សេងទៀតបានតាមសេចក្តីសម្រេចរបស់ម្ចាស់សហគ្រាស ។

**ប្រការ ៥ ៖ ចិររយាល**

ចិររយាលរបស់សហគ្រាសត្រូវបានកំណត់ចំនួន ៩៩ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទ ដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្ម។

## ជំពូក ២

## ដើមទុន-ការផ្ទេរភាគហ៊ុន-ការដឹកនាំសហគ្រាស

**ប្រការ ៦ ៖ ដើមទុន**

សមាជិកមានតែម្នាក់ដែលចូលហ៊ុនជាសាច់ប្រាក់សុទ្ធ ៨០.០០០.០០០ រៀល (ប៉ែតសិបលានរៀល) បែងចែកជា ១.០០០ ភាគហ៊ុន (មួយពាន់ភាគហ៊ុន) ក្នុងមួយភាគហ៊ុនមានតម្លៃ ៨០.០០០ រៀល ។

លោក ..................... ម្ចាស់ភាគហ៊ុនទាំងអស់ ដែលមានចំនួន ១.០០០ ភាគហ៊ុន ស្មើនឹង ដើមទុន ៨០.០០០.០០០ រៀល ។

**ប្រការ ៧ ៖ ការបង្កើនដើមទុន-ការបន្ថយដើមទុន**

**ក-ការបង្កើនដើមទុន**

ដើមទុនសហគ្រាសអាចបានបង្កើនមួយដង ឬច្រើនដងតាមសេចក្តីសម្រេចរបស់ ម្ចាស់សហគ្រាស ។

**ខ-ការបន្ថយដើមទុន**

ដើមទុនអាចបន្ថយបាន កុំឱ្យតែក្រោមកម្រិតដែលច្បាប់បញ្ញត្តិ។

### ប្រការ ៨ ៖ ការផ្ទេរភាគហ៊ុន

កាលណាម្ចាស់សហគ្រាសទទួលមរណភាព ភាគហ៊ុននៃសហគ្រាសនេះត្រូវបានទៅដល់សហព័ទ្ធនៅរស់ និងអ្នកទទួលមរតក ដែលមានសិទ្ធិបន្តសកម្មភាពសហគ្រាសបន្តទៅទៀត។ បើមិន ដូច្នោះទេសហព័ទ្ធអាចរំលាយសហគ្រាសនេះ ។ នៅក្នុងករណីនេះ ក្រោយពីបានទូទាត់កាត់សងដល់តតិយជនដែលជាម្ចាស់បំណុលរបស់សហគ្រាសហើយ ភាគហ៊ុនត្រូវបានចែកចាយទៅដល់សហព័ទ្ធនិងអ្នកទទួលមរតកតាមបំណងរបស់ម្ចាស់សហគ្រាស។

### ប្រការ ៩ ៖ ការដឹកនាំសហគ្រាស

សហគ្រាសត្រូវដឹកនាំគ្រប់គ្រងដោយម្ចាស់សហគ្រាស ឬ ដោយនាយកដែលមិនមែនជាម្ចាស់សហគ្រាស។ នៅក្នុងពេលដែលសហគ្រាសនេះដឹកនាំដោយនាយកដែលមិនមែនជាម្ចាស់សហគ្រាស នាយកនេះទទួលប្រាក់ខែ ឬប្រាក់រង្វាន់តាមការសម្រេចនិងព្រមព្រៀងគ្នារវាងម្ចាស់សហគ្រាស និងនាយករូបនេះ ។

សហគ្រាសដឹកនាំដោយ លោក .................. ម្ចាស់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត។

## ជំពូក ៣

## សេចក្តីសម្រេចរបស់សហគ្រាស-គណនីចរន្ត

### ប្រការ ១០ ៖ សេចក្តីសម្រេចរបស់សហគ្រាស

សេចក្តីសម្រេចទាំងអស់ជាអំណាចរបស់ម្ចាស់សហគ្រាស ដែលមានការទទួលខុសត្រូវផ្ទាល់ចំពោះតតិយជន។ ម្ចាស់សហគ្រាសមានអំណាចដកហូតមុខងាររបស់នាយក បើសិនជាមាននាយកជាតតិយជន។

បើប្រសិនការដកហូតមុខងារនេះ សម្រេចដោយគ្មានមូលហេតុត្រឹមត្រូវម្ចាស់សហគ្រាសត្រូវសងជំងឺចិត្តដល់នាយក។ ប៉ុន្តែនាយកនេះមិនអាចអនុញ្ញាតឱ្យចូលកាន់តំណែងដើមវិញបានទេ ។

### ប្រការ ១១ ៖ គណនីចរន្ត

បើសិនជាមានការចាំបាច់ម្ចាស់សហគ្រាសអាចទុកប្រាក់នៅក្នុងគណនីចរន្តរបស់សហគ្រាស។ ការប្រាក់នៅក្នុងគណនីចរន្តនេះ ត្រូវសមស្របទៅតាមការប្រាក់ដែលអនុញ្ញាតតាមច្បាប់ ។ ហាមផ្តាច់មិនឱ្យម្ចាស់សហគ្រាសខ្ចីប្រាក់សហគ្រាសឡើយ ។

## ជំពូក ៤

## ឆ្នាំការិយបរិច្ឆេទ-ប្រាក់ចំណេញឬខាត-ការរំលាយ-ការផ្លាស់ប្តូរទ្រង់ទ្រាយ

### ប្រការ ១២ ៖ ឆ្នាំការិយបរិច្ឆេទ

ឆ្នាំការិយបរិច្ឆេទ ចាប់ផ្តើមពីថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ លើកលែងតែឆ្នាំការិយបរិច្ឆេទដំបូង ដែលត្រូវចាប់ផ្តើមពីថ្ងៃចុះបញ្ជីពាណិជ្ជកម្ម និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំ បង្កើតសហគ្រាស ។

### ប្រការ ១៣ ៖ ការប្រកាសលទ្ធផលនៃសហគ្រាស

រៀងរាល់ឆ្នាំក្រោយការបិទការិយបរិច្ឆេទ សហគ្រាសត្រូវចាត់ចែងធ្វើគណនេយ្យលទ្ធផល និង តារាងតុល្យការ ។ គណនេយ្យលទ្ធផល មានរាប់ចំណូលនិងចំណាយ ហើយបង្ហាញសំណល់ជា ប្រាក់ចំណេញ ឬ ប្រាក់ខាតរបស់សហគ្រាស ។ នៅលើប្រាក់ចំណេញ ត្រូវមានការដកហូត ៥% យ៉ាងតិច ដើម្បីបង្កើតជាមូលនិធិបម្រុង ។

ការដកហូតយកភាគនៃប្រាក់ចំណេញនេះត្រូវបញ្ឈប់ កាលបើមូលនិធិបម្រុងនេះបានគ្រប់ចំនួន១០% នៃដើមទុនរបស់សហគ្រាស ។

## ប្រការ ១៤ ៖ ការខាតលើសពីពាក់កណ្តាលនៃដើមទុនដំបូង

បើសិនជាឯកសារគណនេយ្យ បង្ហាញឱ្យឃើញការខាតរបស់សហគ្រាសរហូតដល់កម្រិត លើសពីពាក់កណ្តាលដើមទុនដំបូង ម្ចាស់សហគ្រាសត្រូវតែរំលាយសហគ្រាសមុនថិរវេលាកំណត់ ។

ការរំលាយនេះត្រូវធ្វើឡើង បើប្រសិនណាស្ថានការណ៍មិនអាចធ្វើឱ្យមានប្រក្រតីភាពឡើងវិញបានទេ ក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីបានពិនិត្យឃើញនូវការខាតនេះ ។

## ប្រការ ១៥ ៖ ការរំលាយ និងជម្រះបញ្ជីសហគ្រាស

កាលណាផុតថិរវេលារបស់សហគ្រាស ឬក្នុងករណីមរណភាព ការបាត់បង់សមត្ថភាព ការសម្រេចរបស់តុលាការលើទុព្វលភាពផ្ទាល់របស់ម្ចាស់សហគ្រាស ឬការខាតបង់ដើមទុនលើសពីពាក់កណ្តាល សហគ្រាសត្រូវធ្វើការជម្រះបញ្ជីនិងរំលាយសហគ្រាស ។ សេចក្តីសម្រេចស្តីពីការរំលាយសហគ្រាស ត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ការរំលាយសហគ្រាស។ សហគ្រាសត្រូវបញ្ឈប់អត្ថិភាពរបស់ខ្លួន ចាប់ពីថ្ងៃដែល មានចុះនៅក្នុងវិញ្ញាបនបត្របញ្ជាក់ការរំលាយសហគ្រាសនេះ។

## ប្រការ ១៦ ៖ ការផ្លាស់ប្តូរទ្រង់ទ្រាយ

សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត អាចផ្លាស់ប្តូរទ្រង់ទ្រាយទៅជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបានកាលបើមានរូបវន្តបុគ្គល ឬ នីតិបុគ្គលមួយ ឬ ច្រើនទទួលការយល់ព្រមពីម្ចាស់សហគ្រាសឱ្យចូលជាសមាជិក ។

## ប្រការ ១៧ ៖ សោហ៊ុយចំណាយ

ចំណាយក្នុងការបង្កើតសហគ្រាសនេះ ត្រូវបញ្ចូលក្នុងបញ្ជីចំណាយរបស់សហគ្រាស ។

ធ្វើជា      ច្បាប់ដើម ថ្ងៃទី      ខែ      ឆ្នាំ ២០២៣

**បានអាន និង យល់ព្រម**

**ទទួលមុខងារជាអភិបាល**

លោក ....................

# លក្ខន្តិកៈក្រុមហ៊ុន

**MEMORANDUM AND ARTICLES OF ASSOCIATION**

.......................................................................................................

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

Private Limited Company

ដើមទុន ៖ ២,០០០,០០០,០០០ រៀល

# លក្ខន្តិកៈ

# ក្រុមហ៊ុន

....................................................................................................

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត - ដើមទុន ៖ ២,០០០,០០០,០០០ រៀល

❋ ❋ ❋

អ្នកដែលមានរាយឈ្មោះដូចខាងក្រោម ៖

១- លោក ................................ ពាណិជ្ជករ សញ្ជាតិ

អាសយដ្ឋានៈ

លិខិតឆ្លងដែនលេខ៖ ចុះថ្ងៃទី

២- កញ្ញា ................................ ពាណិជ្ជករ សញ្ជាតិខ្មែរ

អាសយដ្ឋាន

អត្តសញ្ញាណប័ណ្ណលេខ៖ ចុះថ្ងៃទី

បានរៀបចំលក្ខន្តិកៈនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមួយទៅតាមការព្រមព្រៀងគ្នាដោយស្ម័គ្រចិត្តនិងតាមលក្ខខណ្ឌដូចតទៅ។

ក្រសួងពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
ចុះបញ្ជីលេខ: 00018318
កាលបរិច្ឆេទទទួល: 26-07-2022 ម៉ោង 16"45'
មន្ត្រីទទួលបន្ទុក:

## ប្រការ ១

## នាមករណ៍ - ទ្រនំស្នាយ

**១-១ ៖ នាមករណ៍**

ក្រុមហ៊ុនមាននាមថា ៖

....................................................................................................

ក្រុមហ៊ុនមានត្រាសំគាល់សំរាប់ក្រុមហ៊ុនប្រើប្រាស់ដែលមាននាមករណ៍របស់ក្រុមហ៊ុននៅក្នុងផ្ទៃត្រា។

នៅក្នុងពល់លិខិតស្នាមវិក័យប័ត្រឯកសារផ្សព្វផ្សាយនិងឯកសារផ្សេងៗទៀតគ្រប់ប្រភេទដែលផ្សាយចេញពីក្រុមហ៊ុនត្រូវតែមានចែងពីក្រោយឬពីក្រោមនាមករណ៍នូវអក្សរច្បាស់និងគ្រប់ពាក្យថា ៖"ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតCO., LTD. ព្រមទាំងចែងនូវចំនួនដើមទុនចុះបញ្ជីក្រុមហ៊ុនផង។

**១.២៖ ម្ចាស់ហ៊ុន**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមួយត្រូវបានបង្កើតឡើងដែលក្នុងនោះមានម្ចាស់ហ៊ុនដូចមានចែងនៅប្រការខាងក្រោយនិងអាចមានបន្ថែមម្ចាស់ហ៊ុននៅពេលក្រោយទៀត។

ចាប់ពីថ្ងៃបានចុះបញ្ជីពាណិជ្ជកម្មតាមបញ្ញត្តិច្បាប់ក្រុមហ៊ុននេះមាននីតិបុគ្គលិកលក្ខណៈផ្ទាល់ហើយស្ថិតក្រោមការគ្រប់គ្រងរបស់ច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជាព្រមទាំងក្រោមការកំណត់នៃប្រការទាំងឡាយដែលចែងក្នុងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

## ប្រការ ២

## កម្មវត្ថុអាជីវកម្ម

ក្រុមហ៊ុនមានកម្មវត្ថុអាជីវកម្មនៅកម្ពុជានិងនៅប្រទេសដទៃដោយចំពោះឬមិនចំពោះដូចតទៅ ៖

| | | |
|---|---|---|
| 261 | | **កម្មន្តសាល គ្រឿងបង្គុំអេឡិចត្រូនិក** |
| | 26120 | កម្មន្តសាល សឺមីកុងឌុចទ័រ និងគ្រឿងបង្គុំអេឡិចត្រូនិកដទៃទៀត |
| 464 | | **ការលក់ដុំទំនិញប្រើប្រាស់ក្នុងផ្ទះ** |
| | 46431 | ការលក់ដុំផលិតផលឱសថ និងផលិតផលសុខាភិបាល |
| 521 | | **ការស្តុកទំនិញក្នុងឃ្លាំង និងការស្តុកទុក** |
| | 52100 | សេវាកម្មស្តុកទំនិញក្នុងឃ្លាំង និងការស្តុកទុក |
| 681 | | **សកម្មភាពអចលនទ្រព្យ ដោយប្រើអចលនទ្រព្យផ្ទាល់ខ្លួន ឬជួលពីគេ** |
| | 68101 | ការទិញ ការលក់ ការជួល និងការធ្វើអាជីវកម្មអចលនទ្រព្យផ្ទាល់ខ្លួន ឬជួលពីគេ |
| 649 | | **សកម្មភាពសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត លើកលែងតែសកម្មភាពធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍** |
| | 64991 | សេវាកម្មប្តូរប្រាក់ |
| 861 | | **សកម្មភាពនៅមន្ទីរពេទ្យ** |
| | 86101 | សកម្មភាពមន្ទីរពេទ្យ |
| 854 | | **ការអប់រំផ្សេងទៀត** |
| | 85499 | ការអប់រំផ្សេងទៀតដែលមិនបានរាប់បញ្ចូល[៣] |
| 702 | | **សកម្មភាពពិគ្រោះយោបល់ផ្នែកគ្រប់គ្រង** |
| | 70200 | សកម្មភាពពិគ្រោះយោបល់ផ្នែកគ្រប់គ្រង |
| 781 | | **សកម្មភាពទីភ្នាក់ងារស្វែងរកការងារ** |
| | 78100 | សកម្មភាពទីភ្នាក់ងារស្វែងរកការងារ[២] |
| 620 | | **ការបង្កើតកម្មវិធីកុំព្យូទ័រ ការពិគ្រោះយោបល់ និងសកម្មភាពពាក់ព័ន្ធ** |

ក្រសួងពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
25

| | | |
|---|---|---|
| | 62020 | សកម្មភាពពិគ្រោះយោបល់កុំព្យូទ័រ និងការគ្រប់គ្រងសម្ភារៈកុំព្យូទ័រ[០] |
| 731 | | **ការផ្សាយពាណិជ្ជកម្ម** |
| | 73100 | ការផ្សាយពាណិជ្ជកម្ម[១] |
| 581 | | **ការបោះពុម្ពផ្សាយសៀវភៅ កាលិកបត្រ និងសកម្មភាពបោះពុម្ពផ្សាយផ្សេងទៀត** |
| | 58130 | ការបោះពុម្ពផ្សាយកាសែត ព្រឹត្តិបត្រ ទស្សនាវដ្តី និងកាលិកបត្រក្នុងទម្រង់ជាក្រដាស ឬអេឡិចត្រូនិច[៣] |
| 591 | | **សកម្មភាពភាពយន្ត កម្មវិធីទូរទស្សន៍ និងវីដេអូ** |
| | 59120 | សកម្មភាពក្រោយការផលិតភាពយន្ត កម្មវិធីទូរទស្សន៍ និងវីដេអូ[៤] |
| 522 | | **សកម្មភាពគាំទ្រការដឹកជញ្ជូន** |
| | 52299 | សកម្មភាពគាំទ្រការដឹកជញ្ជូនដទៃផ្សេងទៀតដែលមិនបានរាប់បញ្ចូល[៣] |
| 421 | | **សំណង់ផ្លូវថ្នល់ និងផ្លូវដែក** |
| | 42101 | សំណង់ផ្លូវ ថ្នល់ ស្ពាន និងផ្លូវក្រោមដី[២] |
| 711 | | **សកម្មភាពស្ថាបត្យកម្មនិងវិស្វកម្ម និងការពិគ្រោះយោបល់បច្ចេកទេសដែលពាក់ព័ន្ធ** |
| | 71101 | សេវាកម្មស្ថាបត្យកម្ម[២] |
| 791 | | **សកម្មភាពទីភ្នាក់ងារទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍** |
| | 79110 | សកម្មភាពទីភ្នាក់ងារទេសចរណ៍[១] |

ការចូលរួមតាមគ្រប់មធ្យោបាយរបស់ក្រុមហ៊ុនជាមួយរាល់សហគ្រាសឬក្រុមហ៊ុនដទៃដែលមាន ហើយឬដែលនឹងបង្កើតនិងដែលមានជាប់ទាក់ទងដោយចំពោះឬមិនចំពោះដល់កម្មវត្ថុអាជីវកម្មពិសេសតាមវិធីបង្កើតក្រុមហ៊ុនថ្មីភាគទុនការចុះឈ្មោះឬទិញសិទ្ធិសមាជិកការរំលាយបញ្ចូលគ្នាសម្ព័ន្ធភាពឬការចូលរួមសហប្រតិបត្តិការនានា។

ជាទូទៅក្រុមហ៊ុនធ្វើរាល់ប្រតិបត្តិការពាណិជ្ជកម្មដែលជាប់ទាក់ទងដោយចំពោះឬមិនចំពោះជាមួយកម្មវត្ថុខាងលើឬកម្មវត្ថុប្រហាក់ប្រហែលគ្នាឬប្រទាក់គ្នាឬដែលមានចរិតសំដៅអនុគ្រោះដល់កិច្ចអភិវឌ្ឍប្រតិបត្តិការរបស់ក្រុមហ៊ុន។

## ប្រការ ៣
## ទីស្នាក់ការ

ទីស្នាក់ការក្រុមហ៊ុនតាំងនៅ៖ ផ្ទះលេខ ៩ ផ្លូវលេខ ២៧៨ សង្កាត់បឹងកេងកង ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។ ទីស្នាក់ការនេះនឹងអាចត្រូវបានផ្ទេរទៅនៅកន្លែងផ្សេងទៀតក្នុងក្រុងដដែលអាស្រ័យដោយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលនិងផ្ទេរទៅទីកន្លែងផ្សេងទៀតក្រៅពីរាជធានីភ្នំពេញអាស្រ័យដោយសេចក្តីសំរេចមហាសន្និបាតម្ចាស់ហ៊ុន។

តាមសេចក្តីសំរេចនៃមហាសន្និបាតម្ចាស់ហ៊ុនព្រមទាំងអនុលោមទៅតាមច្បាប់ជាធរមានក្រុមហ៊ុនអាចមានសាខាមួយឬច្រើនកន្លែងរបស់ក្រុមហ៊ុននៅតាមបណ្តាខេត្តនានាឬនៅបរទេស។

## ប្រការ ៤
## ថិរវេលា

ថិរវេលាសកម្មភាពរបស់ក្រុមហ៊ុនមានចំនួន៩៩ឆ្នាំដែលត្រូវផ្តើមគិតចាប់ពីថ្ងៃបានចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្មលើកលែងតែមានករណីរំលាយក្រុមហ៊ុនមុនកាលកំណត់ឬការពន្យារពេលបន្តថិរវេលានេះអាចត្រូវបានរំលាយមុនពេលកំណត់ឬអាចត្រូវបានពន្យារពេលបន្ត។

យ៉ាងតិចណាស់មួយឆ្នាំមុនការផុតកំណត់នៃថិរវេលា៩៩ឆ្នាំនេះប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំឲ្យមានការប្រជុំមហាសន្និបាតនៃម្ចាស់ហ៊ុនដើម្បីសំរេចទៅតាមលក្ខខណ្ឌទាំងឡាយនៃកូរ៉ុមនឹងភាគច្រើនដែលតំរូវចាំបាច់សំរាប់កែប្រែលក្ខន្តិកៈថាតើក្រុមហ៊ុនត្រូវរំលាយឬត្រូវពន្យារពេលបន្ត។បើប្រធានក្រុមប្រឹក្សាភិបាលមិនបានកោះប្រជុំធ្វើសេចក្តីសំរេចនេះទេសម្លេង១/៣នៃអំណាចបោះឆ្នោតម្ចាស់ហ៊ុនទាំងអស់ក្រោយពេលដែលបានដាក់ពាក្យសុំឲ្យប្រជុំតាមរយៈលិខិតអនុសិដ្ឋិហើយមិនបានទទួលផលតាមសំណូមពរនោះអាចស្នើសុំទៅប្រធានតុលាការមានសមត្ថកិច្ចតែងតាំងអាណត្តិគាហករបស់តុលាការឲ្យទទួលបន្ទុករៀបចំការប្រជុំក្នុងនាមម្ចាស់ហ៊ុនទាំងអស់ធ្វើសេចក្តីសំរេចអំពីបញ្ហានេះ។

ក្រសួងពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

## ប្រការ ៥
## ដើមទុន-ភាគហ៊ុន- ម្ចាស់ហ៊ុន

### ៥-១ ៖ដើមទុន-ភាគហ៊ុន

ម្ចាស់ហ៊ុនដែលមានរាយនាមដូចខាងក្រោមបានដាក់ភាគទុនជាសាច់ប្រាក់ដូចតទៅ ៖

១- លោក ................................ ចំនួន ៩៨០,០០០,០០០ រៀល

២- កញ្ញា ................................ ចំនួន ១,០២០,០០០,០០០ រៀល

សរុបភាគទុនទាំងអស់ចំនួន ២,០០០,០០០,០០០ រៀល (ពីរពាន់លានរៀល)

ភាគទុនសរុបចំនួន ២,០០០,០០០,០០០ រៀលនេះត្រូវបង់ចូលមកក្នុងបេឡាក្រុមហ៊ុនជាសាច់ប្រាក់ទាំងស្រុងនិងគ្រប់ចំនួនដោយម្ចាស់ហ៊ុនទៅតាមភាគហ៊ុនផ្ទាល់របស់ខ្លួនម្នាក់ៗហើយការបង់បញ្ចូលនេះត្រូវបានម្ចាស់ហ៊ុនទាំងអស់គ្នាទទួលស្គាល់ថាពិតជាបង់គ្រប់ចំនួនមែន។

ដើមទុនចុះបញ្ជីក្រុមហ៊ុនត្រូវបានកំណត់ចំនួន ២,០០០,០០០,០០០ រៀល (ពីរពាន់លានរៀល)ស្មើនឹងចំនួនទឹកប្រាក់សរុបដែលបានបង់ខាងលើ។ដើមទុននេះត្រូវបានបែងចែកជាចំនួន១០០,០០០ហ៊ុនដែលនៅក្នុងនោះភាគហ៊ុននិមួយៗមានតម្លៃ ២០,០០០ រៀល។

ភាគហ៊ុនទាំងឡាយខាងលើនេះត្រូវតែបង់បញ្ចូលក្នុងក្រុមហ៊ុនទាំងស្រុងនិងគ្រប់ចំនួនហើយត្រូវបានបែងចែកនិងចុះលេខជូនម្ចាស់ហ៊ុនម្នាក់ៗទៅតាមសមាមាត្រនៃភាគទុនរៀងៗខ្លួនគឺ ៖

១- លោក ........................... មានចំនួន ៤៩,០០០ ភាគហ៊ុនពីលេខ ០០,០០១ ដល់លេខ ៤៩,០០០

២- កញ្ញា ........................... មានចំនួន ៥១,០០០ ភាគហ៊ុនពីលេខ ៤៩,០០១ ដល់លេខ ១០០,០០០

សរុបចំនួនភាគហ៊ុនមាន១០០,០០០ភាគហ៊ុនស្មើនឹងដើមទុនក្រុមហ៊ុនចំនួន ២,០០០,០០០,០០០ រៀល

(ជាអក្សរ ៖ចំនួនមួយរយពាន់ភាគហ៊ុនស្មើនឹងដើមទុនពីរពាន់លានរៀល)

ពល់ម្ចាស់ហ៊ុនប្រកាសជាភាគហ៊ុនចំនួន១០០,០០០ភាគហ៊ុនដែលបានបង្កើតឡើងនិងបែងចែកតាមសមាមាត្រដូចខាងលើគឺបានទទួលការយល់ព្រមពេញគ្នានិងគ្នាព្រមទាំងបានត្រូវបង់បញ្ចូលគ្រប់ចំនួនមកក្នុងក្រុមហ៊ុន។គ្រប់ភាគហ៊ុនត្រូវបានចុះបញ្ជីទៅតាមចំណែកនៃម្ចាស់ហ៊ុន។

អាចទទួលសិទ្ធិជាម្ចាស់ហ៊ុននៅក្នុងក្រុមហ៊ុនតែល្គឹកណាដែលមានកម្មសិទ្ធិភាគហ៊ុនដែលបានបែងចែកជូន។ក្នុងករណីចង់ធ្វើអនុប្បទានភាគទុនត្រូវតែមានការព្រមព្រៀងពេញម្ចាស់ហ៊ុនទៅតាមលក្ខខណ្ឌដែលមាននៅក្នុងប្រការទី៦ចំណុច៦-២នៃលក្ខន្តិកៈនេះ។

## ៥-២ ៖ ការបង្កើនដើមទុន - ការបន្ថយដើមទុន

### ការបង្កើនដើមទុន

ដើមទុនអាចត្រូវបានបង្កើនតាមគ្រប់វិធីដែលច្បាប់អនុញ្ញាតព្រមទាំងឲ្យស្របទៅតាមសេចក្តីសំរេចរបស់មហាសន្និបាតម្ចាស់ហ៊ុន ៖

- បង្កើតបន្ថែមនូវភាគហ៊ុនថ្មីៗជាសាច់ប្រាក់ឬជាវត្ថុ
- បង្វិលបញ្ចូលមួយភាគឬទាំងស្រុងនៃមូលនិធិបំរុងមកក្នុងដើមទុន
- តម្លើងតម្លៃនៃភាគហ៊ុននិមួយៗដែលមានរួចហើយ
- តាមគ្រប់វិធីដទៃទៀតដែលច្បាប់អនុញ្ញាត។

ក្នុងករណីបង្កើនដើមទុនតាមវិធីតំលើងតម្លៃនៃភាគហ៊ុនដែលមានរួចហើយនិងដែលត្រូវបង់ចូលមកក្នុងក្រុមហ៊ុនជាសាច់ប្រាក់នោះត្រូវតែមានសេចក្តីសំរេចដោយឯកច្ឆ័ន្ទអំពីម្ចាស់ហ៊ុន។

ការយល់ព្រមទទួលជាអនុប្បទានិកចំពោះជនដែលត្រូវបញ្ចូលមកក្នុងក្រុមហ៊ុននាឱកាសបង្កើនដើមទុនស្របទៅតាមប្រការទី៦ត្រូវតែធ្វើឲ្យបានត្រឹមត្រូវទៅតាមលក្ខខណ្ឌកំណត់ក្នុងប្រការនេះ។

ក្នុងករណីបង្កើនដើមទុនដោយដាក់បន្ថែមភាគទុនជាវត្ថុភាគទុនជាវត្ថុនេះត្រូវតែបានវាយតម្លៃដោយស្នងការភាគទុនកាលណាតម្លៃភាគទុននេះលើសពី៤០%នៃដើមទុន។បើតម្លៃភាគទុនជាវត្ថុនេះមានតម្លៃតិចជាង៤០%នៃដើមទុនក្រុមហ៊ុនការវាយតម្លៃភាគទុននេះអាចធ្វើឡើងដោយត្រឹមតែម្ចាស់ហ៊ុនទាំងអស់គ្នា។

ក្នុងករណីបង្កើនដើមទុនដោយភាគទុនជាសាច់ប្រាក់រាល់ម្ចាស់ហ៊ុនលើកលែងតែមានការប្រកែកត្រឹមត្រូវមានសិទ្ធិជ្រើសរើសយកចំនួនភាគទុនថ្មីទៅតាមសមាមាត្រនៃភាគទុនដែលខ្លួនមានទៅតាមបែបបទមួយកំណត់ដោយសេចក្តីសំរេចនៃមហាសន្និបាតម្ចាស់ហ៊ុន។

### ការបន្ថយដើមទុន

ដើមទុនអាចត្រូវបានបន្ថយអាស្រ័យដោយសេចក្តីសំរេចនៃមហាសន្និបាតម្ចាស់ហ៊ុនដែលសំរេចទៅតាមលក្ខខណ្ឌបញ្ញត្តិនៃច្បាប់។ក៏ប៉ុន្តែការបន្ថយដើមទុនមិនត្រូវឲ្យប៉ះពាល់ដល់សមភាពនៃម្ចាស់ហ៊ុនឬក៏មិនត្រូវឲ្យនៅតិចជាងពាក់កណ្តាលនៃដើមទុនចុះបញ្ជីដំបូងនិងទាបជាងដើមទុនកំណត់ដោយច្បាប់។ការបន្ថយដើមទុនត្រូវតែអនុញ្ញាតដោយមហាសន្និបាតម្ចាស់ហ៊ុន។

## ៥-៣ ៖ មហាសន្និបាតម្ចាស់ហ៊ុន

៥-៣.១ ៖

មហាសន្និបាតម្ចាស់ហ៊ុនត្រូវប្រារព្ធឡើងយ៉ាងហោចណាស់១ឆ្នាំម្តងក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាភិបាល។

៥-៣.២ ៖

មហាសន្និបាតម្ចាស់ហ៊ុនអាចកោះប្រជុំនៅពេលណាក៏បានដោយសំលេងភាគច្រើនរបស់ក្រុមប្រឹក្សាភិបាលឬដោយប្រធានក្រុមប្រឹក្សាភិបាលឬដោយសំលេងភាគច្រើននៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនឬដោយសវនករ។

៥-៣.៣ ៖

សម័យប្រជុំនៃមហាសន្និបាតត្រូវធ្វើឡើងនៅទីស្នាក់ការក្រុមហ៊ុនឬនៅទីកន្លែងដទៃទៀតដូចមានបញ្ជាក់ក្នុងលិខិតអញ្ជើញ។លិខិតអញ្ជើញត្រូវមានចែងពីកាលបរិច្ឆេទរបៀបវារៈនិងទីកន្លែងនៃមហាសន្និបាតនិងផ្ញើជូនម្ចាស់ហ៊ុនទាំងអស់យ៉ាងយូរ២០ថ្ងៃមុនថ្ងៃប្រជុំ។

រាល់ម្ចាស់ហ៊ុនត្រូវតែកល់ទុកនៅក្នុងទីស្នាក់ការក្រុមហ៊ុននូវអាសយដ្ឋានជាក់លាក់បច្ចុប្បន្នរបស់ខ្លួន។បើពុំដូច្នោះទេម្ចាស់ហ៊ុននោះមិនអាចប្តឹងតវ៉ាបានឡើយប្រសិនបើខ្លួនមិនបានទទួលសេចក្តីជូនដំណឹងពីកិច្ចប្រជុំណាមួយ។

៥-៣.៤ ៖

កូរ៉ុមនៃមហាសន្និបាតម្ចាស់ហ៊ុនត្រូវបានកំណត់ចំនួនសំលេងភាគច្រើនលើសពីពាក់កណ្តាលនៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុន។

ក្នុងករណីមហាសន្និបាតលើកទី១មិនបានទទួលកូរ៉ុមគ្រប់គ្រាន់តាមចំនួនកំណត់ខាងលើនេះទេត្រូវកោះប្រជុំមហាសន្និបាតលើកទី២ក្នុងអំឡុងពេលយ៉ាងហោចណាស់២០ថ្ងៃក្រោយ។

កូរ៉ុមនៃមហាសន្និបាតលើកទី២ត្រូវបានកំណត់ចំនួនសំលេងយ៉ាងតិច១/៣នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុន។

៥-៣.៥ ៖

សេចក្តីសំរេចរបស់មហាសន្និបាតម្ចាស់ហ៊ុនអាចយកជាការបានលុះណាតែមានការយល់ព្រមពីម្ចាស់ហ៊ុនដែលតំណាងឲ្យសំលេងភាគច្រើនលើសពី៥១%នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ។

៥-៣.៦ ៖

មហាសន្និបាតម្ចាស់ហ៊ុនអាចធ្វើឡើងដោយការផ្ញើចំលើយជាលិខិតលាយលក្ខអក្សរជំនួសការមកចូលរួមប្រជុំដោយផ្ទាល់។

ក្នុងករណីនេះសេចក្តីសំរេចអាចយកជាការបានលុះណាតែមានការយល់ព្រមជាឯកច្ឆ័ន្ទអំពីម្ចាស់ហ៊ុនទាំងអស់។

៥-៣.៧ ៖

ម្ចាស់ហ៊ុនទាំងអស់មានសិទ្ធិពេញលេញនៅក្នុងការចូលរួមធ្វើសេចក្តីសំរេចចិត្តទោះបីគេមានឋានៈណាក៏ដោយឬមានភាគហ៊ុនប៉ុន្មានក៏ដោយ។គេមានសិទ្ធិផ្តល់សំលេងស្មើនឹងចំនួនភាគហ៊ុនដែលគេមានដោយគ្មានការកម្រិតអ្វីឡើយ។ម្ចាស់ហ៊ុនម្នាក់អាចចាត់តាំងឲ្យសហព័ទ្ធខ្លួនចូលរួមជាតំណាងនៅក្នុងសេចក្តីសំរេចនានា។ម្ចាស់ហ៊ុនម្នាក់អាចប្រគល់សិទ្ធិជូនម្ចាស់ហ៊ុនម្នាក់ទៀតធ្វើជាតំណាងរបស់ខ្លួនដែរលើកលែងតែក្រុមហ៊ុនមានម្ចាស់ហ៊ុនតែ២រូប។ទោះបីក្នុងករណីណាក៏ដោយម្ចាស់ហ៊ុនម្នាក់អាចប្រគល់សិទ្ធិជូនតតិយជនណាម្នាក់ធ្វើជាតំណាងរបស់ខ្លួនដោយមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវ។

**៥-៣.៤ ៖**

កំណត់ហេតុទាំងឡាយត្រូវរៀបរៀងលើបញ្ជីមួយមានចុះលេខទំព័រនិងចុះហត្ថលេខាសង្ខេបឬក៏លើសន្លឹកក្រដាសមានចុះលើទំព័រនិងចុះហត្ថលេខាសង្ខេបស្របទៅតាមច្បាប់។

សេចក្ដីចំលងឬសំរង់នៃកំណត់ហេតុទាំងនេះមានតម្លៃប្រើប្រាស់បានលុះណាតែមានចុះហត្ថលេខាបញ្ជាក់ថាត្រឹមត្រូវអំពីប្រធានក្រុមប្រឹក្សាភិបាល។

**៥-៤ ៖ កិច្ចសន្យារវាងក្រុមហ៊ុនជាមួយម្ចាស់ហ៊ុន ឬជាមួយអភិបាល**

កិច្ចសន្យាទាំងឡាយដែលធ្វើឡើងរវាងក្រុមហ៊ុនជាមួយម្ចាស់ហ៊ុនឬជាមួយអភិបាលត្រូវតែដាក់ស្នើសុំសេចក្ដីសំរេចអំពីសន្និបាតនៃម្ចាស់ហ៊ុន។

ត្រូវតែដាក់ស្នើសុំសេចក្ដីសំរេចអំពីសន្និបាតនៃម្ចាស់ហ៊ុនដែរចំពោះកិច្ចសន្យាទាំងឡាយដែលធ្វើឡើងរវាងក្រុមហ៊ុននេះជាមួយនឹងក្រុមហ៊ុនមួយដទៃទៀតដែលមានម្ចាស់ហ៊ុនឬអភិបាលជាម្ចាស់ហ៊ុនឬអភិបាលនៃក្រុមហ៊ុនដើម។

**៥-៥ ៖ សិទ្ធិទាក់ទងពត៌មានរបស់ម្ចាស់ហ៊ុន**

នៅក្នុងពេលពិគ្រោះយោបល់របស់ម្ចាស់ហ៊ុនទាំងឡាយទោះបីតាមលិខិតក្ដីឬតាមមហាសន្និបាតក្ដីម្ចាស់ហ៊ុនម្នាក់ៗមានសិទ្ធិទាក់ទងឯកសារនិងពត៌មានចាំបាច់ដើម្បីគេអាចថ្លែងគំនិតបានដោយត្រឹមត្រូវនិងប្រកាន់យកសេចក្ដីវិនិច្ឆ័យណាមួយលើការចាត់ចែងក្រុមហ៊ុន។

ម្យ៉ាងទៀតនៅរាល់ពេលណាក៏ដោយម្ចាស់ហ៊ុនមានសិទ្ធិស្នើសុំឲ្យក្រុមហ៊ុនចេញសេចក្ដីចំលងនៃលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងដែលមានបញ្ជាក់ការចំលងត្រឹមត្រូវមានតម្លៃប្រើប្រាស់តាមច្បាប់ជាធរមាន។

**៥-៦ ៖ សវនករ**

ម្ចាស់ហ៊ុនទាំងអស់អាចតែងតាំងដោយសេចក្ដីសំរេចមហាសន្និបាតម្ចាស់ហ៊ុននូវសវនករមួយរូបឬច្រើនរូបដោយអនុលោមទៅតាមបទបញ្ញត្តិនៃច្បាប់។

អាណត្តិនៃសវនករមានរយៈពេលកំណត់ចំនួន៣ឆ្នាំ។សវនករត្រូវបានទទួលប្រាក់រង្វាន់ស្របទៅតាមច្បាប់។

**៥-៧ ៖ គណនីចរន្ត**

ដោយមានការព្រមព្រៀងគ្នាជាមួយអភិបាលម្ចាស់ហ៊ុនម្នាក់ៗអាចបង្វិលឬដាក់ជាគណនីចរន្តចូលទៅក្នុងបេឡាក្រុមហ៊ុននូវប្រាក់មួយចំនួនដែលចាំបាច់ដល់តំរូវការប្រើប្រាស់របស់ក្រុមហ៊ុន។
ចំណូលប្រាក់ទាំងនេះអាចផ្ដល់ការប្រាក់ឬអាចជាប្រាក់គ្មានការនិងអាចត្រូវបានប្រើប្រាស់ក្នុងលក្ខខណ្ឌដែលអភិបាលកំណត់។

ការប្រាក់ដែលផ្ដល់ឲ្យត្រូវចុះបញ្ចូលទៅក្នុងសោហ៊ុយចំណាយទូទៅនិងអាចត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ។

គណនីចរន្តទាំងឡាយមិនត្រូវបានចាត់ទុកជាកូនបំណុលឡើយ។ក្រុមហ៊ុនមានអំណាចសងវិញទាំងស្រុងឬសងវិញជាផ្នែកៗក្រោយពីបានជូនដំណឹងជាលាយល័ក្ខអក្សរមួយខែមុន។ការសងនេះជាដំបូងត្រូវសងជូនទៅគណនីចរន្តណាដែលមានទឹកប្រាក់ខ្ពស់ជាងគេ។ក្នុងករណីគណនីចរន្តទាំងនោះមានទឹកប្រាក់ស្មើគ្នាការសងត្រូវសងទៅតាមសមាមាត្រដូចគ្នាលើគណនីនិមួយៗ។

ម្ចាស់ហ៊ុនណាដែលចង់ដកយកវិញនូវប្រាក់ដែលខ្លួនបានដាក់ត្រូវជូនដំណឹងចំពោះអភិបាលក្នុងរយៈពេល៣ខែជាមុន។

# ប្រការ ៦
# ភាគហ៊ុននៃក្រុមហ៊ុន អនុប្បទាន និង ការផ្ទេរភាគហ៊ុន

## ៦-១ ៖ ភាគហ៊ុននៃក្រុមហ៊ុន

### ៦-១.១ ៖ សិទ្ធិ និងភារកិច្ចនៃភាគហ៊ុន

រាល់ភាគហ៊ុនមិនអាចត្រូវតំណាងដោយប័ណ្ណលក់ដូរសេរីលើផ្សារហ៊ុនបានឡើយ។ភាគហ៊ុននិមួយៗផ្តល់ជូនកម្មសិទ្ធិករនូវសិទ្ធិស្មើគ្នាក្នុងប្រាក់ចំណេញនិងទ្រព្យសកម្មរបស់ក្រុមហ៊ុន។

ភាគហ៊ុនមួយផ្តល់នូវអំណាចមានសំលេងមួយនៅក្នុងការបោះឆ្នោតនិងនៅក្នុងសេចក្តីសំរេចចិត្តទាំងឡាយរបស់ក្រុមហ៊ុន។

ម្ចាស់ហ៊ុនទាំងឡាយទទួលខុសត្រូវនិងរ៉ាប់រងចំពោះបំណុលនិងការខាតបង់របស់ក្រុមហ៊ុនត្រឹមតែចំនួនទឹកប្រាក់នៃភាគទុនផ្ទាល់របស់ខ្លួនដែលមានដាក់មកក្នុងក្រុមហ៊ុន។លើសពីនេះរាល់ការអំពាវនាវមូលនិធិអំពីសាធារណៈជនត្រូវបានហាមឃាត់។

ការកាន់កាប់កម្មសិទ្ធិលើភាគហ៊ុនមួយផ្តល់នូវសិទ្ធិអំណាចពេញលេញក្នុងការចូលរួមជាម្ចាស់ហ៊ុនក្នុងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុននិងសិទ្ធិអំណាចចូលរួមក្នុងមហាសន្និបាតទាំងឡាយនៃក្រុមហ៊ុន។

ទោះបីនៅក្នុងដៃជនណាក៏ដោយរាល់សិទ្ធិអំណាចនិងភារកិច្ចរបស់ភាគហ៊ុនត្រូវរក្សាទុកដដែល។

អ្នកតំណាងប្រតិសិទ្ធិទាយាទនិងម្ចាស់បំណុលផ្ទាល់ខ្លួនរបស់ម្ចាស់ហ៊ុនម្នាក់ៗទោះបីក្នុងលេសណាមួយក៏ដោយមិនមានសិទ្ធិបង្ខំបិទទ្វារក្រុមហ៊ុនឃុំឃាំងទ្រព្យសម្បត្តិនិងឯកសាររបស់ក្រុមហ៊ុនឬក៏ជ្រៀតជ្រែកតាមបែបណាមួយក្តីចូលទៅក្នុងកិច្ចការគ្រប់គ្រងក្រុមហ៊ុនឡើយ។អ្នកទាំងនេះនៅក្នុងការអនុវត្តន៍សិទ្ធិរបស់ខ្លួនត្រូវគោរពទៅតាមសេចក្តីសំរេចនៃការជំរះបញ្ជីសារពើភ័ណ្ឌនិងសេចក្តីសំរេចនៃម្ចាស់ហ៊ុនទាំងអស់។

### ៦-១.២ ៖ អវិភាគីយភាព នៃភាគហ៊ុន

ភាគហ៊ុននិមួយៗមិនអាចចែកបានចំពោះក្រុមហ៊ុន។កម្មសិទ្ធិករអវិភាគទាំងឡាយ (ដែលទទួលកម្មសិទ្ធិទាំងមូល)ត្រូវតែងតាំងអាណត្តិគាហករមួយរូបដែលជ្រើសរើសយកពីក្នុងចំណោមខ្លួនទាំងឡាយឬអ្នកដទៃពីនេះដើម្បីធ្វើជាតំណាងនៅអមក្រុមហ៊ុន។បើគ្មានការព្រមព្រៀងគ្នាទេកម្មសិទ្ធិករអវិភាគដែលរៀសវៃជាងគេត្រូវស្នើសុំទៅប្រធានតុលាការមានសមត្ថកិច្ចឲ្យតែងតាំងអាណត្តិគាហកនេះ។

## ៦-២ ៖ អនុប្បទាន និង ការផ្ទេរភាគហ៊ុន

**៦-២.១** ពេលម្ចាស់ហ៊ុនអាចធ្វើអនុប្បទានភាគហ៊ុនរបស់ខ្លួនមួយផ្នែកឬទាំងស្រុងនិងគ្រប់ពេលវេលាជូនទៅម្ចាស់ហ៊ុនដូចគ្នាឬជូនទៅតតិយជនជាសមាជិកគ្រួសារបុគ្គលដទៃឬក្រុមមនុស្សផ្សេងទៀតដែលមានផលប្រយោជន៍គ្រួសារឬអាជីវកម្មរួមគ្នា។

រាល់អនុប្បទានភាគហ៊ុនត្រូវតែធ្វើឡើងជាលាយល័ក្ខអក្សរជាលិខិតរវាងឯកជនឬជាលិខិតសារការី។ដើម្បីមានប្រសិទ្ធិភាពជាមួយក្រុមហ៊ុនឬជាមួយតតិយជនលិខិតនេះត្រូវមានការបញ្ជាក់ទទួលស្គាល់របស់

